ទិនានុប្បវត្តិ

ព្រះពុទ្ធសាសនា

ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL
B 3900

ឆ្នាំ ២៥៦២ ព.ស.



ព.ស.
ត.ស.
ក្រសួង
ទូរស័ព្ទ

មហាកុដិសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក

ទីចាត់ការ វត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ

បណ្ណាធិការ ហួត-ហៀម

មាតិកាសៀវភៅ

		ចំណាំពីកូរសាស្ត្រ	ទំព័រទី ១
បណ្ឌាធិការ	. . . . .		
ផេង-ជ្រឿន	. . . . .	ព្រោះហេតុនៃសេចក្តីសុខស្រួលជាសាធារណៈ	— ៣
រ៉ាយ-ប៊ុក	. . . . .	ហេតុដូចម្តេចបានជានាងខ្ញុំទៅជាសាវិកា-	
		នៃព្រះពុទ្ធសាសនា	— ៥
	. . . . .	លិខិតបណ្ណាធិការ	— ៧
	. . . . .	លិខិតសមណនិស្សិតយើង	— ៩
ប្រស័ដ្ឋបញ្ញាចិត្ត	. . . . .	កឋិនពិធម៌	— ១១
	. . . . .	ប្រវត្តិក្មេងកំព្រា	— ១៤
បញ្ញាចិត្ត	. . . . .	ពិភពលោកអនន្តរជាន	— ១៦
ហ.ហ	. . . . .	គួរស្គាល់តញ្ញាតមជា	— ២១
សួន.សុរិន្ទ	. . . . .	បុណ្ណកុមារ	— ២៣
រ៉ាយ-ប៊ុក	. . . . .	ដំណើរទៅស្នែងទន្លាយ	— ២៦
តែ-ឆ្លុន	. . . . .	ជ័យប្រាជ្ញ	— ២៨
បញ្ញាចិត្ត	. . . . .	រឿងគួរដឹងដែលទាក់ទងនឹងថ្នាំជក់	— ៣០
ញ-សឿង	. . . . .	ពិធីបុណ្យបំបួសកុលបុត្រជាតិបារាំងសេស	— ៣៤
មហាជ្ឈាង-ខាត	. . . . .	បញ្ញត្តន្ត្រៈ	— ៤៤
តិកគួច-គីឡែង	. . . . .	អ្នកអានទស្សនាវដ្តីយើង	— ៤៦
មហា ហ៊ុយ-អ៊ួច	. . . . .	និទានខ្លី ៗ	— ៤៧
រ៉ាយ-ប៊ុក	. . . . .	រឿងទុក្ខតាធ្វើពីឧធិជាតិ	— ៥១
ប្រសឺដ្ឋបញ្ញាចិត្ត	. . . . .	ប្លែកតែពិត	— ៥២

R. Kossancavaddey Wittsalabaly R. L 22-12-55

បញ្ហាភាសាជាផ្លូវការ

យើងបានដឹងមកហើយ ក្នុងពេលប្រជុំសមាជ
តាលពីថ្ងៃទី ២៥ កញ្ញា ដើម្បីកែប្រែមាត្រារដ្ឋធម្មនុញ្ញ,
បញ្ហា-កែប្រែចំនួនឆ្នាំយដទៃទៀត យើងមិនបានយក
មកលាតត្រដាងជូនអស់លោកទេ តែយើងខ្ញុំសូមយក
បញ្ហាអក្សរសាស្ត្រដែលត្រូវប្រើមកលាតត្រដាង ដើម្បី
ជាការវិនិច្ឆ័យតទៅ ។

បញ្ហានេះ សមាជពាក់ព័ន្ធនាក់ បានអនុម័តយល់
ព្រមដោយជាប់ខាតថា ត្រូវតែប្រើភាសានឹងអក្សរ
សាស្ត្រខ្មែរជាផ្លូវការ ទោះខាងតិចនិតក៏ដោយ បន្ទាប់
ពីសរទេះដៃនៃការយល់ព្រមនេះមក, សម្តេចឧបយុវរាជ
ក៏ទ្រង់បង្ហាញយោបល់មួយដល់សមាជថា ការអនុវត្ត
តាសាជាតិក្លាមៗក្នុងពេលនេះមិនទាន់បានទេ ហេតុ
នោះត្រូវបន្ថយពេលទុកឲ្យប្រើអក្សរបរទេសបានមួយឆ្នាំ
តត់ ជាគួនឹងអក្សរសាស្ត្រយើងចាប់តាំងពីថ្ងៃទី ២៥
កញ្ញា ឆ្នាំ១៩៥៥ដល់ថ្ងៃ ២៥ កញ្ញា ឆ្នាំ ១៩៥៦ នឹង
ត្រូវផ្សអក្សរសាស្ត្រជាតិអនុវត្តិបានខ្លះៗពេញព្រះរាជ
អាណាចក្រទាំងមូលទោះបីផែនការតិចនិតក៏ដោយ ស-
មាជក៏បានយល់ព្រមដោយស្មារតីនៃក្តីកង្វល់ដែ
ព្រះបរមរាជវាំង មាត្រា៦នៃរដ្ឋធម្មនុញ្ញក៏សម្រេចដោយ
សេចក្តីយ៉ាងខ្លីបំផុតថា "ភាសាជាផ្លូវការគឺភាសាខ្មែរ"

ល្ងាចសមាជបានបើកសម័យប្រជុំជាលើកទីពីរ
វិតនៅពេលដែលរៀបបញ្ចប់សម័យប្រជុំ សម្តេចក៏
ទ្រង់បានរៀបរាប់ពីលទ្ធផល ដែលបានសម្រេចពីការ
ប្រជុំ លុះរៀបរាប់មកដល់ត្រង់មាត្រាពីរនៃរដ្ឋធម្មនុញ្ញ
ដដែលនេះ ក៏ស្រាប់តែមានសំឡេងមួយ ដែលយើង
ស្មានថាប្រហែលជាលោក ទ្រិញ-វ៉ាញ សួរថា ការ
សម្រេចពីអក្សរសាស្ត្រពេលព្រឹកមិញនេះ តើទាក់ទង
ទៅក្រសួងសិក្សាធិការជាតិដែរ- ។

សម្តេចមានបន្ទូលថា - រឿងនេះទាក់ទងទូទៅ
ទាំងអស់ ទោះបីជូចម្តេចក៏ដោយ ។

អ្នកសួរ - បើដូច្នោះយើញថាការសិក្សាបរទេស
នឹងស្ទុះទៅមុខទៀតពុំបានទេ ព្រោះថាដូចជានៅ
មហាវិទ្យាល័យជាដើម នឹងអាចយកភាសាខ្មែរមក
បង្រៀនលើវិជ្ជាតិកនិតទាំងឡាយ ដូចជាទាងវិទ្យវិជ្ជា
វិទ្យាសាស្ត្រ ទស្សនវិជ្ជា ។ល។ នោះបានទេ ព្រោះ
ពុំមានការបកប្រែក្បួនខ្នាតនៅឡើយ បើដូចនេះនឹងសូម
ឲ្យមានការសិក្សាជាភាសាបរទេសនេះតទៅទៀត ។

សម្តេចទ្រង់សួរសមាជ ។ ក៏បានយល់ព្រមម្តង
ទៀតតែសមាជលើកនេះ មានចំនួនតិចជាងការប្រជុំពី
ព្រឹក មួយជា ១០

ឯ. ខ. សមសារ៉ បានបញ្ជាក់ម្តងទៀតថា ការ
សិក្សាភាសាបារាំងនេះ នឹងឲ្យសិក្សាដែលមានឈ្មោះថា
សិក្សាជាភាសាបារាំង (Enseignement en français)
ឬជាយភាសាបារាំង (..... du français)

លោកត្រឹញ-ព័ញ សុំឲ្យមានការសិក្សាជាភាសាបារាំង (Enseignement en français)

សមាជបានយល់ព្រមម្ដងទៀត ; ស្នាទេះដែលត្រូវឡើងដោយបង្គួរ

យោបល់ខ្ញុំថា មាត្រានេះមិនគួរកែប្រែបានទេ ព្រោះជំទាស់ទីឯហេតុពីរយ៉ាង គឺ ទី១ ដោយសមាជរាប់ម៉ឺននាក់បានអនុម័តរួចទៅហើយ ច្បាប់នេះមិនអាចតែប្រែដោយមនុស្សប៉ុន្មានតិចជាង

២ — ភាសារបស់ជាតិធំបំផុតនៅត្រង់ក្រសួងសិក្សាធិការ ចុះបើយើងបណ្ដោយឲ្យក្រសួងសិក្សាធិការនៅតែទំយកតែគោលភាសាបរទេសមកបង្ហាត់តទៅដោយគ្មានលក្ខខ័ណ្ឌនោះ តើពេលណាទើមានមនុស្សចូលចិត្តប្រើអក្សរខ្មែរ បើកូនខ្មែរចេះតែអក្សរបរទេសច្រើនជាងអក្សរសាស្ត្ររបស់ខ្លួន ។

ទោះបីដូចម្ដេចក៏ដោយត្រូវតែអនុវត្តច្បាប់នេះឡើងដើម្បីជម្រុញគំនិតរបស់មនុស្សឲ្យចំប្រឹងលុះត្រាតែសម្រេច ខ្ញុំសូមយកឧទាហរណ៍មួយមកចង្អុលថា ដូចជាមនុស្សព្រមនាក់ធ្លាប់ដំណើរទៅបាត់ដំបង ម្នាក់មានតំរិតសម្រាប់បងប្អូនម្នាក់ទៀតទៅតាមទំនើង តើអ្នកទាំងពីរអ្នកណាដើរដល់មុន នេះជាបញ្ហាមួយត្រូវតែដោះ ។

បើតាមយោបល់សារពត៌មានមាតុភូមិលេខ ១៩៧ ចុះថ្ងៃ ១ តុលា ១៩៥៥ ម្ចាស់គោលរៀបរាប់អំពីផលអាក្រក់នៃការប្រើភាសាជាតិជាផ្លូវការ នៅលើអត្ថបទជា “ភាសាបរទេស” នេះជាយោបល់មួយដែលបណ្ដាលឲ្យរំតែងតែរាយផ្សាយទៅលើទៀត អ្នកនិពន្ធអត្ថបទ “ភាសាបរទេស” នោះប្រហែលជាភ្លេចនឹកនាដល់ពន្ធឹភាសាជាតិហើយមើលទៅម្ល៉ះខ្លាចក្រែង . . . . . ប្រហែលជាលោកចង់ឲ្យភាសាបរទេសមានឫសតែវាដុះដាលក្នុងប្រទេសយើង ។

លោកយល់ថាខ្មែរឯកពាជ្យតែត្រឹមប្រទេសប៉ុណ្ណោះឬ? ឬក៏ឲ្យអក្សរសាស្ត្ររបស់យើងឯពាជ្យផង ។

សង្គ្រាមភាសាទឹងអក្សរសាស្ត្រ ដែលធ្លាប់មានមកតឹងតែងតែលោកនេះជាសង្គ្រាមមួយសម្រាប់បំផ្លាញឯកពាជ្យភាពរបស់ប្រទេសនានា ដោយភាសារបស់គេលេបយកពាល់ពេលវេលា ។ កាលបើភាសាបរទេសមានជ័យជំនះលើភាសារបស់យើងហើយ មិនយូរប៉ុន្មានទេ អក្ខរម្ចាស់ភាសាគង់តែមានសិទ្ធិបញ្ចេញឫកហ៊ឺហារលើប្រទេសយើងបានក្នុងពេលណាមួយ សូមលោកត្រឡប់អានអត្ថបទនៃទស្សនាវដ្ដីយើង លេខ ១១ ឆ្នាំ ១៩៥៤ ទំព័រខាងដើមនោះ លោកនឹងអាចយល់បានដោយការត្រិះរិះ

លោក! សូមជ្រាបថាជនជាតិខ្មែរប្រហែលជាមិនយល់ដូចលោកថា ការធ្វើយឆ្ងងនឹងការគាត់ទរវាងខ្លួនខ្មែរនឹងខ្លួនបរទេសនោះត្រូវសរសេរជាអក្សរខ្មែរនោះទេ, អក្សរឬភាសារខ្មែរប្រហែលជាធ្លាប់ដែនទៅតាន់បរទេសក្នុងពេលធាប់ៗនេះពុំបានឡើយ ។ ចំពោះភាសាទិតនិកប៉ែប្រសិនជាយើងនៅតែបណ្ដោយបែបនេះ ១០ ឆ្នាំទៅមុខទៀត ក៏ខ្មែរនៅតែនិយមភាសាបរទេសដូចដែលគេទៅទំព័រទី ១៨

ជាធម្មតា គេតែងពោលថា: អ្នកនេះមិនសូវស្រួលអ្នកនោះមិនសូវសប្បាយរីករាយ ខ្ញុំមានសេចក្តីវេទនា ។ល។ តែគេមិនដឹង មិនយល់នូវប្រែកពីនៃសេចក្តីមិនគាប់អារម្មណ៍ទាំងនេះសោះ ។ គេថាជានិយមថា អ្នកណាទទួលផលបែបណា គោះប៉ុណ្ណឹងអាក្រក់ គឺមកពីខ្លួនអ្នកនោះបានប្រព្រឹត្តនូវអំពើដែលឲ្យផលបែបនោះ។ គឺថាមកពីខ្លួនឯង ធ្វើដោយខ្លួនឯង នឹងឲ្យអ្នកណាថាជួយខ្លួនបាន ។ សេចក្តីនិយមនេះមានសភាពហាក់ដូចជាសមដ៏ពិតប្រាកដ។ យើងយើញនឹងភ្នែកស្រាប់: ដែលឈ្មោះ(ក) បានមានគោគ្រឿងដ៏ចម្រើនណាស់ តែមកពីការខំប្រឹងរបស់គេ ដែលឈ្មោះ(ខ) ជាអ្នកធ្វើការដែរ ហើយថាថាជាក្រខ្សត់ ចិញ្ចឹមជីវិតដោយសេចក្តីវេទនា ក៏មកតែពីខ្លួនដែរ នឹងឲ្យជនណាថាជួយខ្លួនបាន ព្រោះជនម្នាក់ៗមានបន្ទុកផ្សេងៗពីគ្នាចំពោះខ្លួន ។ បើតាមរឿងនេះ សេចក្តីសុខទុក្ខ នឹងសេចក្តីចម្រើននៃរលាស់យស្តុទ្ធសឹងកើតមកតែអំពីរូបបុគ្គល អ្នកធ្វើដោយខ្លួនឯងប៉ុណ្ណោះ ឥតមានកត្តាអ្វីក្រៅដទៃអាចមកជួយគាំពារឬ ជួយកែឲ្យបានប្រព្រឹត្តទៅស្រួលឡើយ ។

ដូច្នេះគួរតប្បីលើកយកបញ្ហាខាងលើនេះ ទៅប្រៀបធៀបនឹងបញ្ហាខាងរុក្ខជាតិបានដែរ គឺស្វាយផ្លែមកស្វាយ ស្វាផ្លែមកស្វា ឥតមានហេតុអ្វីផ្សេងដទៃដែលត្រូវគេលើកយកមកប្រតិបត្តិ ដើម្បីកែបង្វិលឲ្យស្វាទៅជាស្វាយឬឲ្យស្វាយទៅជាស្វាបានឡើយ ។ ប៉ុន្តែបើតាមការសង្កេត រុក្ខជាតិ និងមនុស្សជាតិ មានសេចក្តីផ្សេងពីគ្នាម្យ៉ាង ដែលមំសចក្ខុយើងមិនអាចឃើញរឿរលែងតែបញ្ញាចក្ខុ ។ ឯការផ្សេងនេះគឺតួវិញ្ញាណ ។

តាមច្បាប់ព្រះពុទ្ធសាសនា តួវិញ្ញាណនេះជាអរូបធម៌ អាចអន្ទោលទៅមក ផ្លាស់ពីរូបមួយទៅមួយទ្រង់ទ្រាយពេលអនិច្ចកម្មនៃមនុស្ស ហើយអាចចម្រើនបានតាមការអប់រំ និងការសិក្សាហ្វឹកហាត់ ។ ឯរុក្ខជាតិមានសភាពផ្លុំឃើញទៅវិញ គឺដើមស្វាយ នៅតែស្វាយទ្រង់ទ្រាយនៅតែមាស ។

ប៉ុន្តែ គោះបើយ៉ាងដូច្នេះ ក៏ដើមរុក្ខជាតិអាចត្រូវគេកែប្រែឲ្យចំរើនបានខ្លះ ដោយក្រម ដោយពួកតាមទំនឹងតាមសេចក្តីប៉ុនប៉ងនៃអ្នកត្រួតការ ។ សូមគាញ្ញទាហរណ៍ខ្លះមកបញ្ជាក់ដូចតទៅ: តាលពីបឋមកប្ប រុក្ខាលតាវល្លិ៍រមែងស្ថិតនៅជាសភាពព្រៃពាំងអស់ សូម្បីតែសត្វតិរច្ឆានក៏ដូចគ្នាដែរ ។ លុះតាលជាលំដាប់មកប្រហែលជាសេចក្តីត្រួតការទេដឹង ដែលបានកែប្រែ រុក្ខាលតាវល្លិ៍ទាំងតិរច្ឆានខ្លះ ឲ្យក្លាយទៅជាវត្ថុដ៏ប្រសើរ គួរដល់ការបាន? ដូចយើងសង្កេតឃើញស្រាប់ក្នុងបច្ចុប្បន្នកាលនេះ គឺមានស្វាយស្រុក និង

ស្វាយព្រៃ មានចេកស្រុក នឹងចេកព្រៃ មានគោ
ស្រុកនឹងគោព្រៃជាអាទិ ដែលមានន័យជាវិសេសនឹងការប្រើ
ប្រកបដោយសភាពផ្សេងពីគ្នា ។ ហើយវត្ថុទាំងនេះ
ទៀត នឹងអាចចម្រើនតទៅមុខបានក៏ដោយអាស្រ័យ
វត្តិសេចក្តីយកចិត្តទុកដាក់នៃអ្នកម្ចាស់កម្មសិទ្ធិផង ។
ផលព្រឹក្សក្នុងសួន ទោះបីមានការភ្ញាយចាកពីសភាព
ព្រៃហើយក្តី នឹងអាចដុះលូតលាស់ព្រមទាំងឲ្យផលដ៏
បរិបូណ៌ស្មើគ្នាឥតមានក្តៀបក្រិនបាន លុះណាតែ
នាយសួនមានមធ្យោបាយជាកុសលគ្រប់គ្រាន់ ។

ឧទាហរណ៍: កូនដ៏ចំការទំហំមួយការ គេត្រូវ
ដាំល្ហុងបានប៉ុន្មានដើម ហើយដាំទៀតតើត្រូវលៃទុក-
ចន្លោះប៉ុន្មានម៉ែត្រពីគ្នាដើម្បីឲ្យល្ហុងអាចដុះបានល្អ មិន
ចង្អៀតចង្អល់ទើសគ្នាទៅវិញទៅមក ក្នុងការស្រូបយក
ជីរម្យ៉ាង ហើយនឹងកូនការបន្ថែមជីរខ្លះទៅលើដើម
ណាដែលអន់ខ្សោយម្យ៉ាង ព្រោះកូនកូនល្ហុងដែលត្រូវ
យកមកដាំ មានជាតិសន្ទុះផ្សេងគ្នា តាមដើមដែល
ពន្លកមុននឹងពន្លកក្រោយ ហើយនឹងតាមលក្ខណៈនៃ
ដីផង ។ ប្រសិនបើខុយ្យនបាល មិនប្រតិបត្តិតាមវិធី
ខាងលើនេះ ហើយបណ្តាយតាមយថាកម្មនៃកូនល្ហុង
នោះដើមណាខ្សោយជាងគេ នឹងនៅក្រិន បើមានផ្លែ
ក៏ផ្លែនោះមកក្តៀបមិនគួរដល់សេចក្តីត្រូវការ ។

ឯដើមល្ហុងដែលក្រិននេះ នឹងត្រូវបានការបន្ថោក
ពីនាយសួនឬ ? មែនពិត បើនាយសួនណាល្ងង់គ្មាន
ឧបាយជាកុសលច្រោកជជាំនឹងពោលថា ហេតុអ្វីក៏ឯង
មិនចំដុះដូចគេ អញបានជាជាំឯងហើយដូច្នេះទៅវិញ
តើសំដីបន្ថោសនៃនាយសួននេះសមតាមហេតុផលឬទេ
មនុស្សក្នុងសង្គមសព្វថ្ងៃ ក៏មានសភាពប្រហែលគ្នានឹង
រឿងខាងលើនេះដែរ ។ មានជនភាគច្រើនរមែងក្រែន
រស់នៅពាំងត្រដរ គ្រាន់តែហែគេហែឯងដោយសេចក្តី
ក្រៀមក្រំ ។ តើសេចក្តីមិនគាប់អារម្មណ៍នេះ បណ្តាល
មកពីខ្លួនមិនចំប្រឹងឬ ? បើតាមសេចក្តីសង្កេតយើញ
ហើយជាការណ៍ដ៏ពិតជងនោះ ក្នុងមួយថ្ងៗ គឺអ្នកពាំង
នេះហើយដែលធ្វើការច្រើនជាងគេឥតមានការសម្រាក
ឥតមានការកំសាន្តហើយគឺខ្លួនទៀតជាអ្នកត្រូវទទួលនូវ
អនិដ្ឋារម្មណ៍ជាងគេ ។ ម្យ៉ាងទៀត ដោយសេចក្តី
អស់សង្ឃឹម ទើបមានពួកខ្លះបណ្តាយខ្លួនឲ្យប្រព្រឹត្ត
ទៅតាមយថាកម្ម ។ តើរឿងបណ្តាលមកពីហេតុអ្វី ?

សេចក្តីដូចតទៅ នឹងជោះស្រាយតាមការយល់
ឃើញរបស់ខ្ញុំប្រស្នាខាងលើនេះ ។

ការមិនសូវសុខស្រួល សេចក្តីរកវាយពាំងបង្ខំ
សេចក្តីរស់នៅគ្រាន់តែកំដរគេ ពាំងនេះបណ្តាលមក
ពីប្រភពគឺសេចក្តីសុខស្រួលដ៏ហួសពីសុខមាលភាព ដ៏
លើសនៃក្រុមជនពួកខ្លះក្នុងសង្គម ។ គេបណ្តាយខ្លួន
ឲ្យអ្នកមានឯកសិទ្ធិមានសមត្ថភាពមានជាតិសន្ទុះ ស្រូប
យកជីវគឺសេចក្តីបម្រើន សេចក្តីសុខស្រួលទៅខ្លួន

តទៅទំព័រទី ១៩

ហេតុដូចម្តេចបានជានាងខ្ញុំត្រឡប់
ទៅជាសារិកានៃព្រះពុទ្ធសាសនា? (ឥន្ទវង្ស)

ការប្រតិបត្តិធ្វើឲ្យនាងខ្ញុំមិនពេញចិត្តចំពោះឫសគល់ នៃ
សាសនា សាសនានេះមានសភាពចង់រស់ជាមួលដ្ឋាន
ខាងដើម ទើសុទ្ធជាមួលដ្ឋានខាងបុណ្យ នាងខ្ញុំទំសុះទំសួច
រហាយចង្រឹតដើម្បីនឹងឲ្យស្គាល់នូវសព្ទថា "និរោធ"
នឹង "សូន្យ" ។

នេះជាគំនិតរបស់នាងខ្ញុំកាលនាងខ្ញុំចូលទៅទស្សនា
ឯសារមន្ទីរគីមេត៍ ។ ខ្ញុំមិនចង់សរសេរពីរឿងព្រះពុទ្ធ-
រូបនៅយ៉ាំងដែលគេគាំងជាបូរាណវត្ថុរបស់ខ្មែរ នៃសារ-
មន្ទីរដែលនាំឲ្យកែប្រែនូវធម្មនិយមចំពោះរបស់នាងខ្ញុំក្រៅ
ពីមនោសញ្ចេតនា, ក្រៅពីសភាពពិចារណានូវ
គាយលក្ខណៈនៃព្រះពុទ្ធរូបនោះ ។ នាងខ្ញុំលែងបាន

ពិសោធត្រង់ការសរសេរអំពីអាទិទេព ឬថ្វីបើចារណ
ញ្ញាណយ៉ាងណាអំពីរឿងនេះ ។ នាងខ្ញុំអាចនឹងពោល
បានថាតែគ្រាណាក្តីខ្ញុំត្រឡប់ទៅជំព្រះពុទ្ធរូបនោះ
សេចក្តីខ្សោយសេចក្តីភាន់ច្រឡំរបស់ខ្ញុំ ក៏រលត់រលាយ
បាត់ក្នុងពេលនោះ ។ ចិត្តខាងបូរាណីយភេញចិត្តខាង
រូបគំនូរប្រៀបដូចនៅសុទ្ធតែឃោតចេញពីជួរភ្នំធំ ។
នៃហេមាល័យ, ក្នុងពេលអ្នកណានោះ ។ នេះចំពោះថ្នាក់នៃ
"ផ្លូវដែលមានមែកប្រាំបីគឺអដ្ឋង្គិកមគ្គ" ដែលមកពីបរមោ-
ស្តាៈ (បរមត្ថសច្ចៈ) វត្ថុណាស្ថិតនៅក្រៅអាយតនៈ
វត្ថុនោះសុទ្ធតែចូលទៅក្នុងធម្មិស្ងាត់ ។ គេមិនអាចហាម
ប្រាមកុំឲ្យគិតថាៈ ការដែលពិនិត្យមើលជាងសិល្បៈខ្មែរ
ធ្វើគ្រាចំចម្ងាត់ព្រះពុទ្ធរូបតាមសភាពឈានមួយទ្រ (Dhyà-
namûdra) មានពលភាពអាចធ្វើឲ្យគាត់សមុទ្រសត-
វត្ថុបាន (ព្រះពុទ្ធរូប, ក្នុងសតវត្ស ទី ១០) ។ គេ-
អាចយល់បានថាការធ្វើបែបនេះ ជាទម្រង់មួយនៃការ-
សិក្សាដោយចំពោះវិជ្ជាយោគខាងប្រទេសទីបេត៍ឬ ?

ខ្ញុំបានសិក្សារៀនសូត្រនូវភាសាសំស្ក្រឹត, បូរាណ
វត្ថុវិជ្ជានៅប្រទេសឥណ្ឌា, ព្រមទាំងសៀវភៅព្រហ្ម-
ញ្ញសាសនានឹងពុទ្ធសាសនា ដែលគេយកមកអប់រំ
និស្សិតក្នុងសាលា ។

ចំពោះអាហារខាងប្រាជ្ញានេះ នាងខ្ញុំបានបន្ថែម
ការធ្វើសមាធិចិត្តតាមក្បួននេតិ-នេតិ (ន៏តិបតិបត្តិ)
ដែលជាផ្លូវចម្រាញ់ខាងធ្វេង, ដកឫសចិត្តចេញពីនីវណៈ
ធម្មិ ។ ផ្លូវ "នេតិ—នេតិ" ដែលគេបានពណ៌នា

នៅក្នុងគម្ពីរឧបនិស័ដ (Upanisad) នឹងនិទ្ទេសវារៈនៃគម្ពីរនេះកើតឡើងដោយព្រះពុទ្ធសាសនាខាងជើង (ចំពោះផែនការនៃកិច្ចរៃគន់ទូវអត្ថបទផ្សេង ។ គេមិនត្រូវភ្លេចថា មានតែគម្ពីរ ចន្ទោគ្យូបានីស័ដ(Chandogyo panisad) នឹងគម្ពីរព្រហទារណ្យកោបានិស័ដ (Brhadara nyako banisad) ដែលទុបត្តិឡើងតាំងពីមុនពុទ្ធសាសនា ។

មានមួយថ្ងៃ, កំពូលនៃចិត្តសទ្ធារបស់នាងខុំចំពោះគ្រឹស្តសាសនាទៅជាមានសភាពស្រាំប្រុះធាមិនអាចរចនាជាថ្មីបានឡើងវិញ។ នាងខុំខំតស៊ូនឹងចិត្តសទ្ធានោះកុំឲ្យបាក់បែកដោយធាប់រហ័សពេក។ នាងខុំខំព្យាយាមធ្វើចិត្តឲ្យបរិសុទ្ធស្អាតជូរផង់តាមការគួរ ដើម្បីនឹងបំបាត់នូវសភាពមន្ទិលក្រៅពីសេចក្តីពិត ។ ក្នុងរយៈវេលាបួនខែ នាងខុំក៏ស្ថិតនៅ មិនមែនក្នុងចិត្តសាបសូន្យទេ តែនៅក្នុងសភាពខេមួយបែប, ផែនដ៏ទ្រដើម្បីនាងខុំមិនដាប់ ។ នាងខុំក៏លះបង់ចោលអាហារចំពោះខ្ញុំការខាងសាសនា ខាងទិដ្ឋភាពក្រៅ ព្រោះថាបំណងខាងសាសនា អាចធ្វើចិត្តឲ្យដាប់ដំពាក់ផ្កាដោយរមោហៈ លោភៈដែរ ។

គម្ពីរវេទន្តៈ (វេទ) គាញចិត្តនាងខុំឲ្យពិចារណាខាងធម៌ស្មែរកហេតុផលឲ្យច្បាស់លាស់ ។ នាងខុំនឹងត្រូវសំគាល់តទៅទៀត ថាការដែលគាញចិត្តនាងខុំឲ្យទៅកាន់គម្ពីរនេះ មកពីគម្ពីរនេះមានធម្មជាតិខាងប្រាជ្ញា នាងខុំត្រូវយល់ថាគម្ពីរអ័ដវៃតា (Advaita) នៃបណ្ឌិតសង្ករៈ (Shankara) មានកំសួលស្ថិតនៅក្នុងសៀវភៅ, មិនមាននៅកន្លែងដ៏វិសាលក្នុងប្រទេសឥណ្ឌាសោះឡើយ ។ មានសញ្ញតនាខាងប្រាជ្ញារបស់នាងខុំបន្ទន់ទៅតាន់ការសិក្សាខាងព្រះសក្យមុនី, ហើយនាងខុំជូនកាលស្រាប់តែសូត្រព្រះត្រៃលក្ខណ៍ ដោយមិនបាននឹកនាសោះឡើយ ។ ប៉ុន្តែដែលនាងខុំទើបនឹងស្គាល់ទូវលទ្ធិពុទ្ធសាសនា ដោយស្ងួចស្ងើឯណាស់នាងខុំមិនគាន់ហ៊ានចូលស៊ុបក្នុងលទ្ធិនេះនៅឡើយ ។ នាងខុំស្ថិតនៅតែម្នាក់ឯងចំពោះមុខគម្ពីរនឹងអត្ថបទខាងលទ្ធិពុទ្ធសាសនា ។ នាងខុំបានព្យាយាមប្រព្រឹត្តតាមវិធីបតិបត្តិថា" ចូរអ្នកយកខ្លួនអ្នកជាបទីប ។

នាងខុំបានមកធ្វើការនៅមហាវិទ្យាល័យព័ល្លកត្តាក្នុងគ.ស.១៩៥១, ហើយនាងខុំបានទំស្ទុះស្ទែងរកគម្ពីរពុទ្ធសាសនា នឹងបូកណាតុតាំងពីភ្នំហេមាល័យរហូតដល់គោះ សីឡង់ដ៏, ក្នុងរយៈវេលា ៣ ខែ ។ នាងខុំបានរស់នៅអស់យូរកាលនាព្រះវិហារហិណ្ឌូ ។ នាងខុំបានទស្សនាទូវអាស្រមជារច្រើន បានជួបពួកវិទ្ធបណ្ឌិត, ស្វាមី នឹងសាធុជន ។ លទ្ធិផ្សេងៗចំពោះប្រពៃណីនៃបណ្ឌិតនឹងត្រកូលព្រាហ្មណ៍ បើតាមនាងខុំពិនិត្យ ដូចជាគ្រាន់តែមានវិជ្ជាខាងប្រាជ្ញានឹងសង្គមមិនមែនជាសាសនា ឬជាលទ្ធិដែលនាំមនុស្សប្រតិបត្តិតាមឲ្យរួចផុតទុក្ខទាំងពួង ។ នៅក្នុងអាស្រមឬចំពោះគ្រូដែលស្ថិតនៅឯកឯង នាងខុំពុំដែលមានបុព្វ



ខ្ញុំមានសោមនស្សចិត្តយ៉ាងក្រៃលែងចំពោះសំនួរ
នៃ "បញ្ហាប្រតិបត្តិធម៌របស់អ្នកស្រុកស្ទឹងត្រែង" ដោយ
មហាហុក-សៀកជាអ្នកនិពន្ធ ។

ខ្ញុំព្រះករុណា ខ្ញុំបាទមិនមែនជាអ្នកឈ្លាសវៃផ្លូវ
ពុទ្ធសាសនា ជាងព្រះមហាថេរគាំងឡាយ ក្នុងព្រះ
រាជណាចក្រយើងនេះទេ តែដោយខ្ញុំធ្លាប់កាន់ប្រស់ប
នឹងអ្នកប្រាជ្ញគាំងឡាយជាច្រើន ក្នុងដែនកម្ពុជរយើង
នេះ ខ្ញុំអាចវិនិច្ឆយរឿងនេះជូនបាន ។

តែមុននឹងខ្ញុំវិនិច្ឆយបញ្ហានេះ គួរតែខ្ញុំយកបញ្ហា
យ៉ាងស្រាលមួយសួរចំពោះជនអ្នកប្រតិបត្តិតាមគោល-
ការណ៍ គាំងពីរបែបនេះសិន ដើម្បីជាការត្រៀមរៀនទៅ
អនាគត ។

សួរថា: ជាយូរណាស់មកហើយ បញ្ហាបែប
នេះម្តេចក៏មិនលេចឡើងក្នុងដែននៃអ្នកពុទ្ធជន ?

ព្រះសង្ឃក្នុងពុទ្ធសាសនាមានច្បាប់ហាមឃាត់មិន
ឲ្យពុទ្ធជនទូលថានអំពីព្រះសង្ឃដែរឬទេ ? បើមានតើ
គម្ពីរណា ? មានអដ្ឋកថាដូចម្តេច ? ព្រះពុទ្ធទ្រង់
បញ្ញត្តនៅពីណា ? ចំពោះហេតុដូចម្តេច ?

សំនួរនេះជាហេតុមួយដែលត្រូវស្រាវជ្រាវតាម-
គោលនៃសាសនាសុទ្ធ ។ ហើយជាការញុំាងឲ្យអ្នក
សង្ស័យគាំងឡាយមានបញ្ហាក្តីច្បាស់ឡើង ព្រោះថាបើ
ស្រាយបញ្ហាគាំងនេះបានដោយគ្រប់គ្រាន់ ។

កាលបើពុទ្ធបរិស័ទ្យស្រុកស្ទឹងត្រែងគាំងពីរពួកនេះ
បានវិនិច្ឆយយ៉ាងច្បាស់លាស់ សូមតបដំណឹងដល់ខ្ញុំ
វិញភ្លាម នោះខ្ញុំនឹងជូនសេចក្តីពិតដោយប្រាសចាកការ
សង្ស័យមួយរំពេច ។

សូមពុទ្ធបរិស័ទដែលជាអ្នកឆ្ងឿនឆ្ងល់គាំងឡាយ
កុំធុញ្ញាន់ចំពោះការដោះស្រាយបញ្ហានេះឡើយ
ព្រោះថា បើចៀសវាងការដោះស្រាយបញ្ហានេះហើយ
ប្រាកដជាស្មុគស្មាញត្រូវតុំយើញដោយពិត ។ ហេតុ
ថា បើខ្ញុំធ្វើយជូនខ្លួនសំនួរនោះតែម្តងទៅ កំនៅសល់
ជនជំពូកខ្វះឆ្ងល់ហើយមិនដឿដែល ជាហេតុឲ្យបាប
ធម៌ចូលលុកដល់ទន្ទ្រានៃជនសប្បុរសនោះទៀត

សូមលោកអ្នកកុំភ្លេចថា ព្រះពុទ្ធមានតែមួយព្រះ
អង្គប៉ុណ្ណោះទេ ដែលធ្លាប់ប្រទានព្រះធម៌នឹងការប្រតិ-
បត្តិ ដើម្បីសេចក្តីសុខរបស់យើងគាំងឡាយ រហូតមក
ដល់បច្ចុប្បន្ននេះ មិនមានព្រះពុទ្ធពីរព្រះអង្គត្រាស់ដឹង
តែម្តងហើយ សំដែងធម៌នឹងការប្រតិបត្តិផ្សេងគ្នានោះទេ

សង្ឃឹមថា ការវិនិច្ឆ័យនឹងកើតឡើងភ្លាម ?

សូមជូនទូវសួស្តីដល់មិត្តពុទ្ធជនទាំងឡាយ !

★

★ ★

បញ្ហាអត្ថបទនៃទស្សនាវដ្តីនេះ តបលិខិតមហាគ្គ-គឺទ្បែងនៅតិណ្ណៀ ប៊ុះប្លៃ ៣០ សីហា ៥៥

ខ្ញុំព្រះករុណា មានសេចក្តីត្រេកអរជាពន្លឹកដោយលោកម្ចាស់ជួយបំពេញយោបល់ដល់ការចាត់ចែងអត្ថបទសម្រាប់ទស្សនាវដ្តីនេះ, យោបល់នោះគឺជាការប្រពៃណាស់ ហើយថែមទាំងសមរំលៅតាមលំអានដែលបណ្ណាធិការលើកមុនលោកម្ចាស់ចាត់ចែងមកហើយ, តែដោយភាគច្រើនដែលអ្នកអានទាំងឡាយបានផ្ញើលិខិតទៅខ្ញុំព្រះករុណា ច្រើនចូលចិត្តឲ្យមានអត្ថបទជាផ្លូវលោកខ្លះផង ។ យោបល់នៃអ្នកអានដែលបានផ្តល់ទាំងប៉ុន្មាននោះ ខ្ញុំពុំបានបដិសេធទាំងអស់នោះទេ ខ្ញុំបានយកយោបល់ទាំងនោះមកធ្លុំហើយពិចារណាទៅតាមហេតុផលនៃកាល:ទេស: កំកាលសម័យបានបង្ខាំបង្ខំឲ្យមានគំនិតដូចតទៅនេះ

ទស្សនាវដ្តីមិត្តសាលាចាលី ពិតមែនតែជាទស្សនាវដ្តីមួយដែលរស់នៅក្នុងសង្គមនៃសាសនាសាកល តែចំពោះសំឡេងរបស់ទស្សនាវដ្តីនេះមិនមែនគ្រាន់តែជាសំឡេងសម្រាប់ញុំាងជនលង់ទៅឲ្យស្គាល់ដៀសាសនាព្រះពុទ្ធប៊ុណ្ណោះទេ គឺត្រូវញុំាងលោកទាំងមូលឲ្យដើរស្របទៅតាមគោលនៃសាសនានេះ ដូចខ្ញុំធ្លាប់ប្រកាសជាច្រើនលើកមកហើយថា : លទ្ធិពុទ្ធជាលទ្ធិសន្តិភាពហើយជាដើមច្បាប់នៃលទ្ធិទាំងឡាយក្នុងលោកផង, កាលបែដូចនេះ លទ្ធិពុទ្ធមានលំអានតាញ្ជូវនេយោបាយពិតពលោកមកចង្អុលបង្ហាញពុទ្ធជនឲ្យដឹងឮខ្លះផង មិនមែនទស្សនាវដ្តីនេះធ្វើនយោបាយដើម្បីលោកជនទេ គឺជានយោបាយដើម្បីពុទ្ធជនឲ្យពិចារណារកកំហុសនៃនយោបាយលោកជន ។ ប៉ុះបើយើងមិនយកលំអាននៃនយោបាយផ្លូវលោកទុកឲ្យពុទ្ធជនពិចារណាទេ ធ្វើម្តេចនឹងឲ្យយើញាគោសនយោបាយ! ការប៉ុះនេះមនមានបណាងធ្វើនយោបាយទៅតាមលំអាននៃលោកជនទោះគឺទេដែរ ព្រោះលទ្ធិពុទ្ធមានសិទ្ធិជាជាប់ខាតប្រទាំងនឹងអំពើអយុត្តិធម៌និងអសន្តិភាពនឹងសែ្វងរកទីបរមសុខ គឺព្រះនិព្វានតែមួយប៉ុណ្ណោះ ។

ការនេះ បើមិត្តអ្នកអានទាំងឡាយយល់ស្របតាមខ្ញុំក៏សូមសំឡេងតាមលិខិត ព្រោះខ្ញុំកំពុងត្រូវការយោបល់ជាទីបំផុតដើម្បីចាត់ចែងទំព័រទស្សនាវដ្តីនេះ ឲ្យសមរម្យទៅតាមបែបទៅនៃសេចក្តីចំរើនខាងផ្លូវព្រះពុទ្ធសាសនា ។

សូមកុំភ្លេចថាការចំរើនទឹងសែ្វងរកសេចក្តីពិតយើញាលុះណាតែមានការប្រទាំងដោយជាប់ខាត ប៉ុះបើយើងចាំតែ អឺ ! អើ ! ទោះតើដូចម្តេចទៅអនាគតនៃទស្សនាវដ្តីនេះ ។

សូមមិត្តអភិនន្ទកុំធ្វេញព្រួយនឹងការសរសេរព្រោះ បន្ទាត់ត្រមាំងអត្ថបទនានា ។
ខ្ញុំតុងតែសប្បាយក្នុងការទទួលយោបល់នឹងការ
ប្តូរ ស្តី

ហ.ហ.

★

★ ★

សិដិតសមណនិស្សិតបែបដឹង

ការដែលយើងបានបញ្ជូននិស្សិតៗអង្គនោះយើងពុំគាន់បានដឹកបមិត្តថា តើនិស្សិតទាំងឯអង្គបានទៅដល់ទីសិក្សាហើយឬនៅ? មានកន្លែងស្រួលបួលឬទេ? ចង្ការន់បិណ្ឌបាតតើប្រព្រឹត្តទៅបែបណា ? ការនេះខ្ញុំសូមយកលិខិតរបស់សមណនិស្សិតយើង មកចុះជូនតាំងស្រួងដូចមានខាងក្រោមនេះ ៖

វិថ្ងាស្ថានទាលន្ទា ថ្ងៃទី ២៤ សីហា ព.ស.២៤៩៨

ចំពោះពរមកព្រះតេជព្រះគុណអធិតី ព្រមទាំងសមាជិកគ្រប់រូបនៃសមាគមមិត្តសាលាបាលី កម្ពុជរដ្ឋ

សូមជ្រាប ។

អាត្មាតាំងបីរូបបានទៅដល់វិថ្ងាស្ថានទាលន្ទា ពីថ្ងៃទី ២០ សីហានេះបានសុខសប្បាយទេ ។

អាត្មាបានធ្វើដំណើរចេញពីក្រុងភ្នំពេញ ដោយភាជនអាយស្នុយេយានកម្ពុជា នៅថ្ងៃទី ១២ សីហា, សំណាក់នៅអរញ្ញមួយយប់ ព្រឹកឡើងថ្ងៃទី ១៣ ឡើងរថភ្លើងរសៀមបន្តដំណើរទៅទៀតដល់ក្រុងបាងកក ម៉ោង ៤ រសៀល ។ ធ្វើដំណើរដោយរថភ្លើងតាំងពីថ្ងៃនោះបានសេចក្តីសុខស្រួល គ្មានទុបសគ្គអ្វីទេ ។ នៅឈប់ក្រុងបាងកក ៤យប់, ថ្ងៃទី ១៧ សីហា ម៉ោង ៨ ព្រឹក បានឡើងអាកាសយានសៀមពីស្ថានីយដនមឿង បានមកទៅខៀត, ដល់ស្ថានីយមង្គលដនក្រុងឆ្លិន, ភូមាម៉ោង ១០,២០ នាទី , អាកាសយានចុះឈប់ទីនេះប្រហែល ២០ នាទី ទើបបន្តដំណើរទៅក្រុងព័លកត្តា , ហោះចូលឈប់សម្រាន្តរយៈពេល ២ ម៉ោងទើបផុត , ដល់ស្ថានីយដាំដាំក្រុងព័លកត្តា ម៉ោង ២,១០ នាទី ។ ពីក្រុងបាងកកទៅព័លកត្តា អាកាសយានហោះខ្ពស់ទើបផុត ។ នៅសំណាក់តែក្នុងមហាពោធិសមាគមក្រុងព័លកត្តា ២យប់ គឺយប់ថ្ងៃទី ១៧-១៨, ថ្ងៃទី ១៩ ស៊ីហា ម៉ោង ១០ យប់ ធ្វើដំណើរពីព័លកត្តាទៅនាលន្ទាដោយមានលោកគ្រូសង្ឃរក្ខិតជាតិលង្កា នៅមហាពោធិសមាគមជួន ៧ អង្គ ។ ម៉ោង ៨ ព្រឹកថ្ងៃទី ២០ ដល់ស្ថានីយភក្តាវក្តូ (Bhaktyapur) ហើយបន្តដំណើរ

ដោយវាថាក្លែងជាតែពីតគ្មានក្លិនវៀតនាលន្ធាទៀត, ខ្ញុំឆ
១ ថ្ងៃដល់វិជ្ជាស្ថាននាលន្ធា ។

អាត្មាពាំងប៊ីរូប មានសេចក្តីរីករាយក្រៃពេក ចំ
ពោះវិជ្ជាស្ថាននេះ ដោយឃើញគ្រឹស្ថានសិក្សាយ៉ាង
ធំសង់ហើយស្រេចនៅលើទីដែលយ៉ាងធំ គណ្តាលវាល
ស្រែ មានអាកាសស្អាតល្អ មានភ្នំងអត្តិសន៍ បន្ត
មកពីក្រុងបត្ត:ដែលស្ថិតនៅចម្ងាយប្រហែល ១០០គីឡូ-
ម៉ែត្រអំពីវិជ្ជាស្ថាននេះ, មានទឹកម៉ាស៊ូនសម្រាប់ប្រើ
ប្រាស់ស្អាតល្អ ដោយគេជីកអណ្តូងយ៉ាងធំ ចាក់ស៊ី
ម៉ងត៍ក្រាលជិតពីលើខ្ទមក់តែបំពង់ចុះទៅ ហើយបូម
ឡើងដោយម៉ាស៊ូន ដែលវង្គកិច្ចាលជួយដល់វិជ្ជា
ស្ថាននេះ ។ វិជ្ជាស្ថាននេះ នៅមានការពង្រីក
យ៉ាងធំតទៅទៀត សព្វថ្ងៃគេបំរុងនឹងសង់គ្រឹស្ថាន
សិក្សាថ្មីៗថែមទៀត ព្រោះគេបំរុងនឹងបង្កើនថ្នាក់រៀនឲ្យ
ដល់ថ្នាក់ដុកទ័រវង្គកិច្ចាលបានជួយទំនុកបំរុងពេញបន្ទុកៗ

កន្លែងនៅ– កន្លែងដែលគេទុកបំរុងអាត្មាពាំងប៊ី
រូបជាសមណនិស្សិតកម្ពុជានោះ គេបានឲ្យភោកសង្ឃ
សៀមនៅទៅហើយ, ពេលអាត្មាទៅដល់ គេប្រាប់ថា
គ្មានកន្លែង, ហើយគេបំរុងឲ្យអាត្មាទៅនៅផ្ទះសំណាក់
សិន ។ រឿងនេះ អាត្មាបានដឹងយ៉ាងម្ចឹងម៉ាត់ ពុំ
ព្រមទៅនៅផ្ទះសំណាក់ ដោយអាងគោលហេតុជា
ច្រើន ដែលជាសំដីរបស់មហាវេរកស្សប: មានសំ
បុត្រដែលធ្វើទៅអាត្មា គាលនៅក្រុងបាងកកជាដើមថា
« កន្លែងបីសម្រាប់សមណនិស្សិតកម្ពុជា បានរក្សាទុកពុំ
ឲ្យអ្នកណាទេ » លោកសៀមគេវាដែកពុំចង់ចេញ
ព្រោះគេបានទៅមុនទៅហើយ ។ អាត្មាប្រាប់អ្នកចាត់
ការថា « សូមឲ្យលោកចាត់ការដោយសុទ្ធចិត្តផងចុះ »
ដើម្បីរក្សាពាក្យសច្ចៈ អ្នកចាត់ការបាននិយាយ
ទឹងលោកសៀមពាំងប៊ីរូប សុំឲ្យទៅនៅផ្ទះសំណាក់
វិញ ហើយគេឲ្យកន្លែងនោះមកអាត្មាពាំងប៊ីរូបនៅរួមគ្នា
ជាមួយលោកសៀម ១អង្គ ។ បន្ទប់ ១ ទំហំ ៦ម៉ែត្រ ៤
ជ្រុង មានអំពូលភ្លើង ២, ផ្ទៃតដាល់ ២ សម្រាប់
និស្សិត ៤រូប ។ និស្សិតមួយរូបៗ មានគ្រែសឹង ១,
តុសរសេរ ១, កៅអី ២, ទូ ១ ដោយឡែកពីគ្នា ។
អាត្មាពុំទាន់ដឹងជម្រៅ នៃការសិក្សាយ៉ាងណានៅ
ឡើយទេ ព្រោះទើបមកដល់ថ្មី ពុំទាន់បានចូលរៀន
ផង, ចាំពេលក្រោយនឹងពណ៌នាឲ្យសព្វគ្រប់ ។

រឿងបង្ហាញ– ប្រហែលជាពុំលំបាកប៉ុន្មានទេ
ព្រោះមានអ្នកធ្វើបាយវៃសម្រាប់និស្សិត, គេយក ១វៃ
៣០រូពីម្នាក់ៗ ស្មើនឹងអាហារូបករណ៍ ដែលវិជ្ជា
ស្ថានទំនុកបំរុង ៣០រូពីនោះឯង, ពុំមែន ៣៥រូពីទេ ។
អាហារគេធ្វើតាមរបៀបឥណ្ឌៀលំបាកធាន់បន្តិចដែរ ប៉ុន្តែ
សង្ឃមថា ខ្លះអាចគ្រាប្រព្រឹត្តទៅបានតាមគេតាមឯង ។

នៅទីបំផុត អាត្មាពាំងប៊ីរូបសូមសំដែងសេចក្តីស្វាមី
ភក្តិ ដ៏ចិត្តស្មោះត្រង់ចំពោះសមាគម, សូមឲ្យសមា-
គមបានចំរើនល្អតលាស់ដុះដាលជាតិយ៉ាគាពតទៅ!

ហត្ថលេខា

តិក្ខ ភ័-យ៉ាវ, មាស-ចន, អាំ-សួន

អត្ថន័យដ៏ថ្លៃ

លំនាំដើម

ព្រះពុទ្ធសាសនា ជាសាសនាដែលពិភពលោក
បានទទួលស្គាល់ តាំងមានគោលធម៌បរិបូណ៌គ្រប់គ្រាន់
ទីងមានកន្លែងដែលគួរកែប្រែបាន តែបើពោលទៅតាម
វិធីផ្លូវវិញ ក៏ត្រូវតែលៃលក៏ឲ្យសមទៅតាមកាល
សម័យ ។

ពុទ្ធជនតាំងឡាយ! គង់ធ្លាប់បានស្តាប់-សិក្សា រឿង
រ៉ាវជាច្រើនដែលទាក់ទងនឹងពុទ្ធសាសនា ព្រមទាំងព្រះ
សទ្ធម្មនៃព្រះពុទ្ធជាម្ចាស់ ដែលជាធម៌ជ្រាលជ្រៅគម្ពីរ-
ភាព បណ្តាលឲ្យពុទ្ធជនជំពូកខ្លះយល់បានដោយពិបាក,

ដូចនោះទើបខ្ញុំសុំសែងរកសៀវភៅណា ដែល
មានការបរិយាយជាវៃបេទិតាន ហើយងាយដល់ការ
អានឹងធាប់យល់ , ផលនៃសេចក្តីព្យាយាមរបស់ខ្ញុំក៏
បានប្រទះសៀវភៅមួយឈ្មោះ " កងទ័ពធម៌ " សៀវ
ភៅនេះ មានច្បាប់ដើមជាភាសាថៃ ដោយការរៀប
រៀងនៃសុជីត បុញ្ញានុភាព , ជាលេខានុការវត្តមន្ត្រី
ក្រសួងវិឡនធម៌នៅបាងកក តាលសុជីត បុញ្ញានុភាព
នៅជាតិកូភាព ហើយជាអ្នកអំណោយការមហាវិទ្យាល័យ
ព្រះពុទ្ធសាសនានៅបាងកកនៅឡើយ ។

តាលបើខ្ញុំបានសៀវភៅនេះហើយ ក៏ប្រឹងយក
មកប្រៀបធៀបជាភាសាខ្មែរ ទទួលលោកថាច់-ស៊ុំ បានប្រៀ
បរៀងរួចមុន ខ្ញុំក៏ចូលរួមពួតដៃគ្នាក្នុងរឿងនេះឡើង
ដើម្បីសម្រេចការនេះឲ្យបានធាប់ហើយ ជាការងាយដល់
ការអានឹងធាប់យល់ផង ។

ខ្ញុំមានសង្ឃឹមថា លោកអ្នកតង់បានក្លឹចស្តាប់
តាលណាលោកអ្នកបានអានរួចហើយ,

សូមទទួលចំណែកកុសលដ៏ចរិសុទ្ធដល់ព្រះតុណា
ម្ចាស់ជាបិតានៃវដ្តកម្ពុជៈដល់ពាជវង្សាតិបាល ដែលមាន
សម្តេចជាប្រមុខ ដល់លោកសុជីតបុញ្ញានុភាព និង
មិត្តរួមសាសនាតាំងឡាយ សូមឲ្យទ្រង់, អស់លោក
តង់, តាំងនៅជាសុខនឹងសម្រេចតាមគោលបំណង ។

ប្រសិដ្ឋ-បញ្ចាធ់ចិត្រ

កងទ័ពធម៌

ប្រែដោយ

ថាច់-ស៊ុំ

វិគ្គទ១

ទ្វារក្រុងពាពណាសីមិនទាន់បើកនៅឡើយ ពន្លឺ
តប់ភ្លើង ដែលភ្លឺឆ្មុះចំពែ្លងចំញ្ជាចធ្វើឲ្យមើលទៅឃើញ
ស្មុទ្ធតែពួករនេះនឹងអ្នកដំណើរ ដែលមកនៅចាំត្រៀប
ត្រា ផ្តាយព្រឹកបញ្ចេញរស្មីភ្លឺច្រាលលៀងពុំ នៅទាង

ប្អូនពិសេស. នាយទ្វារបាលពីរនាក់ឈរការពារនាទីរបស់ខ្លួន យ៉ាងស្ងប់ស្ងៀម ឥតមានអ្នកណាមាត់កនិយាយស្តីឧរញ្ជេញសំឡេងអ៊ូអែកក្នុងបរិវេណនោះឡើយ ។ នៅលើកំពែងមានតាហានយាមមួយក្រុមធំ ខ្លះដើរ ខ្លះអង្គុយមើលទៅពីជើងឃើញក្តក់ភ្លើងតូចៗ ដែលគេបង្កាត់ឡើងដោយអាស្រ័យបំណងណាមួយ ដែលចាក់ទងនឹងក្រុមតាហានទាំងនោះ អ្នកមកនៅវង់ចាំ ក្រៅពីពួកពាណិជនឹងបុញ្ញតិកជន ដែលត្រេចទៅដើម្បីនមស្ការបុញ្ញស្ថាន ព្រមទាំងអ្នកជួសនៃសាសនានិកាយផ្សេងៗមានឥត្ថន្តូ, តិរ្ថិយនឹងចរិញ្ញាដកជាដើម ហើយនៅមានពួកស្ត្រីខ្មែតជាច្រើន ដែលមកដើម្បីជួនស្វាមីខ្លះ បុត្រខ្លះ ដែលបំរុងនឹងធ្វើដំណើរចាកចេញទៅ ។

លុះព្រះសុរិយាបញ្ចេញពន្លឺក្រហមស្រាងៗនៅទិសខាងកើតហើយ នាយតាហានដែលយាមនៅលើកំពែងក៏រំស្រែកប្រាប់ផ្សែអាណត្តិសញ្ញាដោយសំឡេងដ៏ខ្លាំង នាយទ្វារបាលទាំងពីរនាក់ក៏ដកវន្ទុកបើកទ្វារចេញទៅម្នាក់ម្ខាង អ្នកដែលមកឈរង់ចាំក៏ប្រញាប់ដើរចេញទៅដោយរួសរាន់ ឈ្មួញរេះគំប្រញាប់បររេះចេញទៅដែរ មើលទៅហាក់ដូចជាសុទ្ធតែប្រញាប់ចេញទៅ ផ្សែបានធ្លាយចំផុតមុនពេលដែលព្រះអរុណ ឧទ្ធច្ចកំដៅមកលើធម្មជាតិ ពេញពី បណ្តាពួកស្ត្រីដែលដណ្តប់សំពត់ ខ្លួរក្បាលជិត នាំគ្នាមកជួនដំណើរស្វាមី ឬបងប្អូនញាតិសន្តានរបស់ខ្លួននោះ នាងខ្លះជាស្ត្រីមានសន្តានចិត្តខន់ក្លួន ក៏ជ្រប់មុខទៅនឹងជាតដែ បង្អង់ផ្សែឈ្មួនរេះដ៏វែងឆ្ងាយចេញទៅដោយសន្សឹម ចំពាំតែរេះក្រាយបង្អស់នឹងចេញផុតទ្វារក្រុងទៅ ក៏ក្លឹងស្ងាត់មើលចិញ្ចាញ្ចៃដែរយើញច្បាស់ "ពីគាស៊ីទៅគាន់មគធៈ, ពីមគធៈទៅគាន់វជ្ជី, ពីវជ្ជីទៅគាន់គោសលៈ, ពីគោសលៈទៅគាន់វង្សៈ ហើយត្រឡប់មកគាស៊ីវិញ (១)" ពាក្យខ្លី ។ ប៉ុណ្ណោះជាសញ្ញាផ្សែដឹងច្បាស់ ដល់រយៈផ្លូវដែលនឹងធ្វើដំណើរគាត់ទៅរបស់ពួកអ្នកបរេះ ក្រុមញាតិដែលនៅក្នុងក្រុងពារាណសី ត្រូវការជ្រាបអំពីដំណើរប្រព្រឹត្តទៅរបស់អ្នកទាំងនេះ កាលបើបានដំណឹងអំពីឈ្មួញរេះឬអ្នកដំណើរដទៃទៀត ក៏នឹងរង់ចាំលំដាប់ការធ្វើដំណើរថា ឥឡូវនេះ ចេញផុតអំពីដែននេះ ចូលទៅគាន់ដែននោះហើយ, ជិតដល់វេលាដែលនឹងធ្វើដំណើរត្រឡប់វិញហើយឬនៅ ។

ទំនិញដ៏សំខាន់របស់ក្រុងពារាណសី ដែលជាពាជនីរបស់ដែនកាសីនោះគឺ សំពត់ច្រើនបែបដែលត្បាញយ៉ាងល្អមានសាច់ម៉ដ្ឋ ជាទំនិយមប្រើប្រួលទៅក្នុងត្រកូលក្សត្រ, ព្រោះហ្មណ៍នឹងគហតីជាន់ខ្ពស់នៃរដ្ឋទាំងឡាយ ក្រៅពីនេះនៅមានគ្រឿងក្រអូប ដូចជាចន្ទន៍ក្រស្នានឹងគ្រឿងអប់ជាដើម ក្លិនរេះដែលបានរៀបចំជារបៀបស្រេចហើយ ក៏ផ្តុកទំនិញសំពត់ នឹងគ្រឿងក្រអូបទាំងនោះទៅជាច្រើន ។

គោដែលបានទទួលការបំប៉នស្មៅយ៉ាងល្អមុនពេល

(១) កាលបើមើលផែនដីនឹងឃើញថា ការធ្វើដំណើរនេះ ទៅច្រកនឹងទៅជាវង់មូល

ចេញដំណើរ កំណាន់ដើងនាំក្បួនរនេះចេញទៅដោយ
ដំណើរយ៉ាងស្ងាហាប់, គោមួយៗដែលនាំយកមកប្រើ
បានត្រឹសរើសយកសុទ្ធតែគោ ដែលមានពងកាយមាំ
មួន ព្រមទាំងមានលក្ខណៈជាមង្គល. នៅក្បួនរនេះខាង
មុខមានបុរសចំណាស់អាយុអង្គុយខន្ធឹមនឹងបុត្រកំឡោះ
របស់ខ្លួន ព្រមទាំងនិយាយរំលឹកជាស់តឿនណែនាំ
បណ្តើរ ដើម្បីឲ្យបុត្រជាទីស្រឡាញ់ មានសេចក្តី
ស្ងាត់ជំនាញក្នុងការធ្វើដំណើរ និងការគ្រប់គ្រងជីវភាព
ជាដើម ។

បុរសនេះ ពួកអ្នកបវរនេះទាំងឡាយស្គាល់ច្បាស់
តែក្នុងឋានៈជាសត្តពហៈ នាយឈ្មួញរនេះ អ្នកមាន
ចំណែកហ៊ុនជាមួយនឹងសេដ្ឋីជាម្ចាស់រនេះ និងទំនិញ
រផ្សេងៗ ជាអ្នកគ្រប់គ្រងសិទ្ធិជាប់ខាត ទាំងក្នុងការ
ធ្វើដំណើរនឹងការលក់ដូរ. ឥតមានអ្នកណាដឹងការប្រ-
ព្រឹត្តិមកអំពីខាងដើមថា ឧដ្ឋិយៈអ្នកខ្លួលខ្ទុសត្រូវ
ក្នុងការគ្រប់គ្រងក្បួនរនេះនេះ មានដើមកំណើតក្នុង
ដែនគាសីឬដែនណាឡើយ ដឹងត្រឹមតែថា ឧដ្ឋិយៈជា
នាយឈ្មួញរនេះដែលរក្សាពាក្យសត្យ មានមេត្តាករុ-
ណាចំពោះអ្នកតូច មានសេចក្តីឈ្លាសវាងវៃ ព្រម
ទាំងមានសេចក្តីក្លាហានបំផុត. អ្នកបវរនេះទាំងឡាយ
មានសេចក្តីគោរពុកចិត្ត ថែមទាំងដឿងាក់ក្នុងការ
ប្រាសចាកភយន្តរាយផ្សេងៗ ការបើបានធ្វើដំណើរ
ជាមួយនឹងឧដ្ឋិយ ចំពោះការឈប់សម្រាកតណ្ហាល
ផង, ចំពោះការបវរនេះធ្ងន់អួរ , ស្ងួត , ត្រង់
កន្លែងខ្លះដែលរនេះអាចធ្វើបានឧដ្ឋិយមានការឈ្លាស
វៃ ញ៉ាំងក្បួនរនេះផ្សងធ្វើកន្លែងសំខាន់ គួរមានភ័យ
ផ្សេងៗទៅបានដោយស្ងួស្តីជាជាងប ឥតមានត្រួយ
បារម្ភអ្វីឡើយ .

" មិនប៉ុន្មានថ្ងៃទៀតនឹងផុតដែនការសី ចូលទៅ
ការដែនមគធៈ សំណាក់នៅក្នុងវត្តគ្គត្រមួយយប់
ហើយព្រឹកឡើងផុតនឹងទាំងឯងចូលទៅទស្សនាក្រុងរាជ
គ្រឹះ, កាលបើបានធ្វើទៅគ្រប់ស្រុកហើយ នឹងបាន
ប្រៀបធៀបពាជនាទីនៃដែនផ្សេងៗ នឹងក្រុងពាណស
របស់យើងថា តើមានសេចក្តីថ្លៃថ្កុតាយ៉ាងណា ?"

" បតិត្រូបិតា ! កន្លងពេលថ្ងៃត្រង់នេះ យើង
នឹងអ្នកបវរនេះទៅឈប់សម្រាកត្រង់ណា ? " បុរស
កំឡោះដែលមានឈ្មោះត្រូវគ្នានឹងដែនសុរសេនៈ ពោល
សួរទៅរកបិតា ។

" ម្ចាស់ដើមស្វាយធ្លាយសន្ធឹម នៅខាងមុខ
ណោះ ជាវប្រទេសដ៏បន់នោះ គួរជាទីឈប់សម្រាក
ណាស់ " បិតាឆ្លើយ ។

លុះដល់មជ្ឈិមសម័យថ្ងៃត្រង់ជាក់ ដែលជា
វេលាភ្លៅបំផុត ក្បួនរនេះក៏មកដល់ព្រៃស្វាយល្មម ដូច
ពាក្យដែលឧដ្ឋិយៈពោលនឹងបុត្រគាលបើបានឲ្យសញ្ញា
ដល់រនេះខាងក្រោយស្រេចហើយ ឧដ្ឋិយៈបញ្ឈប់រនេះ
ក្បែរផ្លូវខាងស្តាំដៃ បង្គាប់ឲ្យបុត្រដោះគោចេញពីនឹម
ព្រមទាំងយកចន្ទល់មកទល់ជំនួសគោដែលទឹម ហើយ
ឲ្យដឹកគោទៅចងត្រង់គល់ស្វាយដ៏ធំមួយដើម បន្ទាយ

វេទ្យឲ្យវែង ល្មមដើរបរបេះបរបោចស្មៅកន្លែងដែលតាងបាន រួចផ្សែយកភាជនៈបុះទៅកាន់ស្នងគង្គា ដងទឹកមកឲ្យ គេ. ក្បួនរទេះចំងាំនោះកំឈប់សម្រាកនៅបន្តាប់ៗគ្នា មើលឃើញវែងអន្លាយទៅតាមផ្លូវ. (នៅមានត)

★ ★ ★

ប្រវត្តិក្មេងតំព្រា (ត)

ប្រអែបមតិករបស់-ធន- សារឿង

គាលដើមយើងមិនបានដឹងបញ្ជាក់អ្នកអានពីរឿងរ៉ាវខ្លះនៃសពទុកញ៉ា ធន-សម្បត្តិ

អ្នកទុកញ៉ា ធន-សម្បត្តិ ជាបុត្រនៃគ្រួសារមួយមានកំណើតជាអ្នកចំការស្មៅ ដំបូងឡើង បិតារបស់លោកបានរៀបមង្គលការ ជាមួយនឹងនារីរបស់ក្រុងមួយរូបនៅខេត្តបាត់ដំបង គូសង្វាក់នេះបានទៅអាស្រ័យជាមួយគ្នា ចំនួនជាមួយត្រីមាសប៉ុណ្ណោះ ក៏អ្នកជាស្វាមីមានការខឿយណាយក្នុងគាមគុណ ហើយក៏បង្កើលគោគសម្បត្តិ ដែលជាចំណែករបស់ខ្លួនប៉ុន្មានដល់តរៀយ ពាំងអស់ រួចក៏សូមលាតរៀយចេញចាកគេហស្ថានបួលទៅសូមក្មួសនៅវត្តពោធិវាល ។ នាងជាតរៀយក៏មិនមានហាមឃាត់ ដល់ចំណងនោះឡើយ នាងបានដួយបំពេញកិច្ច របស់ស្វាមីលុះត្រាតែបានសម្រេច ។ ពិតមែនតែនាងបានបំពេញការណីយនោះរួចស្រេចហើយ តែនាងមិនមានចំណងនឹងទួលយកបុរសណាមួយមកគ្រប់គ្រងនាងតទៅមុខទៀតឡើយ ; ព្រោះពេលដែលស្វាមីនាងចេញផុតទៅ បានផ្ញើទុកនៅវត្តវិសេសមួយផ្សែនាង គឺការកនៅក្នុងផ្ទៃចំនួនពីរខែ នាងទំរក្បាគកិនាងដោយប្រុងប្រយ័ត្នជាបំផុត ហើយថែមទាំងដាក់ធុរៈចិត្តថាឈប់ទួលយកបុរសណាមួយធ្វើជាស្វាមីដោយដាច់ខាតតទៅអនាគត ។ គំនិតនេះគឺនាងបានផ្តងមកយូរហើយ ចាប់តាំងពីនាងនៅជាតរុណីម្ល៉ះថា កូនដំរីតរបស់នាងជាតិនេះ មិនឲ្យមានរូបបុរសពីរបីលងសុខភាពរបស់នាងបានឡើយ ។ នាងមេម៉ាយទំរក្បាគក៏លុះត្រាតែគ្រប់កំណត់គាលហើយចិញ្ចឹមបីបាច់ដរាបដល់មានវ័យចំរើនឡើងគ្រប់—គ្រាន់ ដែលនាងបានដាក់ឈ្មោះថា ធន-សម្បត្តិ ។ ចំពោះធនតែដែលចូលបួសកន្លងមកហើយក៏រូបនេះមិនបាននៅរួមអាវាសជាមួយនឹងគេទេ លោកបានទំព្យាយាមចំពេញធុតង្គកិច្ច នៅគីរីស្ថានឯណោះ ការព្យាយាមរបស់លោកក៏បានដល់ថ្នាក់ទុក្រិដ្ឋ ដែលជាការៈមួយដ៏លំបាកសម្រាប់តែកូនអ្នកធុតង្គលោកបានដំរះស៊ីលរបស់លោក មិនឲ្យសៅហ្មងដោយប្រការណាមួយឡើយ ។ រាងជា ២០ ឆ្នាំផ្សាយមកហើយព្រះថេរៈអង្គនេះមិនដែលនិមន្តមកកាន់ស្រុកភូមិនឹងគេ-សោះ ដោយលោកកំពុងជាប់ជំពាក់លើការដំរះសន្តានចិត្តរបស់លោក ។

ពេលខាងក្រោយមក លោកបានធ្វើកុដិជាច្រើនហើយក៏នៅស្ងាត់ជាប់លើភ្នំមួយៈមស្រុកបរវៃលិន , ការប្រដិបត្តិរបស់ព្រះថេរៈនេះកាន់តែតឹងតែងឡើងដា

លំដាប់ , ដោយការតឹងរឹងពេកពួកវុក្ខទេវតាដែលអាស្រ័យនៅលើភ្នំនោះប៉ុន្មានបានមកពីសោធលោកជាច្រើនលើកច្រើនគ្រា ។ ទីបំផុតនៃការពិសោធន៍មានវុក្ខទេវតាមួយរូប ដែលធ្លាប់ជាប់ជាសាច់ញាតិលោកពីអតីតជាតិមក ក៏បានចូលមកថ្វាយបង្គំលោក ដោយគេទជាតាបស ទេវតាបសនេះបានយកប្រអប់តូចមួយ , ដូចយើងបានរៀបរាប់ពីមត៌ករបស់ ធន-សារឿនរួចមកហើយ , មកប្រគេនព្រះថេរៈដោយពាក្យថា នេះជារបស់ដែលលោកម្ចាស់ត្រូវតែទទួលយក ដើម្បីទុកឲ្យខ្ញុំប្រុសរបស់លោកព្រោះលោកមានព្រះជន្មគាន់តែតៅមុខណាស់ហើយ ។

សន្តានកល្យាណបុថុជ្ជននោះបើដូចម្តេចក៏ដោយ ក៏គង់មានចិត្តនឹកក្តុកដល់បុត្រសំឡាញ់នោះមិនខាន , ហើយក៏ស្រេបគ្នានឹងការប្រកែករបស់លោកមិនបានការខ្វែត ក៏គួរតែទទួលយកដើម្បីទុកជាបញ្ជីបំពោះអនុជនរបស់លោក ។ ដូច្នោះហើយបានជាវត្ថុនោះធ្លាក់មកនៅលើកណ្តាប់ដៃ អ្នកទុកញ៉ា ធន-សម្បត្តិ ដែលគាត់បានទុកឲ្យដល់បុត្រីលោក គឺនាវ ធន-សារឿនេះខ្វែត ។

ធនន្ទៈបានទំស្បាយៈមអប់រំធុតង្គកិច្ចលុះត្រាតែសុគតទាំងភ្នែននៅលើភ្នំមួយ , រវាង ៧ ពត្រីទើបអ្នកថ្មើរព្រៃម្នាក់បានដឹងហេតុទើបយកសពលោក មកធ្វើឈាបនកិច្ចតាមបវេណីព្រះពុទ្ធសាសនា ។

★ ★ ★

សំណាងបានទំសង្កត់ចិត្ត ដើម្បីជាការអប់រំមួយគ្រា កុំឲ្យចិត្តអ្នកឆ្លៀវឆ្លាតកាមគុណទាំងពេក ។

ការចិញ្ចឹមជីវិតនៃសំណាងលើកនេះមានសភាពផ្ទួយពីកាលមុន គឺពាល់ពេលអ្នកតែងរកបេះផ្លែឈើដែលមានជ្រុងរសជាប់ចិញ្ចឹមជីវិតរបស់អ្នក ។ គេះបើដូចម្តេចក៏ដោយ ការចិញ្ចឹមជីវិតដោយផ្លែឈើ គង់មិនអាចញ៉ាំងជីវិតរបស់អ្នកឲ្យរស់នៅបានស្រួលដែរ — ព្រោះថាជនដែលធ្លាប់តែចិញ្ចឹមជីវិត ដោយអាហារហើយលះបង់យកជាតិបន្ទែមកជំនួសវិញ ក៏ជាកិច្ចមួយដែលនាំឲ្យលំបាកក្នុងជីវិត , តែយើងដឿបានថា ការចិញ្ចឹមជីវិតដោយបន្ទែ ក៏គង់មានផលជាងការចិញ្ចឹមជីវិតដោយអាហារ ដោយហេតុថាការចិញ្ចឹមជីវិតបែបសំណាង ក្នុងពេលនេះអាចចៀសវាងទុបសគ្គច្រើនយ៉ាង !

១- មិនសូវមានរោគបៀតបៀនកាយ

២- ចៀសផុតការគ្រុនចាញ់គ្រប់បែប

៣- មានថាមភាពបរិបូណ៌

៤- មានអាយុវែង

៥- មានពណ៌សម្បុរកាយល្អ

រាល់ព្រឹកអ្នកតែងដើរស្វែងរកផ្លែឈើណាដែលមានរសជាតិល្អស្ទើរតែគ្រប់កន្លែង លុះត្រាតែពេលល្ងាចទើបត្រឡប់មករកទីសំណាក់វិញ ។ អ្នករស់នៅបែបនេះ កន្លងពេលជាជាង ១ ខែមកហើយសព្វថ្ងៃសុខ

តទៅទំព័រ ២២

ពិភពពេលភ័ន្តរន្ទាជាន

ស្រីរស្មីចូរ

ស្រីរៀង

THE LASH WORLD

(BY) រៀបរៀងដោយ

SIR ARTHUR TONAN DOYLE

ប្រែនិងរៀបរៀងជាភាសាខ្មែរដោយ

TRANSLATE AND COMPOSE IN CAMBODIAN.

បញ្ចាំចិត្ត ទឹង សុរិន្ទ

BUNCHONGCHUITR BY SURINN

ន ១

ខ្ញុំបែរជាស្វែងរក

I SEEK ADVENTURE

Mr. Hungerton Gladys's father, was a selfishuntidy kind of man, and I believ he thought I came round to his house three days a week just to see him. I had to listen to his uninteresting conversation not of politeness,but luckily one night when I went there he had to go out to a meeting, and at lsta I found myself alone with Gladys. The moment of my fate had come; for I had decided to askLer to marry me. I felt like the soldier who awaits the signal that will send him tofinal victory or final defeat.

Gladys had been a friend of mine for a long time, but I wanted her to be more than a mere friend. Thorgh some people thought she was rather cold and hard, in my eyes she had every womanly quality. She was all that I could wish for in a woman. I was thinking these thoughts, and was about to break the cilence that

លោកហ៊ីងតឺរថាន់ បិតារបស់ ក្លែតឌិស ជាមនុស្សដែលរឃីញតែប្រយោជន៍ខ្លួនទឹងចិត្តរហ័ស ហើយខ្ញុំដឹងថា គេគិតថាខ្ញុំមកផ្ទះគេ ៣ថ្ងៃក្នុងអាទិត្យ ដើម្បីមកលេងទឹងគេ ។ ខ្ញុំត្រូវអង្គុយស្តាប់ការសន្ទនាដែលគ្មានរសរបស់គេ ដើម្បីជាការរក្សាមារយាទ តែជាគខ្ញុំល្អ គឺក្នុងយប់ថ្ងៃមួយកាលដែលខ្ញុំទៅទីនោះគេបានចេញទៅប្រជុំគ្នាខាងក្រៅហើយក្នុងទីបំផុត ខ្ញុំក៏បាននៅជាមួយក្លែតឌិសតែពីរនាក់ រៀលសំខាន់របស់ខ្ញុំមកដល់ហើយ ព្រោះខ្ញុំជាប់ចិត្តសុំអង្វរផ្សាងរៀបមង្គលការជាមួយនឹងខ្ញុំ ។ ខ្ញុំមានមនោសញ្ចេតនាដូចជាគ ហានដែលរង់ចាំអាណត្តិសញ្ញាណ ដែលនឹងបញ្ជូនទៅផ្សះផ្សាម្រេចនូវជ័យជំនះឬ បរាជ័យក្នុងគ្រាទីបំផុត .

ក្លែតឌិសជាមិត្តរបស់ខ្ញុំមកយូរហើយ តែខ្ញុំត្រូវការផ្សាង

had fallen in the room, when she looked at me and shook her head "I believe that are going to ask me to marry you, Ned," she said "I do wish you wouldn't.It'smuch nicer for us to remain jut friends."

"Now how did you know what I was going to do?" said I, astonished.

"Don't women always know?" she said"But, Ned, our. friendship had always been good and pleasant. It would be a pity to spoil it."

"But why can you not love me, Gladys?Is it my appearance or what?"

"No, it isn't that," she replied. "But the man I want to marry is a man who would look death in the face and have no fear of it—a man of great deeds and strange adventures. Think of all the famous men of history who have done great things and whose names are remembered by all the world. It is menlike those that a woman could love and reapec"

ប៉ានប្រសើរជាងគេ សូម្បីជាមនុស្សខ្វះគិតថា នាងមានដំណើរទំនងមិនទន់ភ្លន់ហើយរឹងប៉ឹងតែសម្រាប់ក្រសែភ្នែកខ្ញុំ នាងមានលក្ខណៈរបស់កុលស្ត្រីគ្រប់ប្រការ ។ នាងមានលក្ខណៈគ្រប់ៗយ៉ាងដែលខ្ញុំត្រូវការក្នុងរូបស្ត្រី ។ ខ្ញុំកំពុងអង្គុយប្រឹគំនិតនេះហើយរៀបទឹងនិយាយចេញទៅ ដើម្បីទម្លាយខ្លួនសម្ងាត់ដែលគេតែងក្នុងបន្ទប់នោះ តិចួនជានាងសម្លឹងមើលមុខហើយត្រវីក្បាលរបស់នាង "ខ្ញុំដឹងថាលោកកំពុងតែនឹងសូមអង្វរឲ្យខ្ញុំរៀបការជាមួយនឹងលោក-ណាត" នាងនិយាយទៀង "ខ្ញុំមិនចង់ឮលោកធ្វើដូច្នោះ សូមឲ្យយើងសេពគប់គ្នាជាមិត្រយ៉ាងដូច្នេះទៀតជាជាង"

ខ្ញុំឆ្ងើយដោយការចម្ងៃកក្នុងចិត្តថា "យ៉ៈ! ម៉េចក៏អ្នកដឹងថា ខ្ញុំកំពុងធ្វើអ្វី"

នាងនិយាយថា "ស្ត្រីណាមិនដឹងអ្វីជាអ្វីទៅតាំងអស់ប្ល តែណាតមិត្តភាពរបស់យើង ក៏ប៉ានធ្វើដំណើរការមកដោយសុខស្រួលនឹងរៀបរយល្អ ខ្ញុំនៅស្ងាយណាស់ ម៉ើនឹងខ្លាយរាំចេញនោះ"

"តែហេតុយ៉ាងម៉េចបានជាអ្នកមិនស្រឡាញ់ខ្ញុំតែគ្មានទិសត្រោះរូបរាងរបស់ខ្ញុំប្លអ្វី" នាងឆ្ងើយថា "ទេមិនមែនដូច្នោះទេ តែបុរសដែលខ្ញុំនឹងរៀបអាពាហ៍ពិពាហ៍ជាមួយនោះ ត្រូវជាប្រុសដែលហ៊ានតស៊ូនឹងសេចក្តីស្លាប់ហើយមិនខ្លាចស្លាប់" ត្រូវជាប្រុសដែលធ្វើការធំៗ ហើយផ្សងព្រេងផ្សងៗ មកច្រើន លក់តែមើលដល់បណ្តាបុគ្គលដែលមានកេរ្តិ៍ឈ្មោះខាងឡាយក្នុងប្រវត្តិសាស្ត្រដែលបានប្រតិបត្តិការដ៏ធំមកហើយ ។ កេរ្តិ៍ឈ្មោះរបស់លោកទាំងនេះ ក៏នៅតដ៏រាល់មានគេចាំឈ្មោះទូទៅក្នុងលោក មនុស្សដូច្នោះឯងដែលស្រី ។ ស្រឡាញ់នឹងគោរព

(នៅមានត)

បញ្ហាអក្សរសាស្ត្រ (តបប់)

ព្រោះនៅសាលារៀនសព្វថ្ងៃ កុំចាំបាច់និយាយដល់វិទ្យាល័យ ឬមហាវិទ្យាល័យធ្វើអ្វី សូម្បីតែគ្រឹស្ថានបឋមសិក្សាជាតិ ក៏គង់តែរៀនភាសាបរទេសច្រើនជាងភាសាខ្មែរវែរៗ ចំពោះប្អូនមួយមិនមែនធ្លាប្រាន់ទឹងការប្រើអក្សរបរទេសជាផ្លូវការអីជាមួយនឹងអក្សរសាស្ត្រជាតិនោះប៉ុន្មានទេខ្ញុំតែតែចូលចិត្តនៅខ្មែត ព្រោះជាការងាយដល់ខ្ញុំ, តែខ្ញុំដូចជាអាណិតជនរួមជាតិខ្លះដែលបានទទួលលិទិត សេចក្តីជូនដំណឹង... ជាអក្សរបរទេសអំពីគ្រឹស្ថានរាជការនិងគ្រឹស្ថានជំនួញពាំងឡាយ ជនរួមជាតិពាំងនោះតែងតែគាន់ក្រដាសដើរស្នូរគេឯងក្នុង ៩០ ភាគរយទៅហើយ ។

ទេ! ខ្មែរយើងនឹងបានឯកពជ្ឈថ្មី ។ តាងនាមសម្តេចឧបយុវរាជគាលទ្រង់តង់ក្នុងពជសម្បត្តិ ចុះម្តេចក៏នៅមានមនុស្សជំពូកខ្លះ ចង់ទុកឲ្យអក្សរសាស្ត្រជាតិធ្លាក់ក្នុងក្រញាំនៃអក្សរសាស្ត្របរទេស ?.....

ការចាត់ចែងផ្លូវទូត គេមិនបានហាមឃាត់ទេ, ការរៀនភាសាបរទេសក៏គេមិនឃាត់ឃាំងដែរ យុវជនខ្មែរមួយរូបៗ ត្រូវតែចេះភាសាប្រើនទើបឲ្យឈ្មោះថាជាមនុស្សរស់នៅក្នុងសង្គមនៃប្រទេសឯកពជ្ឈ។ ការសិក្សាក្នុងគ្រឹស្ថានសិក្សាមួយ ។ ត្រូវតែឲ្យមានអក្សរសាស្ត្របរទេសច្រើនជាងជាងជាប់ខាត គោះលើកែ្លបៃបថណាក៏ដោយ, អក្សរប្តូរសាណា ដែលមានប្រយោជន៍សំខាន់ជាងគេក្នុងលោក នោះគួរយើងយកមកបង្រៀនទុកជាភាសាទី ២ នឹងភាសាដទៃទៀតជាបន្ទាប់ហូរហែទៅ តែមិនមែនឲ្យភាសាបរទេសមកបញ្ចេញពន្លឺដើរគួរលើផ្ទៃនៃកម្ពុជៈក្នុងពេលដែលផ្តុតកំណាត់ពេលមួយថ្នាំនោះទេ ។

តាមសេចក្តី នៃអ្នកនិពនមាតុភូមិបានពោលជាក់កំហុសយ៉ាងខ្លាំងមួនលើការប្រើភាសាជាតិតាមផ្លូវការ ជាហេតុនាំឲ្យខូចប្រយោជន៍របស់ប្រទេស..... ក្រែងលោខូចប្រយោជន៍អ្នកចេះភាសាបាំងឬ ? លោក ! ឬក៏ខ្លាចជនបរទេស នៅប្រទេសខ្មែរគេចេះភាសានឹងអក្សរសាស្ត្រយើង ?

ការចំរើនដោយអាស្រ័យប្រើអក្សរបរទេសនោះអ្វី ខ្លះទៅលោក ?

ការវិនាសព្រោះតែប្រើអក្សរសាស្ត្រនោះដូចម្តេច ? យោបល់នេះខ្ញុំសូមជនរួមជាតិវិនិច្ឆ័យមើល ។ រឿងធម្មន្តញ្ញាមាត្រាពីរត្រូវទុកតាមសមាជពាប់ម៉ឺននាក់បានអនុម័តហើយ ។

ការសិក្សារបស់ជាតិត្រូវតែបន្ថយការសិក្សាភាសានឹងអក្សរបរទេស ឲ្យបានធាប់ចាប់តាំងពីពេលនេះទៅ ហើយត្រូវបង្កើតគណៈកម្មការ សម្រាប់ប្រែកម្មវិធីបង្រៀនជាភាសាជាតិចាប់តាំងពីគ្រឹស្ថានបឋមសិក្សា... រហូតដល់មហាវិទ្យាល័យជាទីបំផុត ការធ្វើបានប៉ុន្មានត្រូវអនុវត្តតាមក្បាម ។ ។

ភាសាទិកទិក ដែលខាត់ខ្លឹនឹងក្រស្នូងដូចខ្មែ

ទៀត ត្រូវគណៈកម្មការរៀបចំធ្វើបង្អែនពេលឲ្យបាន
ច្រើនជាងនេះទៅទៀត

ចាប់តាំងពីនេះទៅសេចក្តីត្រៀមនៃព្រះរាជក្រម,ព្រះ-
រាជក្រឹត្យ,ប្រកាស ត្រូវធ្វើជាអក្សរសាស្ត្រជាតិតែម្តងទៅ
កុំចាំបាច់ធ្វើជាបាវពីរ ហើយបកប្រែមកជាខ្មែរវិញនោះ
នេះជាហេតុនាំឲ្យខាតពេលតតំអើ ហើយខូចពេលអ្នក
បកប្រែ។ ដែលត្រូវប្រែអត្ថបទឬប្បាប់សំខាន់អ្វី
ផ្សេង ។ ដែលមានបួចមកហើយ

តាសាបរទេសត្រូវរៀនទុកសម្រាប់បំពេញវិជ្ជា
ខាងបរទេសបានហើយ ៖ដូចម្តេចមិញមាត្រា ២ សម្រេច
នៅថ្ងៃ ២៨ កញ្ញាឆ្នាំ ១៩៤៥ ដោយមតិភាគ្រស្តី
ស្មុគ្គ ... ។

បណ្ណាធិការ

★ ★ ★

ឆ្ពោះទៅរកសេចក្តីសុខស្រួល
ជាសាធារណ៍ (តបប់)

ប្រើចំពោះខ្លួនឯងលែងត្រឹម ទៅទុកគ្រែកាចាំបាច់ដែល
អ្នកគ្រឿមក្រែត្រូវការយកមកប្រើជាប្រយោជន៍ ។ គេ
តែងយកទំនៀមសព្វគ្រប់មកពោលរំសាយសេចក្តី
ទុក្ខព្រួយថា យើងមិនត្រូវគិតទេ "កណ្តៀវពួនត្រង់
ណា ក៏ពួនតែត្រង់នោះ"។ យើងជាមនុស្ស គួរយក
ទំនៀមល្អងខ្លៅនេះមកប្រតិបត្តិឬ? ការគ័ន្តច្រឡំនេះមក
ពីសេចក្តីស្មានខុសនឹងមកពីសេចក្តីស្រវឹង គេយកការ
ក្រឿមក្រំនឹងការសុខស្រួលដ៏លើសទៅផ្ទាប់ក្លាប់យ៉ាង
ស្អិតជាមួយនឹងថាន:ឬជាតិផ្សងៗនៃជនពាលឲ្យាយ ។
ដោយអាស្រ័យហេតុនេះ ទើបមានសេចក្តីផ្សងគ្នា
មេយៗទឹងដ៏រាងមនុស្សនាទាក្នុងសង្គម ចំណែកប៉ើធ្វើ
ការអ្វីធំពាំងពួនគេតែងនិយមយកទំនៀមលូតលាស-
មច្ឆរមកជាប្រមាណ ដូចជាការសិក្សាក្នុងសាលារៀន
នឹងការកន្ទើតផលិតផលជាអាទិ ។ ចុះត្រង់សេចក្តី
សុខស្រួលនៃមនុស្សក្នុងសង្គម ប្រការម្តេចក៏គេមិន
និយមយកលូតលាសមច្ឆរ មកជាប្រមាណផង? គេ
ត្រូវប់ជាបណ្តាយឲ្យជនគាគប្រើនក្នុងសង្គម ភ្ញាយ
ទៅជាវត្ថុជាតុក្រៃ ទៅជាវត្ថុជាតុមិនគួរដល់ការ ហើយ
ក្នុងថ្ងៃណាមួយ ពួកនេះខ្លះនឹងទៅជាប្រកពនៃអសន្តិ
សុខដែលលោកយរមែងស្អប់ខ្ពើម ប៉ុន្តែលោកយនៅ
តែមិនគិតរកមធ្យោបាយដើម្បីកំចាត់គ្រឿងសំអុយនេះ។
ព្រះសម្ពុទ្ធទ្រង់សំដែងថា: "មានជនគាគច្រើនទាំងគ្នា
ស្រែកប្រាប់គេថា: ខ្លួនភ្លៀណាស់ ប៉ុន្តែជនពួកនេះ
មិនព្រមសុខចិត្តទម្លាក់ខោលនូវគប់ភ្លើងដែលកំពុងឆេះ
ឱលពាលលើអាត្មាឡើយ" ។

ប្រការម្តេច ចានជាពួកជនក្រៃនេះនឹងទៅជា
មេបង្កនូវអសន្តិសុខ ដោយពេលដោយខណៈ? រឿង
នេះបណ្តាលមកពីសេចក្តីត្រូវការតែម្យ៉ាង ។ ដូច
មនុស្សម្នាក់ស៊ីអម្ពិលក្បែរជនដទៃម្នាក់ តើអ្នកនេះនឹង
លេបទឹកមាត់តាមឬទេ? ការចេញទឹកមាត់ហើយលេប
តាមដោយឥតអម្ពិលស៊ីនេះហើយដែលនាំឲ្យមានសេច

ភ្ជាប់ក្រៀមក្រំនឹងអសន្តិសុខ ។

គឺការសុខស្រួលហួសក្រមច់ណ្ដាំនៃជនពួកខ្លះក្នុងសង្គមនេះហើយដែលជាមេដើមចមនៃសេចក្តីក្រៀមក្រំនៃជីវភាពគ្រប់គ្រង ចំពោះគាលអសន្តិសុខក្នុងវដ្តផ្សេងៗ ដែលលោកយើងបានបង្ហូចប្រុះ មិនសូវដែលជាប់ កុងលំជាប់គាលវេលា ។

ព្រះភាគឫម្ចាស់ចរមសម្ពុទ្ធ ដោយទ្រង់ជ្រាបច្បាស់នូវហេតុជាទីកើតនៃសេចក្តីសុខនឹងជាទីកើតនៃសេចក្តីទុក្ខរបស់សត្វកុងលោកដូច្នេះ ទើបទ្រង់ទេសនាប្រដៅពួកពុទ្ធបរិស័ទ ឲ្យប្រព្រឹត្តនូវអប្បិច្ឆតាធម៌ (សេចក្តីប្រាថ្នាត្រឹមតែការចាំបាច់) ព្រមទាំងបញ្ជាតួដល់ពុទ្ធបរិស័ទផ្ទាល់ឲ្យប្រើតែចីពរបីវៀងគ្រប់រូបគោះបីអង្គណាមានឋានៈខ្ពស់ទាបយ៉ាងដូចម្តេចក៏ដោយ ជាចៅអធិការក្តីជាពហូសូត្រក្តីជាពាជាគណៈក្តី (ល) ។

ដូច្នេះកុងសង្គមព្រះពុទ្ធសាសនា សេចក្តីសុខស្រួលជាសាធារណ៍រវាងពុទ្ធបរិស័ទ តែងប្រព្រឹត្តទៅជាហូរហែតមានអាក់ រឿរលែងតែមានពួកអលជ្ជីមកប្រឡែតជ្រែកបន្ទុំឬចិញ្ចឹមដំរីតែដោយសារ ។

បើតាមសេចក្តីនេះគួរតែលោកយើងកុងសង្គមផ្សេងៗយកតម្រាប់តាមរបៀបសង្គមព្រះពុទ្ធសាសនា ទើបភាវនិរាសចាកអសន្តិសុខ ទើបសេចក្តីសុខស្រួលជាសាធារណ៍ប្រាសចាកភ្យាបាទ កើតមានទៅនឹងពួកទៅៗ

(ផេង-ស្រីរ ២០-៤-៥៥)

★ ★ ★

ហេតុដូចម្តេចបានជាខ្ញុំត្រឡប់ទៅជាសាវិកានៃព្រះពុទ្ធសាសនា(តបប)

សិទ្ធិដូចប្រុះនឹងពួកជ្ញានិន (Jnànin) បរិសុទ្ធស្អាត (នាងខ្ញុំមិនមែនថាគ្មានសោះនោះទេ) ។ នាងខ្ញុំបានឃើញសេចក្តីប្រែថាអ័តវ៉ែត = អ៊ែទន្ទ: (Advaita vedanta) ទៅតាមរស្មីនៃកំមយោគ (Kamayoga) តក្តិយោគ (Bhaktiyoga) ព្រមទាំងចិន្តាំនើប ដែលមានសភាពជួយ នឹងប្រពៃណីដែលអាចរចនាព្រហ្មញ្ញសាសនា នឹងពុទ្ធសាសនាឲ្យមានសភាពមិនច្បាស់លាស់ ។ តួមតិខាងក្នុងរបស់ខ្ញុំ មានបំណងទៅតាន់តារំលត់នៃសំខារ (ដែលធ្វើឲ្យមនុស្សលោកអន្ទាលទៅមកកើតស្លាប់ៗកើតកុងភព) ដោយពិចារណាបំបែកព្រមទាំងវិសគន់នូវសកម្មភាពរបស់នាងខ្ញុំ ។ ចំណែកខាងធម៌ "តក្តិ" (Bhakti) នាងខ្ញុំមិនយើញអ្វីស្មើនឹងគ្រីស្តសាសនា ដែលនាងខ្ញុំបោះបង់ចោលទៅហើយៗអវិសាន (notion de Brekmen កុងដែនបរមត្ថវិជ្ជា, សញ្ញាណព្រហ្មណ៍, អត្តន, (Atman) ឥស្សារ (Isvara), មាយា (Maya), សត្ត-ចិត្ត (Sat-chit), បើខ្លួនជាមានសភាពខ្សត់គ្មាយ៉ាងណាចំពោះលទ្ធិក្រែក-គ្រិស្តសាសនាត្រង់សព្ទថា: ជីវសត្ត (Etre) ព្រះស្រឡាំង (amé), ព្រះអាទិទេព (Dieu), កម្ម (Péché), បុព្វហេតុ (Essence), លោក (Logos), នាងខ្ញុំអាចយល់ជាក់ច្បាស់បានថាជាផ្នែកខាងគំនូសដែលបើកឲ្យនាងខ្ញុំយើញពិតប្រាកដថា ជាសព្ទសម្រាប់ពន្យល់សភាព

នៃទន្ទរបស់សត្វ តែមានសភាពជួយជាយ៉ាងជាក់ស្តែង
ទឹងអនត្តៈសុញ្ញត (Anatma sunyâta) នៃ
ព្រះពុទ្ធសាសនា ។ ចោះបង់ចោលការប្រាស្រ័យចំពោះ
ឯកភាពនៃអាទិទេព ដែលជាលក្ខណៈនៃលទ្ធិខាងគ្រីស្ត
សាសនា ដើម្បីនឹងពិចារណាសត្វ , បុគ្គលដែល
មានសភាពមិនច្បាស់លាស់ ហើយឯងឹតជាងព្រះ
វិត្រលក្ខណ៍ទៅទៀត មិនអាចនឹងបញ្ជាក់ឲ្យច្បាស់
ក្នុងចិត្តបាន ។ នាងខ្ញុំលះបង់ព្រះគ្រីស្ត ចំពោះ
តែការដែលនាងខ្ញុំយល់មិនច្បាស់លាស់ចំពោះសព្វថា
សត្វ, បុព្វហេតុ, ជីវិត (Etre-Essence-Vie) ។

ការប្រាស្រ័យជាយ៉ាងជ្រាលជ្រៅ ចំពោះពុទ្ធសាស-
នាប្រវត្តិ , ព្រមទាំងកិច្ចដែលគេអនុញ្ញាតឲ្យពួកសៀក
សិក្សារៀនសូត្រខាងព្រះពុទ្ធសាសនានៅប្រទេសចិ-
នេត៍ អាចរាចនានាងខ្ញុំឲ្យទៅជាសាវិកាមួយមានចំណង
ចង់យល់ជាក់ច្បាស់ ហើយនឹងរស់នៅតាមលទ្ធិនាគ-
ជុន (Nàgàrjuna) ។ ការដែលខ្ញុំលស្គាល់នូវលទ្ធិ
ក្នុងព្រះពុទ្ធសាសនាណាមួយ , មិនអាចធ្វើឲ្យពុទ្ធមា-
មកជនទៅជាពួកអធិមុត្ត (អ្នកប្រកាន់សាសនាហួស
ហេតុដោយហេវាយ៉ៅ) ទេ ។ ព្រះពុទ្ធសាសនាគឺជា
សាសនាមួយដែលបុគ្គលអាចជ្រើសរើសនូវតុល្យភាព
យកមកប្រតិបត្តិតាម ហើយលទ្ធិមធ្យាមិក:(Mathya-
mika) មានឫសចាក់ចូលទៅជ្រៅក្នុងគាថា :

" សព្វេ ធម្មា អនត្តា

" សព្វេ ធម្មា អនិច្ចា

" សព្វេ ធម្មា ទុក្ខា

បើតាមវិចារណញ្ញាណ , គាថាទីមួយជាជាង
វចនាព្រះពុទ្ធសាសនាឲ្យកើតឲ្យមានៈឡើងហើយ ជាន
វចនានានឹងទៅជាសាវិកាមួយនៃព្រះបរមគ្រូជាម្ចាស់ ។

★ ★ ★

គួរស្គាល់កញ្ញាកម្ពុជា

ប្រទេសកម្ពុជាបានយើញច្បាស់ដោយមំសចក្ខុ
អំពីការរើសកញ្ញាឯកប្រទេសកម្ពុជាហើយ ។ យើង
ត្រូវដឹងថាបុរសកំដោយស្រីកំដោយ សុទ្ធតែមានរូប
សម្បត្តិប្រកបដោយលំអធម្មជាតិផ្សេង ។ គ្នាលំអ
នេះមិនមែន កើតឡើងដោយការស្ងួតស្អាងប្តូរលាបលន
នោះទេ ។ បើតាមពិត ដែលទ្រាប់ដឹងតាមលំអ
ព្រះពុទ្ធសាសនាមក លំអធម្មជាតិដែលកើតឡើង
ដោយធម្មជាតិសម្រាប់រូបម្នាក់ៗ ក៏អាស្រ័យការកសាង
ផ្តាល់ខ្លួនពីអតីតជាតិមក ហើយការកសាងនេះលុះណា
តែស្របទៅតាមលំអព្រះពុទ្ធសាសនាផង ។

កញ្ញាសោភាពាំងឡាយ សូមកុំអាលច្រឡំចំ
ពោះរូបសម្បត្តិរបស់ខ្លួន កើតឡើងដោយការដុះលាង
នឹងលាបលន ហើយកញ្ញាដែលមិនត្រប់ត្រាន់
ដោយរូបសម្បត្តិក៏កុំអាលខាមនស្ស ហើយយល់ថា
ខ្លះការនឹងតុបតែងដោយត្រប់ត្រាន់ ។

បើតាមពិតលំអដែលគេត្រូវរើសឲ្យសមទៅ
តាមវ័សនានៃការកសាងរបស់នារីមួយរូប ។ នោះ គឺ

លំអធម្មជាតិ ។ បើពោលតាមសភាពនេះ សមាជិកនៃអ្នកបើសនាវ៉ែងតត្រូវតែចេះដោយពិតប្រាកដ ចំពោះលក្ខណៈនៃលំអនេះ បើយើងពុំធ្លាប់ដឹងឬចេះនូវលក្ខណៈនៃលំអធម្មជាតិទេ យើងអើសបានតែនាវ៉ែងណាដែលមានលំអដោយការតុបតែងប៉ុណ្ណោះ ។

គ្រប់បរិវេណនៃការបើសតញ្ញាឯកតាមសង្កាត់នៅភ្នំពេញខ្ញុំបានទៅពិនិត្យស្ទើរគ្រប់កន្លែង តែបានដឹងច្បាស់ការបើសនេះ មិនឲ្យសគ្នាពីការយើញលំអតាមផ្លូវចិត្តនឹងគ្រឿងតុបតែងប៉ុណ្ណោះ ខ្ញុំក៏មិនអាចបដិសេធនូវការបើសបែបនេះបានដែរ ព្រោះខ្ញុំមិនមែនជាសមាជិកក្នុងការជ្រើសបើសនេះ ហើយថែមទាំងពុំមានសមត្ថភាពគួរធ្វើជាសមាជិកនោះបានផង ដោយហេតុថា ខ្ញុំមិនដែលបានប្រទះនាវ៉ែមានលំអធម្មជាតិគ្រប់ទៅតាមលក្ខណៈនៃច្បាប់ព្រះពុទ្ធសាសនាហើយខ្ញុំមិនធ្លាប់ស្គាល់លំអនាវ៉ែតាមច្បាប់លោកសាកលផង ។

សូមមិត្តអ្នកអានកុំអាលយល់ថា អត្ថបទនេះសរសេរដើម្បីជំទាស់ការដែលគេធ្វើរួចមកហើយ ខ្ញុំសរសេរចង់យល់ថា តើការបើសលំអនេះទៅតាមរបៀបណា? មិត្តគង់ឆ្លើយខ្លួនឯងក៏បាននៅពេលដែលមិត្តបានទៅឃើញការបើសផ្តាច់ព្រាត់នៅថ្ងៃទី ២៤-២៥-២៦ វិច្ឆិកាខាងមុខនេះនៅកន្លែងបរិវេណពិពណ៌អន្តរជាតិមិនខាន ។

ចំពោះបញ្ហាដែលគេលើកមកសួរដល់នាវ៉ែអ្នកប្រឡងប្រដែងសោត ក៏ជាបញ្ហាធម្មតាប៉ុណ្ណោះ ហើយនឹងមានបញ្ហាខ្លះក៏មិនគួរសមយកមកសួរក្នុងពិធីនោះផង នេះបើតាមយោបល់របស់ខ្ញុំ តែទោះបីដូចម្តេចក៏ដោយ នាវ៉ែទាំងឡាយនោះនៅតែមិនរួញរាចំពោះបញ្ហានោះទេ ស៊ូតែធ្វើយតាមការឈ្វាសវៃរបស់ខ្លួន ។

ខ្ញុំសូមសរសើរដល់ការអង់អាចនៃនាវ៉ែទាំងឡាយ ដែលស្ម័គ្រចិត្តចូលទៅប្រណាំងប្រដែងដើម្បីសំដែងការឆើតឆាយរបស់ខ្លួនទំាងចំពោះសមាជិកអ្នកជ្រើសបើសដែលមានវិរិយៈមិនលះបង់ ប្រឹងលុះត្រាតែអាចរកនាវ៉ែឯកសម្រាប់មាតុប្រទេសជាលើកដំបូងនេះ ។

សូមមិត្តជួយពិនិត្យមើលផ្សព្វផ្សាយចំពោះលំអនាវ៉ែដែលខ្ញុំទំាងយកមកផ្សាយជូនទៅលេខក្រោយ ខ្ញុំយល់ថានាវ៉ែទាំងនេះ មានសមមូ្យភាពល្មមប្រឡងប្រដែងបានដោយពិតមែន ។ ។

ដល់ថ្ងៃប្រឡងផ្តាច់ព្រាត់បើសតញ្ញាឯកកម្ពុជាទំាងដូនលក្ខណៈថាលំអធម្មជាតិផ្សេមិត្តវិនិច្ឆយ នៅទំព័រទស្សនាវដ្តីយើងលេខ ១១ ដែលត្រូវចេញជាបន្ទាប់គ្នានេះ ។

ហា. ហា.

× × ×

ប្រវត្តិក្មេងកំព្រា (ត)

ភាពរបស់អ្នកបានប្រពឹត្តទៅស្រួលបួលហើយ តែអ្នកនៅមានចារម្ភបន្តិច គឺការខ្វះខាតសំលៀកបំពាក់ នេះជាបញ្ហាមួយដែលមិនអាចដោះស្រាយបានតែឯកឯង ។

ថ្ងៃនេះអ្នកដើរវេកផ្ទះឈឺ ខុសពីធម្មតា គឺថាពីមុនអ្នកស្ទើរវេកតែនៅពីដាច ប៉ុន្តែកន្លែងទំាងឡាយ ដែលអ្នកធ្លាប់វេកបាន ក៏ថែរជាគ្មានសោះ

បណ្តាលឲ្យដំណើរបស់អ្នកគាន់តែធ្វាយទៅ ។ ក្នុង
វៃ្រដែលអ្នកមិនធ្លាប់ជួបប្រទះ ។

នៅតែ្បរជ្រោះដែលមានរុក្ខជាតិលូតលាស់បំព្រង
សារធ្យូរយើញថា នឹងមានផ្លែឈើ គួរជាទីគាប់
ចិត្ត អ្នកបានដើរចុះទៅកាន់ជ្រោះនោះ ហើយឡើង
លើដើមមាក់ប្រេងមួយដើម ដែលមានផ្លែកំពុងតែទុំ
តាសពេញ ។

អ្នកកំពុងតែបេះបរិភោគ នឹងឮប៉ប៉ុះយកទៅទី
ដម្រំរបស់ខ្លួន ។ អ្នកពុំមានចេតនានឹកក្នុកដល់ហេតុ
ដែលប្រឹងនឹងមានដល់អ្នកឡើយ , ចិត្តអ្នកកំពុងតែ
សប្បាយរីករាយនឹងធម្មជាតិគាំងឡាយ អារម្មណ៍អ្នក
កំពុងតែបណ្តែតទៅតាសពេញលើអាកាសវេហាស៍អ្នក
សប្បាយរីករាយ ហើយភ្លេចខ្លួន ។

ក្រោយនេះបន្តិចអ្នកបានចោលភ្នែកសំឡឹងមក
ខាងក្រោមស្រាប់តែប្រទះឃើញសត្វថាន់មួយយ៉ាងធំ ដែល
កំពុងតែវាឡើងសន្សឹមៗទៅរកអ្នក , សំឡេងយ៉ាងខ្លាំង
" អួយយ៉ួយជួយផង " បានផ្ទុះចេញពីមាត់អ្នក
ដោយមិនដឹងខ្លួន ព្រោះជាការភ័យហួសហេតុ ។
ឃើញសត្វថាន់មិនបានអើពើនឹងសម្លេងនោះទេ វាចេះតែ
វាឡើងបន្តិចម្តងៗ ជិតដល់ខ្លួនអ្នកហើយ , ពុំដឹងជា
រកឧបាយណាមួយនឹងដោះខ្លួនឡើយ នឹងលោតផ្លោះ
ទៅដើមឈើដទៃទៀត ដើមឈើទាំងឡាយក៏ជុះឃ្លាត
ឆ្ងាយពីគ្នា ។ អ្នកមានអារម្មណ៍តែមួយគឺការប្តូង
ស្តែងដល់ព្រះវត្តន៍ត្រ័យ, នេះហើយជាការខ្លីពីងបំណុល
ចិត្តរបស់អ្នក ។

(នៅមានត)

×

×　×



ជីវិតអភ័ព្វ (ត)

ឯអ្នកដែលដើរផ្លូវមកជាមួយគ្នានោះ ស្ទាក
ឮពាក្យសុខទុក្ខស្អាតៗស្រស់បស់ក៏ពិតមែន តែក៏មិនអាច
រាយតម្លៃឮពាក្យផ្តែផ្តល់ជាងបុរសនោះបានឡើយ ហើយ
សំដីនិយាយគ្រប់ម៉ាត់ក៏សំដែងអាការគោរពចំពោះបុរស
នោះយ៉ាងខ្លាំង ។

"អ្នកណាដេកនុ៎ះ ?" បុរសនោះស្រែកសួរនៅ
ពេលដែលដើរកាត់តែ្បរសាលានោះ

"ប្រហែលជាអ្នកសូមទានទេមើលទៅ ព្រះតេជ-
គុណ !" សម្លេងបុរសម្នាក់ឆ្លើយទៅ

"ហ្ន៎ ! មានក្មេងម្នាក់ដេកនៅជាមួយផង ចូល
ទៅមើលសិនមើល" បុរសនោះនិយាយតទៅទៀត

"ព្រះតេជ-គុណមិនគួរនឹងចូលទៅទេ ព្រោះសាលាធានេះស្មុកស្រែគ្រាតណាស់ មិនសមគួរដល់កិត្តិយសព្រះតេជ-គុណជាមេទ័ពនៃទេវតិរ៉ែនតរឡើយ" ជាសម្លេងរំពឹករបស់បុរសម្នាក់ទៀត

ទូសយុទ្ធ មេទ័ពដែលមានឈ្មោះល្បីល្បាញលាន់ឮដូចផ្គរលាន់នៃទេវតិរ៉ែនតរ ដែលខើបនឹងត្រឡប់មកពីពិធីបុណ្យព្រះពុទ្ធជាតិសេកជាមួយនឹងមិត្តភក្តិ មិនព្រមស្តាប់ពាក្យនោះ បែរជាដើរចូលទៅកាន់សាលានោះ ឯអ្នកដែលដើរតាមលោកមកនោះ ក៏នាំគ្នាដើរទៅតាមក្រោយលោកដែរ ។

"អ៊ើ! លោកមេទ័ពពោលនឹងមិត្តភក្តិ "ប្លែកមែន! អ្នកសូមគានពីរនាក់នេះ ដេកលក់តាំងពីថ្ងៃព្រលប់អញ្ចឹងកើត ពិធីបុណ្យព្រះពុទ្ធជាតិសេកអ៊ូអែម្ទឹងៗមកដេកតើតដែរហ្ន៎ មិនគិតនាំគ្នាទៅចាំទទួលន្ទូវព្រះរាជគានដូចស្មមដទៃទេតេ តែ! ទុ! វាឈឺទេដឹង"

"ភានាធ!" លោកមេទ័ពហៅដោយទឹកមុខញញឹម "គេកំពុងតែបែកគានៅព្រះរាជវាំងឯណោះ ម៉េចក៏មិននាំគាឯងទៅទទួលយកនឹងគេ គិតតែមកដេកអញ្ចឹង តប៉ះតស្ទាបហោយ"

"តាគាត់មិនគ្រាតសោះពីរប៉ាថ្ងៃមកហើយ" ក្មេងនោះឆ្លើយព្រមទាំងប៉ះបីកភ្នែកទាំងពីរសម្ងឹងម៉្លេលគ្រឿនតែងតាយដ៏ល្អវិចិត្ររបស់លោកមេទ័ពដោយសេចក្តីគោតក្រែង

"ម៉េចអញ្ចឹង? គាត់ឈឺឬ?" លោកមេទ័ពសួរ "គាត់ដេកលក់" ហើយកុមារនោះបែរទៅអង្រួនជាស់តាចាស់ជរាព្រមទាំងស្រែកថា "តា! តា! ទៅទទួលយកគានធំគេធាប់ឡើង ខ្ញុំឃ្លានណាស់ហើយ"

សម្លេងស្រែករបស់កុមារ បានធ្វើឲ្យអ្នកទាំងអស់ដែលឈរនៅទីនោះនឹកអាណិតយ៉ាងខ្លាំង រហូតដល់លោកមេទ័ពលូកដៃហូតយកច្រាក់ដែលដាក់នៅក្នុងក្របូបចងក្លាប់នឹងវែកក្រវាត់មកហុចឲ្យកុមារនោះភ្លាមហាមណា:

បុរសម្នាក់ដែលឈរនៅជិតលោកមេទ័ពនោះបានឈ្លោកទៅពិនិត្យមើលមុខរបស់តាចាស់ជរាដែលដេកលក់នោះ ហើយក្នុងពេលនោះឯងគាត់ក៏ខុនទ្បើងថា

"ទុ! តាចាស់សូមគាននេះគាត់ស្លាប់ហើយទេតើ"

"ស្លាប់ហើយ!" លោកមេទ័ពសួរបន្ថែមពាក្យទៀតដោយទឹកមុខសង្វេគ "ហើយម៉េចទៅក្មេងនេះ!"

– ប្រហែលជាទៅគាត់ហើយមើលទៅ ហើយប្រហែលជានៅមិនទាន់ដឹងថាគាស្លាប់ទេ បានជានៅដេកជាមួយគ្នាដូច្នេះ នេះប្រហែលជាខើបនឹងស្លាប់ថ្មីៗនេះមើលទៅ" បុរសនោះពោល –

– តាគាត់មិនទាន់ស្លាប់ទេ! កុមារនោះឆ្លើយទៀង អម្បាញ់មិញនេះគាត់នៅបើកភ្នែកយើញនៅឡើយ ។

លោកមេទ័ពនៅស្ងៀម ទឹងអាណិតនឹងសង្វេគយ៉ាងខ្លាំង ចំពោះសភាពនៃអ្នកក្រីក្រលំបាក ដែល

ត្រូវមកដេកស្ងាប់ដោយគ្រោះថ្នាក់ខ្លាំង តាមដោយ
កន្ទេងសាធារណៈដូច្នេះ ។ លោកមេទ័ពជាមនុស្ស
ដែលមានសន្ដានចិត្តល្អ, គោរពនឹងអាណិតអាសូរ
មេត្តាអ្នកដទៃជានិច្ច ភាពវេទស់តាចាស់ដកដែលដេក
ស្ងាប់នៅចំពោះមុខលោកនោះ ធ្វើឲ្យលោកវេទនា
អាណោចអាធ័មជាខ្លាំងបំផុត ។

" តាវេទស់ឯងស្ងាប់ហើយអានាង ! អានាង
ឯងនៅដេកជាមួយនឹងគាត់មិនបានទៀតទេ " លោក
ពោលនឹងកុមារនោះ " ចុះអានាងឯងនឹងតាឯងទាំងពីរ
នាក់មកពីណាមក ? មានបងប្អូនញាតិសន្ដានស្ងាប់
សោះហិតនៅឯណា ? "

" ខ្ញុំមិនដឹងដែរ " កុមារឆ្លើយ " ខ្ញុំមកតែពីរ
នាក់នឹងតា "

" ឥឡូវតាឯងគាត់ស្ងាប់ហើយ អានាងឯងមាន
បងប្អូនឯណាខ្លះទៀតនៅមួយនឹងគេទៀ "

" ខ្ញុំនៅជាមួយនឹងតា "

" នៅមិនបានទេ " លោកមេទ័ពពោលផ្ទួន
ទ្បើង " អានាងឯងមានបងប្អូននៅឯណាខ្លះ ? "

" គ្មានទេ ! " កុមារឆ្លើយ " ខ្ញុំមានតែតានេះឯង "

លោកមេទ័ពនៅស្ងៀមមួយស្របក់ធំ ទើប-
និយាយនឹងមិត្តភក្តិលោកថា

" ក្មេងនេះ ប្រហែលជាគ្មានញាតិសន្ដានបង
ប្អូនទេ បើមិនដូច្នោះមិនមែនដើរមកសុំទានតែពីរនាក់
គាននឹងទៅដូច្នេះទ្បើយ ថ្ងៃនេះជាថ្ងៃមានមង្គល បើ
មានរឿងអ្វីជាទុក្ខសោកតើតទ្បើងដូច្នេះ យើងក៏គួរ
តែជួយជ្រោមជ្រែងកំចាត់ទុក្ខសោកនោះចេញ មក !
មកយើងជួយគ្នា ! ជួយគ្នាចាត់ចែងបូជាសពតាចាស់
នេះ យើងយកបុណ្យទៅចុះ ចំណែកខ្ញុំ ខ្ញុំនឹង
ខ្ចីលយកក្មេងនេះទៅចិញ្ចឹមធ្វើជាកូនចិញ្ចឹម ! បើ
យើងនឹងបណ្ដាយទ្បើរគ្រាប់ទៅតាមយថាកម្មទៅអនា
គតនៃក្មេងនេះនឹងខូចឥតអំពើ ម៉េចអ្នកណាយល់
ឃើញយ៉ាងម៉េចខ្លះ ? "

មិត្រភក្តិទាំងអស់ ក៏យល់ព្រមតាមលោកមេទ័ព
ដូច្នោះក្មេងពេលយប់នោះឯង វត្តជាយក្រុងក៏មានការ
បូជាសពតាចាស់ដកអ្នកសូមទាន ដែលគ្មានអ្នកណា
ម្នាក់ស្គាល់ តែមានលោកទេសយុត្តមេទ័ពនៃទេវតិរ
នគរនឹងក្រុមមិត្រភក្តិលោកជាអ្នកចាត់ការបូជា មាន
ការនិមន្តព្រះសង្ឃមកបង្សុកូលសពនោះ ត្រឹមត្រូវតាម
រាប្រពៃបបវេណីការបូជាសពគ្រប់ប្រការ ។

កុមារតូច ចៅរបស់ខ្មោចតាចាស់ដកសុំទាន
អង្គុយយំរៀបរាប់រហូតវេលា ជាទីគួរឲ្យសង្វេគពន់
ពេកណាស់ ។ លោកមេទ័ពព្យាយាមលួងលោម
នឹងសាកសួរឫងរ៉ាវផ្សេងៗ មានស្រុកទេស ម៉ែឪ
ជារដើម តែក៏គ្មានបានសេចក្តីថាដូចម្តេចសោះ មិន
ដឹងជាស្រុកទេសនៅឯណា ម៉ែឪឈ្មោះអីក៏មិនដឹង
ដឹងតែថានៅជាមួយនឹងតាប៉ុណ្ណោះ ហើយគ្រាប់ដើរ
សូមទានគេចាស់តែមកដល់ទេវតិរនគរនេះ ។

ដំណើរកំសាន្តនៅស្ងួនទន្លាយ (ក)



វត្តហិណ្ឌូស្តង់, បើសង្កេតតាមសភាព តែវត្តនេះនិយមប្រពៃណីបូរាណ, មានសេដ្ឋកិច្ច មិន ភូមិសាស្ត្រផ្សេងទៀតទេ ដូចវត្តមាន អាចគិតផ្សះផ្សាបានដោយងាយ, ហើយប្រែន ស្ថានការណ៍នយោបាយមួយដាំឯកច្ឆន្ទ តែអាណា កើតវិបរិតផ្សេងៗជាច ។ បញ្ហាសង្គមកិច្ចដាបញ្ហា វិទ្រមួយៗមានទំហំធំទូលាយ, មានសង្គមផ្សេងៗ សុខុមគម្លាភាពនាំឲ្យកើតទុក្ខសង្គដាច្រើនវៃបបយ៉ាង; គ្នាមានទុក្ខាគានខាងប្រពៃណីបូរាណ ខ្លះ ខាងកុល បញ្ហាដែលលំបាកនឹងដោះស្រាយបំផុតគឺបញ្ហាពួក សម្ព័ន្ធខ្លះ, ខាងវណ្ណៈខ្លះ ហើយពួកនេះស្ថិតនៅ ចណ្ឌាល, គឺពួកវណ្ណៈហ៊ីនតេទ ។ ច្របូកច្របល់គ្នាគ្នានរបៀបរៀបរយសោះឡើយ ។

ឯវត្តហិណ្ឌូស្តង់ដែលមានព្រះពុទ្ធសាសនាតាំងនៅទី វត្តនេះមាន ពង្ស ទុស្សាហកម្មដាច្រើន គឺពេងរវៀ ក្រុងញ្ជីវដែល្លី មានលោកបណ្ឌិតនេហ៊ីរូនាយករដ្ឋ- កម្ម៉ាស ៣៩០ ខ្នង, ព្យង្គឈើ ៣០ លាន គាន, តែ មន្ត្រីជាអ្នកមគ្គទេសក៍យ៉ាងចំណាន, បានបន្ត មិនសូវមានប្រែងកាតទឹងហាមភាពនាពាសាស្ត្រ ។ បើ នយោបាយលោកមហាត្មៈគន្ធីតាំងពីនោះជាបឋមក ។ តាមពិនិត្យ, វត្តនេះ ដូចជាវត្តប្រកបដោយភោគ ទៅស្នងទន្លាយក៏សួរទៅលោកអាម៉ាត់សិន ថា: ទ្រព្យច្រើនជាគរ ប្បការ ព្រោះថាជាវត្តមានកសិកម្ម "អ្នកណាដែលមាននាមថាបណ្ឌិតនេហ៊ីរូ?" ជាច្រើនកន្លែង; ខាងទុស្សាហកម្ម, ក៏បម្រុងទឹងបង្កើត បណ្ឌិតនេហ៊ីរូនេះជាបុព្វបុរសប្រទេសឥណ្ឌា ។ រោងចក្រ, យន្តជាច្រើន, ច្រាក់ខ្លួនក៏មានច្រើន ។ លោកបដិសន្ធិនៅទីក្រុងអល្ម៉ាហាថាដ, ថ្ងៃទី ១៤ វិច្ឆិកា

គ.ស. ១៨៨៩ ។ ដីខ្ពស់បណ្តិតនេហ៍រូនៅវដ្តកាស៊ីម៉ីរ
វិតបានធ្វើដំណើរមកកាន់ទីក្រុងដែល្ហី (គ.ស.
១៧១៦) ។ ពាក្យថានេហ៍រូនេះមកពីជីតាលោក
នាមរាជកុលបានទទួលព្រះរាជអំណោយព្រោះបាន
ហ្វាក្រស៊ីការ នូវដីមួយកន្លែងមានគេហដ្ឋាននៅមាត់
វិត្រកដីក; ពាក្យហិណ្ឌីថា: នហារវែប្រថាត្រែកដីក,
ក្លាយទៅជានេហ៍រូ ។ បានជាដីតាខ្លួនលោកប្រែនាមថា
ភូលនេហ៍រូ ។ ដីដូនខ្លួនលោកនាមនាងលក្ស្មីនារយ័ន ។
នេហ៍រូធ្វើមេធាវី; ដីតាលោកនាមតង្កា-ធរ.នេហ៍រូណា ថៅ
ហ្វាយក្រុង ដែល្ហី ។ កាលមានបះបោរនៅទីក្រុង
ដែល្ហី (១៨៥៧) ក្រុមគ្រួសាររបស់លោកបានវត់
ទៅពួននៅទីក្រុងអគ្រ: ។ នៅទីក្រុងនេះដីតាលោក
បានបដិសន្ធិ នៅថ្ងៃទី ៦ ឧសភា គ.ស. ១៨៦១ ។
យើងមិនអាចពោលទៀតស្តាវខ្លួវដីប្រវត្តិលោកបណ្តិត
នេហ៍រូទេ, យើងគ្រាន់តែពណ៌នាដោយសង្ខេបថា:
បិតាលោកនាមលោកម៉ូទីលាល់នេហរូ, មាតាលោក
មានប្អូនស្រីនាមនាងក្រិស្នា ។ លោកបានរៀប
វិវាហមង្គលការនឹងនាងកមលា, អាយុ ១៧ ឆ្នាំ,
លោកអាយុ ២៦ ឆ្នាំ ។ លោកមានបុត្រីម្នាក់
នាមនាងអិន្ទិរ៉ា មានស្វាមីម្នាក់នាម ហ្វេរូហ្ស-គន្ធី
ដាដាតិប៉ារសី (មិនមែនជាញាតិសាលោហិតរបស់
លោកមហាត្មៈគន្ធីទេ) ។ ដល់មកថ្ងៃ១ឧសភា គ.ស.
១៩០៥, បិតាមាតា, ប្អូនស្រីនឹងលោកបានឡើងនាវ
ទៅកាន់ប្រទេសអង់គ្លីតែរ ។ ក្រុមគ្រួសារទាំងអស់បាន
ទៅដល់ទីក្រុងហារូវហើយ បិតាលោកបានយកលោក
ទៅផ្សារៀនសូត្រនៅវិទ្យាល័យក្រុងនេះ ។ បន្តិចទៀត,
គ្រួសាររបស់លោកបានវិលត្រឡប់មកប្រទេសឥណ្ឌា
វិញទុកលោកនៅតែម្នាក់ឯងឯទីក្រុងនេះ ។ លោក
ទើបនឹងមានអាយុ ១៥ ឆ្នាំ, លុះដល់ថ្ងៃ គ.ស.
១៩០៧, លោកបានចូលទៅរៀនមហាវិទ្យាល័យ
ភ័មព្រិដ្ឋ ។ លុះប្រឡងជាប់សញ្ញាប័ត្រ គ.ស. ១៩១០
ដល់ គ.ស. ១៩១២ លោកបានប្រឡងជាប់ជាមេធាវី,
ហើយក៏វិលត្រឡប់មកកាន់ប្រទេសឥណ្ឌាវិញ លោក
បានធ្វើជាមេធាវីហើយលោកបានរៀបវិវាហមង្គលការ
នឹងនាងកាមាលា ឆ្នាំ ១៩១៦ នៅទីក្រុងដែល្ហី ។
លុះមកដល់ឆ្នាំ ១៩១៩, លោកមហាត្មៈគន្ធីបានធ្វើ
មេដឹកនាំកងការបះបោរហើយលោកបានធ្វើពិធី
សម្ពោធន៍ទូវបាវចនារបស់លោក សត្យគ្រហៈសាភៈ
(Satyagraha Sabha) ដែលមានសមាជិកជាច្រើន
ធ្វើសច្ចាប្រណាំងថាត្រូវកុំប្រតិបត្តិតាមបទបញ្ជត្តិច្បាប់
វូឡាត់ជាច្បាប់ចក្រពត្តិនិយមអង់គ្លេស ។ ដល់
លោកបានឃើញការចលនានោះ លោកក៏ចូលមក
ស៊ុំចុះជាសមាជិក ដោយលោកមិនបានគិតនូវផលអំពី
តាយវិការបែបនេះសោះឡើយ ។

លោកមហាត្មៈគន្ធីបានកំណត់ថ្ងៃទី ១ អ៊ូត គ.ស.
១៩២០ ជាកាលបរិច្ឆេទសម្ពោធន៍នៃលទ្ធិមិនព្រមធ្វើ
សហការជាមួយនឹងរដ្ឋាភិបាលនឹងលទ្ធិអព្យាបាទ,
គឺមិនគំទ្រគាំគួនអ្នកដទៃ ។ តែមានថ្ងៃមួយពេល

សាយណ្ហសម័យ, មាននាយប៉ូលិសចូលមកបង្ហាញ
សំបុត្រពីរាជការថាកុំឲ្យខ្ញុំចូលទៅសន្ទនាការ ជាមួយ
នឹងគណៈប្រតិភូប្រទេសអហ្គានីស្ថង់ ។ គណៈ
ប្រតិភូនេះបានទៅរួមប្រជុំនឹងគណៈប្រតិភូអង់គ្លេស
ក្រោយសង្គ្រាមប្រទេសអហ្គានីស្ថង់ឆ្នាំ ១៩១៩, ក្នុង

ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់ហើយ ទ្រង់
អាណិតកុមារជ័យពន់ពេក ទ្រង់មានព្រះតម្រិះថា បើ
កាលណាដល់ពេលចូលលេង អញមើលទៅមិនស្រួល
នឹងស្រែកបញ្ឈប់មិនឲ្យលេង ។ ទ្រង់ក៏ប្រទានអ្នក
ស្ងួតស្អាងយ៉ាងចំណានបំផុត នឹងមហាតលិក ៤ នាក់
ឲ្យមកកុមារជ័យ ប្រើតាមត្រូវការ ។

កុមារជ័យលុះបានអ្នកស្ងួតស្អាង នឹងមហាតលិក
៤ នាក់មកហើយ ក៏បង្គាប់ទៅអ្នកស្អាងថា អ្នកបង
ដែលព្រះមហាក្សត្រគាត់មកនេះ ត្រូវទទួលធ្វើតាម
បង្គាប់ខ្ញុំ បើមិនធ្វើឲ្យត្រូវតាមបង្គាប់ខ្ញុំទេ ខ្ញុំនឹងចូល
ទៅក្រាបបង្គំទូលព្រះមហាក្សត្រឲ្យយកទោស ។ ចំ-
ណែកអ្នកស្ងួតស្អាង ត្រូវស្អាងខ្លួនខ្ញុំនេះឲ្យមានសាច់

រដ្ឋការមហាពាជ អាម៉ានុល្លាហ៍ ។ តែមិនដឹងជា
យ៉ាងណា, ស្រាប់តែលោកទទួលនូវដីកាមួយពីពាជការ
បង្គាប់ឲ្យលោកចេញពីទីក្រុងដេចារ៉ាំនុក្នុង ២៤ ម៉ោង ។

(មានត)

★

★ ★



(ចប់)

ស្បែកមុខមាត់ដំណើរទំនងដូចជាទារក ដែលទើបតែ
ទើតបានប្រាំពីរថ្ងៃ ។ ចំណែកមហាតលិកទាំង ៤
ត្រូវបើបមច្ចមបំពេរ ឲ្យដូចជាអ្នកចំអើកូនខ្ចី ទើបអ្នក
ទាំងអស់គ្នាបួនខ្លួនបាន ។

បើមិនប្រណិបតន៍តាមពាក្យនេះ មុខជាមាន
ទោសមិនខាន ។

អ្នកស្ងួតស្អាងនោះ យកថ្នាំ ប្រេង មៀល នឹង
គ្រឿងប្រដាប់សម្រាប់ស្ងួតស្អាងផ្សេង ។ មកគោរ
ណាបខ្លួនកុមារជ័យ តាំងអំពីសក់ រហូតដល់ចុងជើង
ដរាបតាល់តែមានពណ៌សម្បុរថ្នាខ្ចី មានទ្រង់ទ្រាយ
ដូចជាទារកទើបនឹងកើតបានប្រាំពីរថ្ងៃ ។

កុមារជ័យ បង្គាប់ឲ្យមហាតលិកទាំង ៤ នាក់ចង

អង្រឹងហើយឲ្យជាក់ខ្នងផ្តេកទៅក្នុងអង្រឹង យកសំពត
យ៉ាងស្អាតមកគ្របពោះយោលបំពេរជារាល់ថ្ងៃមិនដែល
ដាច់ , ហាមមិនឲ្យអ្នកណាមួយមកលេងក្នុងផ្ទះនោះ
ឮសោះ ។ បើមានគេមករកត្រូវសួរឲ្យច្បាស់ប្រាកដជ
ថា មានការអ្វី? បើគេប្រាប់ថាមកលេងត្រូវប្រាប់
ឲ្យគេត្រឡប់ទៅវិញទៅ ។ បើគេប្រាប់ថាមករកបង
នេះបងនោះ ត្រូវប្រាប់តាមមានតាមគ្មាន ។ បើ
គេប្រាប់ថាមករកឈ្មោះខ្ញុំ ត្រូវប្រាប់ថា លោកមិន
នៅទេ លោកទៅចាំស៊ីលថាត់ទៅហើយ ។

បើគេសួរថា នេះជាកូនអ្នកណា ? ត្រូវប្រាប់
ថា កូនលោក

-.,... កើតបានប៉ុន្មានថ្ងៃ? ---កើតបាន
៧ ថ្ងៃ

...,ម្តាយទៅណា ? ... ម្តាយស្លាប់ហើយ

--- ថ្ងៃណាទើបលោកត្រឡប់មក ? ...
ថ្ងៃសេនចំបាប់ ។

ថ្ងៃមួយគ្រូចំបាប់នោះ បានមកដើម្បីមើលរូប ។
លុះមកដល់ភូមិកុមារជ័យហើយសួរគេថា អ្នកចំបាប់
រមស់ព្រះមហាក្សត្រនោះឈ្មោះអ្វី ?

អ្នកស្រុក អ្នកចំបាប់នោះឈ្មោះជ័យ

គ្រូចំបាប់ ផ្ទះនៅឯណា ?

អ្នកស្រុក ផ្ទះនៅឯណោះ

គ្រូចំបាប់ ជ័យនោះក្មេងឬចាស់ ?

អ្នកស្រុក ជ័យនោះនៅក្មេង

គ្រូចំបាប់ដើរសំដៅទៅដល់ផ្ទះកុមារជ័យហើយ
បានឡើងទៅលើផ្ទះ ឃើញមហាតលិកកំពុងយោល
បំពេរឆ្លីវ ។ មហាតលិក បានសួរគ្រូចំបាប់នោះថា
លោកអញ្ជើញមកមានការអ្វី ?

គ្រូចំបាប់ ចាមកលោកជ័យ

មហាតលិក លោកមិននៅទេ

គ្រូចំបាប់ ចុះលោកអញ្ជើញទៅណា ?

មហាតលិកលោកទៅតាំងស៊ីលថាត់ទៅហើយ ។

គ្រូចំបាប់ ចុះចំនួនប៉ុន្មានថ្ងៃ ទើបលោកអញ្ជើញ
មក មហាតលិក ពុំលោកមានប្រសាសន៍ថា ដល់
ថ្ងៃសេនចំបាប់ទើបលោកត្រឡប់មកវិញ សេនថ្វាយ
ព្រះមហាក្សត្រតែម្តង ។

គ្រូចំបាប់ ចុះដែកនៅអង្រឹងកូនអ្នកណា ?

មហាតលិក នេះជាកូនរបស់លោក ។

គ្រូចំបាប់ កើតបានប៉ុន្មានខែហើយ ?

មហាតលិក ទើបនឹងកើតបាន ៧ ថ្ងៃ ។

គ្រូចំបាប់ ចុះម្តាយទៅណា ?

មហាតលិក ម្តាយគ្រាន់តែធ្វើនំខ្នុរហើយ
អនិច្ចកម្មទៅ ។

គ្រូចំបាប់គិតថា បើកូនទើបនឹងកើតបាន ៧ ថ្ងៃ
ប៉ុណ្ណោះទៅហើយ ចំណង់បើផ្ទៃពុកវាមិនដឹងជាប៉ុន្មាន
ទៅទៀត ។ ធម្មតាកូនតែងគាត់ទៅផ្ទៃពុក បើផ្ទៃពុក
វាំង កូនក៏ធំ, បើផ្ទៃពុកវាតូច កូនវាក៏តូច ។ ចំ-
ណែកខាងម្តាយទៀតសោតគ្រាន់តែធ្វើនំខ្នុរហើយក៏-

ស្លាប់ទៅទៀត ។ ជាហេតុមួយនាំឲ្យដឹងបានថា
កូននេះប្រាកដជាកាត់ទៅខាងឪពុក បើកាត់មកខាង
ម្តាយប្រហែលជាម្តាយមិនស្លាប់ទេ ។ ឯខ្លួនគេទៀត
សោតថ្ងៃនេះគេនៅតាំងស៊ីលនៅឡើយ ចំណែកខ្លួន
អញមានតែកម្ទាំងហើយនឹងស្មៀតគ្មានស៊ីលអាតមអ្វី—
នឹងគេសោះ ។ បើយ៉ាងនេះឃើញថានឹងលេងជាមួយ
នឹងគេមិនបានបើអញនឹងឈប់តែម្តងទៅ ក្រែងព្រះ
មហាក្សត្រដឹង, ដូច្នេះត្រូវតែចូលទៅក្រាបបង្គំទូលព្រះ
អង្គឲ្យទ្រង់ជ្រាបសិនថា ស្អែកនេះនឹងលេងថ្វាយមិន
បានព្រោះខ្លួនមានដម្លឹគ្រូនក្តៅក្រហាយញាក់សព្វសាច់តាំង
អស់ទើបអញរួចខ្លួន ។

លុះគិតដូច្នោះរហ័យគ្រូចំបាប់ ចូលទៅក្រាបបង្គំ
ទូលព្រះមហាក្សត្រថា បពិត្រព្រះសម្មតិទេព ទូលព្រះ
បង្គំពុំសូវស្រួលខ្លួន ភ្តៅញ័រញាក់សព្វសាច់តាំងអស់
នឹងលេងចំបាប់ថ្វាយក្នុងថ្ងៃស្អែកនេះមិនបាន សូមទ្រង់
ព្រះមេត្តាព្រះរាជទានទោស ។

ព្រះមហាក្សត្រ ឯងលេងមិនកើត តើរកអ្នក
ដទៃសិនបានឬទេ ?

គ្រូចំបាប់ សូមទ្រង់ព្រះមេត្តាប្រោស ទូល
ព្រះបង្គំនឹងថ្វាយមិនបានទេ ។

ព្រះមហាក្សត្រ ក៏ទ្រង់ទទួលការៈនេះដោយ
តុល្យភាព ។

(នៅមានត)

រឿងគួរដឹងដែលទាក់ទងនឹងថ្នាំជក់.

(ដោយ ប. បញ្ជង់ចិត្រ.)

យើងធ្លាប់បានឮតែទោសរបស់ថ្នាំ ។ ចាស់ៗ
ច្រើនតែហាមក្មេង ។ ដែលជក់ថ្នាំដោយអាងថា វា
ឲ្យទោសដល់រាងកាយ ។ ស្ត្រីក្រមុំស្អាត ។ ច្រើន
តែខ្ពើមប្រុសកម្លោះដែលជក់ថ្នាំ ដោយនាងប្រាប់ថា
ស្អុយក្អកពេលដែលចូលទៅជិត ។ គ្រូពេទ្យចូល
ចិត្តអធិប្បាយថា ថ្នាំឲ្យទោសដល់រាងកាយច្រើន
ណាស់ អាចធ្វើឲ្យកើតរោគដំបៅសួត (Cancer) ។
គ្រូច្រើនតែហាមសិស្សមិនឲ្យជក់ថ្នាំជាដាច់ខាត ។

តែគួរឲ្យប្លែកណាស់ក្នុងខណៈដែលនរណាៗក៏
សុទ្ធតែយល់ឃើញថាថ្នាំមានទោសយ៉ាងខ្លាំងនោះ
ពួកមនុស្សប្រាជ្ញខ្លះនយមការជក់ថ្នាំ ស្ត្រីរូបខ្លះនយម
ដែលហាមប្រាមសិស្សមិនឲ្យជក់ថ្នាំនោះ ខ្លួនឯងក៏
ជក់ថ្នាំរាល់ ។ ថ្ងៃ ។

តាលបើដូច្នេះ មិត្រនឹងដឿងឬថាថ្នាំមាន
ទោសពិតប្រាកដនោះ ។ លោកធីវឈិល នាយក
រដ្ឋមន្ត្រីប្រទេសអង់គ្លេសនោះ ជក់ថ្នាំស៊ីគារបន្តកន្ទុយ
គ្មានដាច់ឡើយ រឿរលែងតែពេលដែលលោកលក់ប៊ុណ្ណោះ
បើថ្នាំឲ្យទោសដ៏កំណាចដល់រាងកាយពិតប្រាកដនោះ
រដ្ឋបុរសនេះលោកនឹងហ៊ានជក់ថ្នាំឬ? សូមមិត្រអាន
តទៅ មិត្រនឹងបូលចិត្តរឿងកំរបស់ថ្នាំនេះច្បាស់

លាស់ឡើង ។

ប៉ុន្តែមិនមែនជារបស់ថ្មីទេ មានអ្នកបានស្គាល់ជ្រាមកជាង៤០០ឆ្នាំហើយ ។ តាមប្រវត្តិសាស្ត្របានពោលទុកដូច្នេះថា កាលពីថ្ងៃទី ១៤ តុលា គ.ស. ១៤៩២ ដែលនៅវេលា ៤ ៦ ៣ ភ្នែកទន្ទឹងមកហើយ ថ្ងៃដែលពោលដល់នេះជាថ្ងៃសំខាន់បំផុតក្នុងប្រវត្តិសាស្ត្រនៃជ្រាល ព្រោះថ្ងៃនោះហៅថ្ងៃដែលដូនជាតិអឺរ៉ុបម្នាក់បានដួបប្រទះនឹងសន្ទឹកថ្មាំដាំជាគ្រាដំបូង លើកោះវៃតធ្លិង (Wtling Island) ក្នុងប្រទេសបាហាម៉ាស (Bahamas) ដែលតាំងនៅទ្វីបអាមេរិកតណ្ហាលតែជាប្រទេសដែលនៅក្នុងការអារក្ខារបស់អង់គ្លេស ។ អ្នកដែលបានយើញជាប្រចក្សគឺលោកខូឡុំប័ស (Columbus) ។ ឥឡូវនេះវេលាកន្លងទៅហើយជាង៤ ៦ ០ ឆ្នាំ តែសន្ទឹកថ្មាំដាំដ៏អស្ចារ្យនេះក៏នៅមានតាំងពាណិជ្ជកម្មនឹងតំបន់ដ៏កំណាចរបស់មនុស្សខ្លះទៀតដែលតាមពិត ក៏នៅមានលក្ខណៈនៃការជំរាស់គ្នាតាំងពីរផ្នែក ខ្លះថាមានគុណ ខ្លះថាមានទោស ។

ជ្រាមនេះ ខូឡុំប័ស ដែលជាកូនគាត់ជាតិអេស្បាញ-ឥតាលី ជាអ្នកដួបប្រទះហើយនាំយកមកផ្សាយដល់ពិភពលោកក៏ពិត តែអ្នកដែលអនុញ្ញាតឲ្យជ្រាមក្លាយទៅជាទំនិញរបស់សង្គមបាននោះ ក៏គឺស្តេចដែនដីប្រទេសអង់គ្លេស ដែលនឹងបានពោលដល់លក្ខណៈទុកដូចតទៅនេះ

ស្តេចដែនដីដែលទ្រង់អនុញ្ញាតឲ្យសង្គមក្នុងប្រទេសអង់គ្លេសបានោះ ក៏គឺព្រះបាទអិតវ៉ាតទី៧ (Edward VII) ។ ក្នុងរជ្ជសម័យនៃសម្តេចព្រះពាជិនី វិកតរវៀ (Queen Victoria) ដែលជាព្រះមាតានៃព្រះបាទអិតវ៉ាតនោះ ។ ព្រះពាជិនីទ្រង់ឡើមបារីជាទីបំផុតហើយប្រគាន់ថា អ្នកដាំបារីជាអ្នកដែលមានយាទ ។ ការនាំយកថ្មាំដាំមកប្រើក្នុងវិធីបែបណាក៏ដោយ ជារបស់ដែលហាមយ៉ាងខ្លាំងក្នុងបរិវេណព្រះពាដវាំង ដូច្នេះក្នុងយុគសម័យនោះ ពួកខុនណាង ភ្នាក់ងារពាដការទើបមិនមានអ្នកណាហ៊ានដាំបារីក្នុងតំបន់ព្រះពាដវាំងឡើយ ។ តែក្រុតមកតំទ្រង់មានព្រះពាដរយៈបល់បែកផ្សេងទៅទៀត ក្នុងវេលាដែលព្រះអង្គទ្រង់គង់នៅក្នុងតំណែងជាឧបយុវពាដនៅឡើយនោះ ព្រះអង្គតំទ្រង់សោយបារីញៀនខ្លាំងណាស់ដែរ ហើយលុះព្រះអង្គឡើងសោយពាដសម្បត្តិជាប់ព្រះបាទអិតវ៉ាតទី៧ គាលណា ព្រះពាដកិរណីយកិច្ចជាបឋមដែលទ្រង់ធ្វើគឺ ទ្រង់បានប្រកាសលើកលែងទោសកំហុសក្នុងការដាំបារីក្នុងសង្គមដែលពាដមាតាបង្កើតព្រះអង្គទ្រង់បានត្រាស់បង្គាប់ហាមប្រាមដល់ពួកអ្នកដាំបារីទាំងឡាយ-

ការប្រកាសលើកលែងទោសហាមប្រាមមិនឲ្យដាំបារីក្នុងព្រះពាដាំងអង្គេសនេះ ទ្រង់បានធ្វើក្នុងទុកាសដែលមានការដាប់លៀងធូងជាគ្រាដំបូងក្នុងព្រះពាដាំង គ្រាក្រោយដែលទ្រង់ឡើងសោយពាដហើយ ក្នុងវេលាដែលពួកក្សៀវប្រុស ។ ទាំងឡាយកំពុងតែអង្គុយនៅ

កងឯបន្ទប់ជំនុំកាហ្វេនោះ ព្រះបាទអិតវ៉ាត្រង់ស្តេចយាងមកគង់ជាមួយដៃរដើម្បីត្រួតត្រាមើលទុនណាងទៀ មួយសន្ទុះតមកទ្រង់បានសួរ ពួកពាជទូតបរទេសនីងទុនណាងពាជការពាំងឡាយដែលសុទ្ធតែទឹកមុខដ៏តេញទៀដោយការអត់ទ្រាំយ៉ាងលំបាកគ្រប់គ្នា ដូចជាថា នីងសូមអភ័យអ្វីម្យ៉ាងតែគ្មានអ្នកហ៊ានឆ្លើយអ្វី ហើយគ្រប់គ្នាក៏សំដែងទូរសេចក្តីត្រេកអរបស់នោះដោយទឹកមុខដ៏ស្រស់ស្រាំ—

កងខណៈនោះឯង ព្រះអង្គទ្រង់បានប្រកាសចំពោះប្រជុំជនក្នុងពីនោះដោយព្រះសូរសៀងដ៏សុភាពទន់ភ្លន់ថា "សុភាពបុរសពាំងឡាយ សូមលោកដក់ចារីចុះ" ព្រះពាជតម្រាស់គ្រានោះឯង គេប្រកាន់ថា ជារបស់សំខាន់បំផុតនៃយុគនោះ ព្រោះជាសេចក្តីប្រណីចំពោះការអត់ធន់ដ៏លំបាករបស់ព្រះពាជតំណាក់ក្នុងយុគនោះជាក្រៃលែង ។ បើនីងរាប់រៀលាពីថ្ងៃដែលខ្ញុំបាទសូមប្រទេសនីងសន្ទឹកថ្នាំគ្រាដំបូង រហូតដល់ថ្ងៃដែលព្រះបាទអិតវ៉ាត្រង់ប្រកាសអំណាចដ៏ធ្ងៃវិទ្ធាតរបស់ព្រះអង្គអនុញ្ញាតឲ្យពាជការនាំគ្នាដក់ចារីបាននោះ ជារៀលាឆ្ងាយពីគ្នាដល់ ៤០០ថ្ងៃ ដែលជារឿងស្ទើរតែមិនគួរជឿតែម្តង ។ ក្នុងពេលដ៏វែងឆ្ងាយនេះ អ្នកដក់ចារីពាំងឡាយបាននាំគ្នាស្រាវជ្រាវរកពូជដ៏ពុលឬស្រែងពាំងនេះ គាល់តែស្ទើរតែគ្មានវិធីត្រកំណាត់តែម្តង

សន្ទឹកថ្នាំដក់ក៏បានក្លាយជាវត្ថុមានតម្លៃសម្រាប់ជនជាតិអឺរ៉ុប ដូចគ្នានីងអំបិលនីងគ្រឿងទេសដែលជារបស់មានតម្លៃថ្លៃបំផុតរបស់ជនជាតិ រោ ម៉ាន់ (Romans) ។ ពួកអ្នកជំនួញខ្ញុំកំដរក្នុងសម័យបុពណានីងគិតតម្លៃខ្ញុំកំដរដែលគេលក់ឲ្យតាមចំនួនសន្ទឹកថ្នាំដក់ ។ ពួកអ្នកដែលតាំងភូមិលំនៅ ។ ក្នុងមលរដ្ឋវ៉ីយ៉ូនៀ (Virginia) សហរដ្ឋអាមេរិក សុទ្ធចិត្តចាយប្រាក់ថ្លៃបញ្ជូនសន្ទឹកថ្នាំដក់ដែលល្អជាទីបំផុតដល់មួយសន្ទឹក ៣៥០ដុល្លា (ប្រហែលជា ១២.២៥០រៀល) ដែលប្រាក់ចំនួននេះអាចនីងប្រើក្នុងការរៀបមង្គលការនីងស្តីក្រមុំបានយ៉ាងស្រួលតែម្តង ។

ក្នុងប្រទេសរុស្ស៊ីនីងប្រទេសនានាភាគខាងកើតត្រូវជួបប្រទះនីងគារុណកម្មដ៏ខ្លាំងនីងសេចក្តីស្លាប់ដែលជាប់ពាក់ពន្ធមកពីថ្នាំដក់នេះជាចំនួនច្រើន ។ ក្នុងអឺរុបភាគខាងលិចនោះ សន្ទឹកថ្នាំដក់បានបង្កឲ្យកើតជាក់ទោសដល់ទៅចង្កត ប្តកាត់ចេញពីគោរពពាប់អានសាសនា ព្រោះតែល្មើសនីងច្បាប់ដែលពាក់ពន្ធនីងថ្នាំដក់—

ក្នុងសហរដ្ឋអាមេរិកសន្ទឹកថ្នាំដក់ដែលធ្វើឲ្យពុលស្រែងនេះឯង ដែលធ្វើឲ្យប្រវត្តិសាស្ត្រក្នុងផ្លូវសង្គភិច្ច សង្គមនីងផ្លូវនយោបាយលៃរលៅទៅ លោកដេនទ្រិគ ហិនរី (Patrickenry H) ជាបុគ្គលម្នាក់ដែលចុះហត្ថលេខាប្រកាសឥស្សរភាពរបស់សហរដ្ឋអាមេរិក បានក្លាយទៅជាបុគ្គលដែលមានឈ្មោះបោះសម្លេងជាគ្រាដំបូង ក្នុងកាលៈលៃលោកបានជំទាស់

ទឹងច្បាប់របស់ស្តេចផែនដីអង់គ្លេស ក្នុងការគារុណដែលគាត់ចង់ទឹងថ្នាំជក់នេះ

ក្នុងបច្ចុប្បន្ននេះ ប្រជាជនទូទៅពាំងចាស់ពាំង-ក្មេង-អ្នកមាន អ្នកក្រក៏សុទ្ធតែនាំគ្នាជក់ថ្នាំរីស្ទើរតែពាំងអស់ ។ ពួកអ្នកពាជការទឹងត្រូវប្រើប្រាំរដែលគិតជាទម្ងន់ប្រមាណជា ៧៥គីឡូក្រាម សម្រាប់ពិធីរៀបមង្គលការ ហើយអាចប្រើដល់ទៅ ១៥០គីឡូក្រាម ក្នុងពិធីបូជាសព ដើម្បីទទួលភ្ញៀវ ។ មានមនុស្សសុខចិត្តទទួលភ័យក្នុងការជាប់គុកដោយលបលួចដាំសម្ងឹកថ្នាំជក់ក្នុងការរបស់គេ ដែលជាការខុសច្បាប់។ សម្តេចព្រះរាជិនី អេលីហ្សាបែត (Queen Elizabeth) បានឲ្យឈ្មោក ស៊ីរ វ៉ាលធឺរ រ៉ាឡេហ៍ (Sir walter Raleigh) ជាអ្នកបង្រៀនវិធីជក់ថ្នាំរដែលព្រះនាងរហើយមានអ្នកខ្លះទំពាស្លឹកថ្នាំចុកទៅក្នុងមាត់ដើម្បីធ្វើឲ្យធ្មេញស្អាត ។

ក្នុងខណៈពាក់ពន្ធដល់វិទ្យាសាស្ត្រក្នុងផ្លូវពេទ្យនាំគ្នាដឿថា ថ្នាំជក់ទឹងធ្វើឲ្យកើតដុំថ្មៅសួតបាននោះមួយផ្នែកទៀតក៏ត្រូវបាប់មកជាប្រើថ្នាំជក់ក្នុងផ្លូវដែលទឹងជាថ្នាំបំបាត់រោគបាន ដូចក្នុងគ្រាកើតគាឡរោគប្អ ពិស (Plague) គ្រាធំនៅក្នុងប្រទេសអង់គ្លេស គាល ឥ.ស. ១៦៦៤–១៦៦៦នោះ ពួកសិស្សពាំងច្បាយក៏សុទ្ធតែត្រូវបង្គាប់ឲ្យជក់ថ្នាំ ជក់១ថ្ងៃ១ខ្សៀវ ដើម្បីប្រើជាថ្នាំបំបាត់រោគ បើសិស្សរើនទឹងមិនព្រមជក់ទឹងត្រូវទទួលទោសវិញ ។

ដូច្នេះ មិត្រទឹងឃើញបានថា ថ្នាំរមានពាំងគុណទឹងទោស ។ ដូច្នោះ មិត្រដែលគិតជក់ថ្នាំរក៏គួរតែពិចារណាជាមុនសិនថា គួរជក់ ឬមិនគួរជក់។ ទៅសដែលបានឃើញងាយ។ នោះគឺ ខាតច្រាក់។ មិត្រនៅមិនទាន់បានជក់ថ្នាំរផង គ្រាន់តែទៅទិញមកប៉ុណ្ណោះ មិត្រក៏ខាតច្រាក់ទៅហើយ ។ ហេតុនោះក្នុង។ ដែលនៅរកច្រាក់មកចាយទូនឯងមិនទាន់បាន ក៏គួរតែប្រយ័ត្នក្នុងរឿងនេះវ្យមែនទែន គួរតែប្រយ័ត្នជាងមនុស្សចាស់ ។ សម្រាប់បុរសកម្លោះដែលកំពុងតែស្រឡាញ់ស្ត្រីក្រមុំនោះវិញ ក៏ត្រូវតែប្រយ័ត្នជាពិសេស ព្រោះមិត្រអាចនឹងមិនដឹងក៏បានថា ស្ត្រីក្រមុំស្អាត។ នោះ ស្អប់បុរសដែលជក់ថ្នាំរ៏ណាស!!!

★

★ ★

ពិធីបុណ្យបំបួសកុលបុត្រជាតិបារាំងវិសេស

១ រូបនៅវត្តឧណ្ណាលោម



ក្នុងថ្ងៃអាទិត្យ ១កើតខែកត្តិក ព.ស. ២៤៩៨ (១៦-១០-៥៥) វេលាម៉ោង ៣ កន្លះរសៀល នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ មានពិធីបុណ្យបំបួសកុលបុត្រជាតិបារាំងវិសេស ១ រូប ជាសាមណេរ ដោយមានសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ជាព្រះឧបជ្ឈាយ៍ ។ កុលបុត្រនេះមានឈ្មោះឡ្រ៊ែង-ប៊ូតែល អាយុ ២៥ ឆ្នាំ បានទទួលពុទ្ធិកនាមថា អានន្ទៈ នៅវេលាដែលបួសរួចហើយ ។

នៅព្រះវិហារវត្តឧណ្ណាលោមក្នុងវិថ្ងៃនោះ, ផ្នែកខាងព្រះសង្ឃ,គេបានឃើញសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយវត្តឧណ្ណាលោម, ព្រះពោធិវង្សបាង់ហ្វាង់ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត្យ, ព្រះសាសនមុនីជាចៅអធិការពិកក្ដូវង្សី ភ្នំពេញ ព្រមទាំងព្រះពាជាគណៈថានានុក្រម និងព្រះតិក្ខុសង្ឃឯទៀតៗ ជាច្រើនអង្គ ។ ផ្នែកខាងគ្រហស្ថ, មានអស់លោកជាមន្ត្រីបរទេសទាំងឡាយដែលបានអញ្ជើញទៅចួបជុំជាតិចួបជាល់ខ្លួនគឺលោកវេជ្ជបណ្ឌិត ប៊ុ-ហ៊ីប្ប៉ត់ ជាពុទ្ធិកជនជាតិបារាំងដែលជាពំនឹងរបស់សាមណេរនោះ ! លោកស៊ីង់ - ប្ញាវតែស ទីប្រឹក្សានៅក្រសួងឃោសនាការជាតិ និងអស់លោកជាសមាជិកនៃអង្គ

ទូតបរទេសប្រចាំប្រទេសកម្ពុជាគឺ អ្នកឧកញ៉ានីធិលោក ម៉ាវធិន-ហ៊ីវ្ស នៅស្ថានអគ្គទូតអាមេរិកាំង, លោកលេខាធិការនីធិអនុព័ន្ធនៃស្ថានអគ្គភាជទូតជប៉ុន, លោកកុងស៊ុលនៃប្រទេសចិន, លោកស្រី-ប៉ាម នាយរោងាអនុព័ន្ធនៃគណៈកម្មការអន្តរជាតិប្រទេសឥណ្ឌូជាដើម ព្រមទាំងឥស្សរជនជាតិខ្មែរទាំងឡាយ មានលោក សឺន-សាប់ អតីតភូឈួយទីស្តីការរដ្ឋមន្ត្រីក្រសួងសិក្សាធិការ, លោក ស៊ុន រ៉ាន់ សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ, លោក ឌ-ជាវលី, លោក បេ-យាន មួយអន្លើដោយពពួកពុទ្ធបរិស័ទជាតិ យៀកណាមនិងជាតិខ្មែរជាច្រើនរូបទៀត ដែលយើងសូមអភ័យទោសដោយពុំបានរៀបរាប់នាមឲ្យសព្វគ្រប់ក្នុងទីនេះ ។

និយាយដោយរួបរួមគឺថា នៅវេលានោះ មានបណ្តាជនកុះករប្រជ្រៀតគ្នាអើតកវែងកខ្វី ទាំងក្នុងព្រះវិហារ និងក្រៅព្រះវិហារ ដើម្បីចង់ស្គាល់ ចង់ឃើញនូវកុលបុត្រចម្លែក ១ រូបគឺសាមណេរអានន្ទៈ ជាជាតិបារាំងវិសេសដែលទើបនឹងចូលមកគាន់តែជាសមណៈ

នៅប្រទេសកម្ពុជាយើងជាលើកដំបូងបង្អស់ ។

ក្នុងពេលបញ្ចប់ហើយ, សាមណេរអានន្ទៈបានថ្វាយសុន្ទរកថាជាភាសាបារាំងសូមអរគុណចំពោះគណៈសង្ឃមានសម្តេចសង្ឃនាយកជាប្រធាន ដែលបានទទួលការៈកិច្ចពិធីបញ្ចប់ព្រមទាំងចំពោះឥស្សរជនទំាងមិត្តនៃព្រះពុទ្ធសាសនាទាំងអស់ដែលបានធ្វើតទុកាសអញ្ជើញមកជួយអបអរសាទរបំពេញកិត្តិយសជាក្បៀវកិច្ចពិធីនេះដោយស្មោះសរ ។

លុះចប់កិច្ចនេះសព្វគ្រប់ហើយ, គេបានរៀបដំណើរគេសដ្ឋៈដោយបរិយាកាសយ៉ាងរីករាយចំពោះក្បៀវជាបញ្ជិតនឹងគ្រហស្ថទៅពីបរិវេណខាងមុខព្រះវិហារជាកិច្ចបង្ហើយបុណ្យត្រឹមប៉ុណ្ណោះ ។

ឯប្រវត្តិរូបសង្ខេបនៃសាមណេរអានន្ទៈនោះ, សូមអស់លោកអ្នកអានជ្រាបតាមសុន្ទរកថាដែលលោកព្រះគ្រូសង្ឃសន្តាប៉ុណ្ណ-សុម្ភាវបានប្រែសម្រួលមកពីភាសាបារាំង ហើយដែលយើងសូមចុះផ្សាយដូចតទៅនេះ ។

" ខ្ញុំព្រះករុណា, អាត្មាភាព សូមថ្វាយអំណរគុណដ៏ជ្រាលជ្រៅចំពោះសម្តេចជាព្រះសង្ឃនាយកគណៈមហានិកាយនិងព្រះថេរានុត្ថេរគ្រប់អង្គ, ទ្រង់, ឯកឧត្តមរដ្ឋមន្ត្រីនៃព្រះរាជរដ្ឋាភិបាល, ឯកឧត្តមសមាជិកនៃអង្គទូតព្រមទាំងអស់លោកអ្នកជាឥស្សរជនជាតិវិទូនិងបរទេស, ដោយរួបរួមគឺចំពោះពុទ្ធមាមកជនទំាងមិត្តនៃព្រះពុទ្ធសាសនាដែលមានមេត្តាជួយបំពេញកិត្តិយសដ៏ប្រសើរដល់ខ្ញុំព្រះករុណាអាត្មាភាពក្នុងពិធីនេះ។

ខ្ញុំព្រះករុណាអាត្មាភាព ពុំបានប្រើវោហារវិលបរទាយយកមកអធិប្បាយហេតុផលប្រគេន-ថ្វាយ-ជូនក្នុងពិធីនេះទេ ។ ហេតុនៃផ្សះនេះមានតែម្យ៉ាងហើយជាសេចក្តីពិតឥតបំផ្លើស ដែលបើកបង្ហាញនូវចិត្តគំនិតរបស់ខ្ញុំព្រះករុណា អាត្មាភាពប្រគេន-ថ្វាយ-ជូនឲ្យបានជ្រាបច្បាស់ដូចតទៅនេះ

ខ្ញុំព្រះករុណា, អាត្មាភាព មានកំណើតនៅប្រទេសជាំាង បានចំរើនវ័យវឌ្ឍនៈធំឡើងក្នុងមជ្ឈដ្ឋានកម្មកររាស្ត្រមធ្យម, មាតាបិតាពុំមែនជាអ្នកគាំទ្រសាសនាគ្រីស្តទេ ជាមជ្ឈតត្តកបុគ្គលសុទ្ធសាធ គឺជាអ្នកឥតប្រកាន់សាសនាណាមួយឡើយ ។ ពាក្យហេតុនេះ បច្ចេមវ័យរបស់ខ្ញុំព្រះករុណា អាត្មាភាពក៏បានតទ្ធឹងទៅក្នុងមជ្ឈដ្ឋានប្រាសចាកការប៉ះពាល់សាសនាណាមួយដោយពិត ។ ខ្ញុំព្រះករុណា អាត្មាភាពពុំមានទោមនស្សទេព្រោះការនេះថែរជាទស្សនៈយ៉ាងបរិសុទ្ធក្នុងដីវភាពដ៏ជ្រះស្រឡះចាកការស្រវ៉ាំងស្រវ៉ាក់ន្តច្រឡំគ្រប់យ៉ាង ។

ចាប់តាំងពីអាយុគំរប់ ២០ ឆ្នាំ ឥរិយាបថអំពើពុលឈប់សិក្សាមក, ខ្ញុំព្រះករុណា អាត្មាភាព ក៏បានហាត់រៀនសង្កេតត្រួសៗនូវសាសនាធំៗ ហើយបានទាក់ជាប់ចិត្តនៅចុងក្រោយបំផុត ដែលយើញមានតែមួយប៉ុណ្ណោះ បើនិយាយដោយចំពោះតែព្រះពុទ្ធ - សាសនា ។

ព្រះពុទ្ធសាសនាពុំមែនដូចជាសាសនាដទៃ ដែលប្រើនជាលទ្ធប្រើអាគារបង្ហូរនោះទេ តាំងពុំមែនជាជំនឿឥតហេតុផលផង គឺពេញជាតបធម្ម, តាមសេចក្តីយល់របស់ខ្ញុំព្រះករុណា អាត្មាភាព គឺជារបៀបនៃការសិក្សា ដែលមានទំនងដូចជាវិទ្យាសាស្ត្រ សម្រាប់ដុសខាត់ចិត្តឲ្យបរិសុទ្ធផូរផង់ ។

ហេតុតែមួយយ៉ាងនេះឯងហើយ ដែលនាំឲ្យខ្ញុំព្រះករុណា អាត្មាភាព មិនជ្រើសយកជំនឿ នឹងលទ្ធដទៃ ត្រឡប់មកដឿកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ ។ ខ្ញុំព្រះករុណា អាត្មាភាព បានពាយករមើលសៀវភៅតាំងច្បាប់ពុទ្ធសាសនាជាច្រើន ទើបកើតគំនិតយ៉ាងខ្ជាប់ខ្ជួនមួយឡើងថា ត្រូវចេញមកកាន់បូពាទិស រស់នៅក្នុងទីនេះ ព្រមទាំងសង្កេតមើលនូវដីវភាពរបស់ប្រជាជនពុទ្ធសាសនិក ដើម្បីនឹងយកជាបែបបទដែនសិក្សា ព្រមទាំងប្រតិបត្តិតាមវិធីនៃប្រជាជនទាំងនេះ ដំណាក់ការស្រាវជ្រាវរកផ្លូវចេះដឹងប្រយោជន៍នឹងបណ្តុះបញ្ញាឲ្យបានសម្រេចផល ដើម្បីនឹងផ្សាយនូវសុភមង្គលបំពោះសព្វសត្វទាំងអស់ ។

នេះតុំមែនជាការដើរផ្លូវព្រៃដ៏អស្ចារ្យមួយឬ ? ចំពោះអ្នកដែលឆ្ងល់ព្រាន់នឹងដីវភាព ខាងសម្ភារនិយមនឹងជំនឿថ្មី ដែលឥតផលប្រយោជន៍ ហើយទិស្រាវជ្រាវរកទៅគឺយើញជាក់ថា មានតែវិបស្សនាភាវនាក្នុងព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ដែលប្រកបដោយតម្លៃពិតប្រាកដ ។

គឺហេតុតែមួយយ៉ាងហ្នឹងឯង ដែលបណ្តុះបំណងខ្ញុំព្រះករុណា អាត្មាភាពឲ្យចង់ស្វែកដណ្តប់កាសាវពស្ត្រ ដែលជាមគ្គាបាយដ៏ល្អតែមួយក្នុងការប្រតិបត្តិនឹងការសម្រេចខាងផ្លូវវិបស្សនាភាវនា ដើម្បីឲ្យបានទៅជាបុគ្គលមួយរូប ដែលឥតទ្រព្យសម្បត្តិ ឥតមានឋានៈវិជ្ជាខ្ពង់ខ្ពស់ដ៏អាចនៅជាសុខសប្បាយបាន ។

ខ្ញុំព្រះករុណា អាត្មាភាព សូមបញ្ចប់សេចក្តីនេះ ដោយសូមថ្វាយនូវអំណរគុណចំពោះអស់លោកអ្នកពាជការ នៃព្រះរាជអាណាចក្រខ្មែរឯកពាជ្យ ដែលបានអនុញ្ញាតឲ្យខ្ញុំព្រះករុណា អាត្មាភាពបានសម្រេចផ្សេងៗដោយងាយ ហើយដែលផ្តួចផ្តើមឲ្យកើតមានពិធីបុណ្យនេះឡើង ។ ខ្ញុំព្រះករុណា អាត្មាភាព សូមថ្វាយអំណរគុណក្នុងទីនេះ ចំពោះលោកវេជ្ជបណ្ឌិតប៊ី-ហ្សត៍ ដែលជាសមាជិកទេសិក: (ជាតិបារាំងដូចគ្នា), លោកស៊ុន-ង៉ាន់ សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ និងលោក ស៊ុន-សាច់ អតីតនៅហ្វាយខែត្រ ទាំងជាអតីតកូឈួយរដ្ឋមន្ត្រីក្រសួងសិក្សាធិការជាតិជាដើម ដែលបានជួយឧបត្ថម្ភចាត់ចែងពិធីបុណ្យបុសដ៏ទុក្ខារិកនេះ ។

ខ្ញុំព្រះករុណា អាត្មាភាព មានអំណរណាស់ដោយបានសង្កេតឃើញលោក មាវឌិន-ហ៊ីស្ស រដ្ឋទូតនៅស្ថានឯកអគ្គរដ្ឋទូតអាមេរិក ដែលថាអ្នកមានសេចក្តីខ្នះខ្នែងក្នុងការស្វាបនាមេត្រីភាពរវាងអ្នកគាំពារព្រះពុទ្ធសាសនានៅប្រទេសកម្ពុជានឹងសហរដ្ឋអាមេរិក បាន

អញ្ជើញមកក្នុងឱនេះ ។

នៅទីបំផុត, ខ្ញុំព្រះករុណា អាត្មាភាព សូមប្រគេន-ថ្វាយ-ជូន នូវពរតាមគន្ធព្រះពុទ្ធសាសនាដ៏ស្មោះចំពោះពីដួងហឫទ័យវត្ថុថា :

សូមសម្ពុច, ព្រះថេរានុត្ថេរៈ, ទ្រង់, ឯកឧត្តមនឹងអស់លោក-អ្នកគ្រប់រូប ជាន់ប្រកបដោយសុខភាពនឹងសន្តិភាពអស់កាលជាអង្វែងតរៀងទៅ ។"

ញ. សឿង

★

★ ★

បុណ្ណាកុមារ (ត)

ជាការប្រសើរណាស់, លោកមេទ័ព ក្រោយពីបានរួមពិធីបុណ្យព្រះពរជាតិសេកហើយ, នៅបានប្រកបកុសលក្នុងការបូជាសពបុគ្គលអនាថា ហើយខួលចិញ្ចឹមក្មេងកំព្រាដែលគ្មានទីពឹងម្នាក់ទៀត ។ ក្មេងកំព្រានេះ លោកមេទ័ពបានដាក់ឈ្មោះឲ្យថា " បុណ្ណាកុមារ " លោកមេទ័ពគ្មានកូនប្រុសសោះ មានតែកូនស្រីម្នាក់ អាយុប្រមាណគ្នាទឹងបុណ្ណាកុមារនេះ ។ ក្មេងទាំងពីរនាក់មានវ័យចម្រើនធំឡើងក្រោមដំបូលផ្ទះជាមួយគ្នា ដោយសេចក្តីស្និទ្ធស្នាលឯបុណ្ណាកុមារជាក្មេងដែលចេះដាក់ខ្លួនមិនឆ្មើងឆ្មៃមានវាចាផ្អែមល្ហែមទន់ភ្លន់សុភាពរាបសា ហើយដំណើរទំនងជាអ្នកធ្លាតវាងវៃ ។ ដូច្នេះហើយបុណ្ណាកុមារទើបភ្លាយទៅជាទីស្រឡាញ់ពេញចិត្ត របស់លោកទេសយុទ្ធ មនុស្សដែលបុណ្ណាកុមារហៅថា "ឪពុក" យ៉ាងក្រៃលែង ។ ពិសេសជាងនោះទៅទៀត ភរិយារបស់លោកមេទ័ព ក៏គ្មានសេចក្តីរង្កៀសស្អប់ខ្ពើមកូនចិញ្ចឹមដោយសារតែមានត្រកូលថោកទាប គឺគ្រាន់តែជាចៅរបស់អ្នកសួមពានពីមុននោះ ត្រឡប់ជាជួយទៅវិញ, នាងស្រឡាញ់បុណ្ណាកុមារស្មើនឹងកុសលាកុមារីដែលជាបុត្រីតែមួយ ក្នុងត្រកូលនោះ

លោកមេទ័ពទេសយុទ្ធ ជាមនុស្សដែលស្រឡាញ់វិជ្ជាដោយគ្មានអ្វីប្រៀបស្មើបាន ព្រោះបុព្វបុរសរបស់លោកត្រូវប្រកបរឿយៗ ទាំងតែធ្លាប់ធ្វើជាមេទ័ពហានតាំងអស់នៅក្នុងទេវតិរ៉ានគរជាច្រើនដំណមកហើយ ។ ការគ្មានកូនប្រុសតវង្សត្រកូលនោះ ជាបញ្ហាដែលលោកមេទ័ពទេសយុទ្ធព្រួយបារម្ភជាខ្លាំង មិនលោះពេល លុះបានបុណ្ណាកុមារមកធ្វើជាកូនចិញ្ចឹម លោកនឹកត្រេកអរយ៉ាងក្រៃលែង ហើយទំយកចិត្តទុកដាក់ទំនុកបំរុងយ៉ាងពេញទំហឹង ដោយមានបំណងនឹងឲ្យបុណ្ណាកុមារជាអ្នកតវង្សត្រកូលតទៅ ។ សេចក្តីវាងវៃវៃឆ្លាតនឹងអង់អាចក្លាហ៊ានរបស់បុណ្ណាកុមារជាទីពេញចិត្តរបស់លោកមេទ័ពយ៉ាងខ្លាំង លុះបុណ្ណាកុមារមានអាយុសមល្មមដល់ការសិក្សា លោកមេទ័ព ក៏បានយកទៅផ្ញើនឹងអាចារ្យក្នុងសាលាវៀងដែលលេចឮល្បីល្បាញឈ្មោះជាទីបំផុត ក្នុងទេវតិរ៉ា

នគរ ។ បុណ្ណកុដារកំពុងសិក្សាស្វាធ្យាយជាន់ពូវតែ ជាឆ្នាំសិស្សគាំងធ្លាយក្នុងឆ្នាំថ្មាក់ តែលុះសិក្សាបានផុតថ្នាក់ទៅគឺនគរហើយ លោកមេទ័ពក៏បញ្ជូនឲ្យទៅរៀនបន្តវិជ្ជាជាន់ខ្ពស់ នៅសំណាក់អាចារ្យទិសាជាមោក្ខកុដ្ឋតក្កសិលា ។

បុណ្ណកុមារត្រូវធ្វើដំណើរចាកចេញពីទេវគិរីនគរទៅកាន់ក្រុងតក្កសិលាច្រើនថ្ងៃ ក្នុងទីបំផុតក៏បានត្រឡប់មកកាន់ទេវគិរីនគរវិញ ព្រមទាំងនាំយកនូវគំរិះវិជ្ជាផ្សេងៗ និងថ្មីដែលក្នុងវិជ្ជាអាវុធគ្រប់បែបជាឆ្នាំសិស្សទាំងឆ្លាយក្នុងសំណាក់អាចារ្យទិសាជាមោក្ខ ក្នុងសម័យនោះមកផង ។

២ ស្ថានសួគ៌នៃជីវិត

នៅពេលត្រឡប់ពីក្រុងតក្កសិលាមកកាន់ទេវគិរីនគរវិញនោះ បុណ្ណកុមារដែលក្នុងឆ្នាំនេះហៅថា បុណ្ណមាណព ជាទេពរើនធំឡើងពេញប្រុសពេញវាងហើយ ។ បុណ្ណមាណពមានដំណើរបែបគាត់ជាអ្នកអង់អាចមានៈអត់ធន់ មានរាងកាយជំដំបងខ្ពស់ស្រឡះដែលប្រកបដោយទឹកមុខញញឹមស្រស់ភ្លែកមុតស្នេហ៍ជាទីគួរចាប់អារម្មណ៍ដល់អ្នកដែលបានឃើញ ។ តែបើពុំណាជាប្រកបត្រមៅដោយចំណេះវិជ្ជាជាន់ខ្ពស់យ៉ាងណាក៏ដោយ បុណ្ណមាណពក៏មិនវាយប្រកាន់ខ្លួនសោះឡើយ អ្នកនៅតែសុភាពរាបសាចំពោះមនុស្សជាតិនឹងគោរពគោតក្រែងចំពោះលោកមេទ័ពទេសយុទ្ធនឹងលោកស្រីដែលឪពុកម្តាយចិញ្ចឹមដូចធម្មតា ដែលក្នុងខណៈនេះ លោកតាំងពីវានាក់នេះគាន់តែចាស់ៗក្នុណាស់ហើយរហូតដល់សក់ស្កូវឆ្មេញជាក់ថ្លាលផត - នោះ

តាលេបើចាស់ៗ គាន់តែជរាទ្រុឌទ្រោមចុះ ក្មេងៗតំចេះតែចម្រើនធំតាមលំដាប់ជាកម្ងោះក្រមុំឡើងនេះជាតារធម្មតាៗ កុសលាកុមារី ធីតាតែមួយរបស់លោកមេទ័ពទេសយុទ្ធនឹងលោកស្រី ដែលតាលបុណ្ណកុមារធ្វើដំណើរចាកចេញពីទេវគិរីនគរទៅសិក្សានៅក្រុងតក្កសិលា នៅជាតរុណីតូចៗនឹងមានលំអយ៉ាងផ្តាប់នោះឥឡូវនេះក៏បានចម្រើនធំឡើងពេញរូបពេញវាងជាក្រមុំដែរហើយ ។ នាងមានលំអស្រស់បំព្រងទៅតាមធម្មជាតិជាទីគួរចាប់អារម្មណ៍ក្រៃលែងដែលខុសគ្នាស្រឡះពីពួកនារីបច្ចុប្បន្ន ដែលមានលំអកើតឡើងពីការតុបតែងជួយបន្ថែមស្ថិតស្អាងដោយគ្រឿងវិទ្យាសាស្ត្រ នាងប្រៀបដូចជាបុប្ផជាតិរីកឡើងហើយក្រអូបឈ្ងុយឈ្ងប់សាយទូទៅពេញទេវគិរីនគរ ដែលអាចស្រូបទាញនូវពួកគមពាំងឆ្ងាយ មកពីទិសានុទិស តែថានាងកុសលានៅតែគាំងខ្លួនជាកល្យាណីដែលចិតនៅក្នុងនូវឪវាទរបស់មាតាបិតា មិនព្រមសំដែងខ្លួនឲ្យក្លេតក្លើនទៅតាមលំអដោយតាមគុណចំពោះពួកបុរសទាំងនោះឡើយ ហើយប្រការមួយទៀតនាងក៏បានបូជានូវសេចក្តីស្នេហាដោយទឹកចិត្តដ៏បរិសុទ្ធចំពោះបុណ្ណមាណពមនុស្សដែលនាងធ្លាប់ហៅ “បង” មកតាំងពីយូរ

យារត្រាដែលនាងនៅតូច ។ មកម្ល៉ះ ដូច្នេះ បាន
ជានាងមិនវិលវល់អើពើនឹងពួកភមពដែលចាំតែហើរមក
ធាបចំជញ្ជក់នូវកេសរត្បាថ្នាំនឹងខ្លួនូវសជាតិនោះ
សោះឡើយ ។

ចំណែកឯបុណ្ណមាណពនោះ ជាមនុស្សស្មោគគាព
ជាក់ខ្លួន ហើយតែងតែគិតថា ខ្លួនមានថាន:ត្រឹមតែ
ជាកូនបិតាក្មេសប៉ុណ្ណោះ ។ តាវដែលខ្លួនបានខ្លួល
ន្លូវិការទុបត្តម្ភំនុកបម្រុងមកពីតូច ។ រហូតដល់ធំហើយ
មានចំណេះវិជ្ជាបន្តិចបន្តួចនោះ ក៏ដោយសារតែសេច-
ក្តីមេត្តាករុណារបស់លោកមេទ័ពទេសយុទ្ធនឹងលោកស្រី
ប៊ុណ្ណោះ ដូច្នោះតារប្រព្រឹត្តិតម្លើងខ្លួនរហូតដល់ហ៊ាន
សៅប្រតិព័ទ្ធស្នេហាចំពោះបុត្រីរបស់លោកអ្នកមានគុណ
នោះ បុណ្ណមាណពតែងប្រកាន់ថាជាការអកតគ្គញ្ញូ
តែឯងតាល បុណ្ណមាណពក៏ដូចជាស្មុគ្រស្មាញក្នុងចិត្ត
ជាខ្លាំង តាលបើនឹកឃើញដល់តារចម្ងៃកមួយថែបទៀត
ដែលនាងកុសលាបានសំដែងន្លូវិការស្និទ្ធស្នាល
នឹងខ្លួនខុសប្លែកពីប្រក្រតី តាល់តែមិនអាចនឹងបដិសេធ
ខ្លួនបានថា ខ្លួននឹងមិនមានសេចក្តីស្នេហាចំពោះរូប
នាង ! ខ្លួនមិនអាចនឹងឃាត់ហាមន្លូវសេចក្តីស្នេហា
នោះបាន តាលបើធម្មជាតិបានសាងមកឲ្យខ្លួនហើយ
នោះតែក៏បេះតែទំសួគ្រាំអត់សង្កត់ខ្លុក ព្រោះតារជាក់
ខ្លួនឯង ។

តម្លោះម្ចាស់ទៀតដែលមកតាក់ទងនឹងនាងកុសលា
ដែរនោះគឺវិស្សកៈ តម្លោះដែលមានរូបរាងធំធំបងរ កូន
ប្រុសតែមួយរបស់សេនាបតីម្នាក់ដែលត្រូវជាសម្លាញ់
នឹងលោកមេទ័ពទេសយុទ្ធ ។ វិស្សកៈមានវ៉ាសនា
ល្អជាងអ្នកដទៃ ព្រោះចេញចូលស្និទ្ធស្នាលបានតាមចិត្ត
ក្នុងផ្ទះរបស់លោកមេទ័ពទេសយុទ្ធ ដោយលោកមេទ័ព
ពប់តនដូចកូនចៅរបស់លោក ហើយខ្លួកចិត្តថា នឹង
មិនប្រព្រឹត្តអំពើថោកទាបផ្សេងៗ ព្រោះបានសិក្សារៀន
សូត្រវិជ្ជាជាន់ខ្ពស់មានវិជ្ជា ពិជ័យសង្គ្រាមជាដើមមក
ពីច្រើនសំណាក់ហើយ ថែមទាំងបានចូលខ្លួនខ្លួល
តំណែងជានាយទាហានទៀតផង ។ តែវិស្សកៈមាន
សេចក្តីសង្ឃឹមយ៉ាងមាំថា នឹងបាននាងកុសលាមកជួប
សុខទុក្ខធ្វើជាគូវាសនាក្នុងអនាគតជាមិនខាន ។

បុគ្គលដែលវិស្សកៈខើសតែកជាពីបំផុតក្នុងនឹងគេ
គឺ បុណ្ណមាណព បុរសកម្ងោះដែលបានសិក្សាសៈម្រេច
វិជ្ជាការជាន់ខ្ពស់មកពីសំណាក់អាចារ្យទិសាបាមោក្ខនៃ
ក្រុងតក្កសិលានុះឯង ។ វិស្សកៈធ្លាប់បានសិក្សាមក
ពីសាលារៀននោះមុនដែលគួរតែជាមិត្តភក្តិនឹងគ្នាក្នុង
ថាន:ជាអ្នករួមអាចារ្យនឹងសាលារៀនជាមួយគ្នាតែត្រ-
ឡប់ជាវេរឆ្ងៃសស្អប់ខ្ពើមបុណ្ណមាណពទៅវិញ។ ការណ៍
គាងនេះ ព្រោះវិស្សកៈមេលងាយបុណ្ណមាណពថាជា
ចៅរបស់តាចាស់សូមគានមកពីមុនប្រការមួយ ហើយ
ប្រការមួយទៀតដែលសំខាន់បំផុតគឺ វិស្សកៈដឹងថា
បុណ្ណមាណពនឹងនាងកុសលាមុខជានឹងមានការខាត់
ខនគ្នាខ្លះមិនខាន ព្រោះនាងកុសលាស្និទ្ធស្នាលនឹង
បុណ្ណមាណពខុសប្រក្រតី ។ ពាសស័ង្ខាំងពីរនៅតង

គួហាតែមួយមិនបានយ៉ាងណា វិស្សកៈក៏តែងតែគិត ថាបុណ្ណមាណពក៏ជាបុគ្គល ដែលមិនគួរនឹងមានជីវិតរស់នៅរួមលោកជាមួយនឹងខ្លួនយ៉ាងនោះដែរ ។

លោកមេត្តិយសុទ្ធជាអ្នកមើលឃើញនូវការណ៍ផ្សាយ លោកពិនិត្យមើលឃើញថាកុសលាបុត្រីរបស់លោកនោះគ្មានបុគ្គលណាមួយសមនឹងធ្វើជាគូវាសនាដូចបុណ្ណមាណពឡើយ ។ លោកពេញចិត្តនឹងការជាក់ខ្លួនក្លួនចិញ្ចឹមលោកណាស់ រហូតដល់មានលាន់វាចានិយាយនឹងកិរិយាលោកថា នឹងមិនព្រមលើកកុសលាផ្សេអ្នកណាក្រៅពីបុណ្ណមាណពឡើយ ហើយបំណងនេះក៏ស្រេចគ្នានឹងកិរិយាលោកដែលស្រឡាញ់បុណ្ណមាណពដូចជាកូនចេញពីទ្រនាងដែរនោះ តែថាបំណងនេះក៏ដឹងចំពោះស្ងាមកិរិយាតែត្រឹមពីរនាក់ប៉ុណ្ណោះហើយបំណងនេះនឹងបានសម្រេច ឬមិនសំរេចនោះ អ្នកណាមួយនឹងដឹងបាន ព្រោះជារឿងអនាគត ?

វិជ្ជាបើកផ្លូវ

ជីវិតនៃមនុស្សយើងនេះ មានវិជ្ជាជាគ្រឿងបើកផ្លូវឲ្យដើរទៅរកឋានៈដ៏ខ្ពង់ខ្ពស់បាន ។ ជាន់វណ្ណៈឬជាតិត្រកូល ដែលគេជ្រាប់តែនាំគ្នាប្រកាន់នោះ មិនមែនជាកូនសោសម្រាប់បើកផ្លូវឲ្យដីវិតនៃមនុស្ស ធ្វើដំណើរការទៅកាន់សេចក្តីសុខចំរើនបានឡើយ ។ សុភមង្គលក្នុងជីវិតនៃមនុស្សយើងគ្រប់រូប ដែលនឹងបានសម្រេចនោះ ក៏ដោយសារតែវិជ្ជាការនៃមនុស្សយើង ដែលខំប្រឹងយកជ័យជំនះក្នុងធម្មជាតិដែរ ។ ដូច្នេះជីវិតនៃមនុស្សយើងបើគ្មានវិជ្ជា ក៏មិនខុសគ្នាពីសម្ភវៈដែលគ្មានវាសជាតិនៃអំបិលដែរ ហើយមនុស្សយើងនេះ បើគ្មានវិជ្ជាប្រចាំនៅក្នុងខ្លួនទេនោះ ក៏គ្មានពេលដែលត្រូវនឹងសង្ឃឹមនូវឋានៈនៃជីវិតដ៏ខ្ពង់ខ្ពស់បានដែរ បើទុកជាអ្នកនោះមានជាន់វណ្ណៈ ឬជាតិត្រកូលដ៏ខ្ពង់ខ្ពស់ក៏ដោយ ។ តែជាការផ្ទុយគ្នាទៅវិញ បើទុកណាជាអ្នកនោះកើតឡើងក្នុងជាន់វណ្ណៈ ឬជាតិត្រកូលដ៏ទ្រុតខ្សោយ ឬទន់ខ្សោយក៏ដោយ បើមានវិជ្ជាប្រចាំនៅក្នុងខ្លួនហើយ អ្នកនោះអាចកែប្រែជីវិតខ្លួនពីការទ្រុតខ្សោយ ឬទន់ខ្សោយនោះ ឲ្យឡើងទៅកាន់ឋានៈដ៏ខ្ពង់ខ្ពស់បាន ។

ព្រឹមបរាណីនៃទេវគិរីនគរ ក្នុងបុណ្យចំរើនព្រះជន្មវស្សានោះ ទឹងត្រូវចាត់ឲ្យមានការប្រឡងប្រជែងថ្នូរដៃចំពោះព្រះភក្ត្រព្រះពារ ដើម្បីជ្រើសរើសរកអ្នកដែលមានថ្នូរដៃឯកក្នុងការប្រឡងប្រជែងនោះយកមកធ្វើជាមេបញ្ជាការកងទ័ព ។ បណ្តាអ្នកមានថ្នូរដៃខាំងខ្លាយដែលបានទៅសិក្សាឬហាត់វិជ្ជាអាវុធពីសំណាក់ផ្សេង ។ គឺបានន៉ាមកកាន់ទេវគិរីនគរក្នុងទុតាសនោះ ដើម្បីប្រឡងថ្នូរដៃនៃខ្លួនក្នុងវិជ្ជាអាវុធផ្សេង ។ ដោយមានបំណងដល់ថានន្តរសក្តិជាមេបញ្ជាការនៃកងទ័ព ។

ការប្រឡងថ្នូរដៃក្នុងវិជ្ជាអាវុធនេះ មិនមែនមានបើកឲ្យតែអ្នកដែលមិនទាន់បានចូលធ្វើជាគហានប៉ុណ្ណោះឡើយ សូម្បីនាយគហានដែលជាមេក្រុម

មេកងកំអាចបូលប្រឡងថ្វៃដៃបានដែរ ដើម្បីនឹងបានឡើងតំណែងនឹងនាទីរបស់ខ្លួនឲ្យខ្ពស់ជាងដើម ។

វិស្សកៈក្រុមមេកងតាហានេះ មានសង្ឃឹមយ៉ាងមាំថា ខ្លួនបានឡើងថានន្តរស័ក្តិជាមេបញ្ជាការតាហាន ដូច្នោះវិស្សកៈខំហាត់សមវិជ្ជាអាវុធផ្សេងៗពាល់ថ្ងៃ ហើយរង់ចាំដល់ថ្ងៃដែលនឹងត្រូវបូលប្រឡងដោយការរសាប់រសល់ក្នុងចិត្ត ព្រោះវិស្សកៈបានដឹងមកពីមាត់លោកមេទ័ពទេសយ្ជ្ញទ្ធថា បុណ្ណមាណពកូនចិញ្ចឹមរបស់លោក គឺមានបំណងថា នឹងចូលទៅប្រឡងដណ្តើមយកតំណែងជាការមេបញ្ជាការកងទ័ពដែរ ។ វិស្សកៈសង្ឃឹមយ៉ាងខ្លាំងថា មុខជាគ្មានអ្នកណាអាចដណ្តើមយកជ័យជំនះ ក្នុងការប្រឡងថ្វៃដៃបានទេរ៉ៃយ ក្រៅពីរូបគេនោះ សូម្បីបើទុកជាបុណ្ណមាណពដែលបានសម្រេចខាងវិជ្ជាអាវុធនឹងយុទ្ធវិជ្ជាមកពីក្រុងតក្កសិលាក៏ដោយ ព្រោះបុណ្ណមាណពមានរូបពងតូចតាចជាងខ្លួន ។

ពិធីបុណ្យចំរើនព្រះជន្មវិស្សាក្នុងថ្ងៃនោះអធិអធមគគ្រឹងគ្រែងជាងសព្វឆ្នាំ ព្រោះមានមនុស្សដែលត្រូវចូលខ្លួនមកប្រឡងថ្វៃដៃក្នុងវិជ្ជាអាវុធជាច្រើនរហូតដល់ត្រូវចាត់ការជ្រើសរើសមុនពេលបីថ្ងៃ ។ ក្នុងពេលញាថ្ងៃនោះ ព្រះលានខាងមុខព្រះពជ្រកំផង ពេញទៅដោយពួកមនុស្ស ។ សម្លេងហ៊ោកញ្ជ្រៀវនៃពួកអ្នកគាន់ជើងចាំនសងខាង ក៏លាន់ឮឡើងយ៉ាងគឹកកង អ្នកខ្លះស្រែកច្រៀង, ខ្លះចាក់ក្បាច់, ខ្លះញាក់មុខមាត់, ខ្លះអរ, ខ្លះភ័យ ជំនួសមនុស្សព្រមទាក់ដែលកំពុងតែប្រឡូកគ្នា ដែលខ្លួនគាន់ដើងរៀងៗខ្លួន ។

បុណ្ណមាណពបានឆ្ងងផុត នូវគូប្រឡងប្រជែងច្រើននាក់មកហើយ ទើបបានទទួលចុះឈ្មោះ ដើម្បីចូលប្រឡងប្រជែងថ្វៃដៃចំពោះព្រះភក្ត្រនៃព្រះពជ្រ ។ ឯវិស្សកៈគឺជាណ្តើមយកតំណែងជាមេបញ្ជាការកងទ័ពបាន តែត្រូវនៅប្រឡងម្តងទៀតនៅចំពោះព្រះភក្ត្រព្រះពជ្រ ដើម្បីការពារតំណែងនោះទុកឲ្យបាន បើសិនជាចាញ់ក៏ត្រូវត្រឡប់ទៅគាន់តំណែងជាមេកងដូចដើម ។ វិស្សកៈសង្ឃឹមជាក់ក្នុងចិត្តថា ខ្លួនទឹងត្រូវបានបូលប្រឡងថ្វៃដៃជាមួយនឹងបុណ្ណមាណព ហើយមុខជាមានជ័យជំនះដោយពិតប្រាកដ ព្រោះវិស្សកៈពិនិត្យឃើញច្បាស់ថា បុណ្ណមាណពនោះស្ទាត់ជំនាញតែខាងវិជ្ជាគុណជាវប្បុណ្ណោះ ឯថ្វៃដៃខាងលំពែងវិញនៅខន់ខ្លាយជាងខ្លួនច្រើនណាស់ ប្រសិនបើនឹងប្រឡងអ្នកដែលជ្រើសរើសអាវុធកំមុខជានឹងយកលំពែងជាមិនខាន ដែលវិស្សកៈស្ទាត់ជំនាញជាងវិជ្ជាដទៃ ។ នៅពេលយប់មុនដែលនឹងចូលទៅប្រឡងថ្វៃដៃដណ្តើមយកជ័យជំនះចំពោះព្រះភក្ត្រព្រះពជ្រ បុណ្ណមាណពបានចេញទៅអង្គុយតែម្នាក់ឯងនៅលើដើងម៉ាថ្កងសួនច្បារខាងក្រោយផ្ទះ ។ បុណ្ណមាណពបានបណ្តាយឲ្យចិត្តក្ខួចនឹក ទៅដល់សភាពខាងដើមនឹកដល់ថានៈក្នុងវ័យកុមារនៃខ្លួនដែលគ្រាន់តែជាទៅរបស់

តាចាស់សូមទាន ដែលតែងតែគ្រាច់រង្គាត់ទៅតាមច្រកល្អកនិគមជនបទផ្សេង ។ មិនដែលស្គាល់មុខផុតម្ដាយយ៉ាងណា នៅឯណា ទឹកភ្នែកដែលខ្ជិនមិនចង់ឲ្យចេញនោះ ក៏ចេះតែហូរចេញច្រោក ។ ដោយការតឹសត់ តែក៏ហាក់ដូចជាធូរស្រាលបន្តិចទៅវិញ ក្នុងពេលដែលទឹកដល់ការដែលលោកមេទ័ពទេសយុទ្ធ អ្នកមានចិត្តសប្បុរស បានរើសយកមកបិញ្ចឹមហើយថ្នាក់ថ្នមបីបាច់ថែរក្សាស្រឡាញ់ដូចជាកូនបង្កើត ព្រមទាំងទុកបំរុងផ្សេងៗទាល់តែមានសមត្ថភាព អាចចូលទៅប្រឡងប្រជែងថ្វីដៃជណ្ដើមយកតំណែងនៃតាហានដ៏ខ្ពស់ក្នុងពេលថ្ងៃស្អែកនេះ ។ ឫណាមាណាពទឹកដល់រង្វង់មុខញញឹមស្រស់ នៃភុសលាធីតា ហើយដកដង្ហើមវែងៗ បញ្ចូលកូនក្រអូបនៃផ្ការីកសេចក្ដីសុខនៅក្នុងសួតដោយទឹកមុខសួតស្រស់ថោនហាក់ដូចជាមានទាំងទុក្ខទុនទឹងសុខនៅក្នុងខ្លួន ។

ពេលនោះ ព្រះចន្ទពេញវង់រះអណ្ដែតឡើងលើនភាល័យ បំភ្លឺសត្វលោកគ្រប់សាកដុំពពកជាមន្ទិល ។ ឫណាមាណាពងើយមុខរចោលភ្នែកក្រឡេកមើលព្រះចន្ទហើយដាក់ភ្នែកមកមើលខ្លួនឯងវិញ ហើយរំពឹងគិតក្នុងចិត្តមមែព្រមទាំងបរញ្ជាសមេធតិច ។ ថា

ឱ ! ព្រះចន្ទអើយ ! លោកមានពន្លឺភ្លឺស្រែទន់ត្រជាក់ធ្លុះបំភ្លឺមកលើខ្ញុំ ។ ក៏ដូចជាទន្យាយសែនអត្ថ ដែលទទួលន្ទរពន្លឺនោះមិនបាន ព្រោះជាន:របស់ខ្ញុំនៅឆ្ងាយណាស់ !

ខណៈនោះ ឫណាមាណាពដូចជាក្ងាក់ខ្ជូនត្រើតនឹងសម្ងួនដ៏ស្រួយឆ្ងាយដែលឮឡើងនៅខាងក្រោយខ្នងប្រហែលគ្នានឹងសម្ងួនខ្លឹប ជាសម្ងួនៃនាងកុសលាដែលឈរនៅទីឆ្ងាយបំផុតនឹងដើមអសោកក្បែរដីងម៉ានោះ ហើយនាងកុសលាមកលួចដែលឈរនៅពីក្រោយណានោះ ឫណាមាណាពក៏មិនបានដឹងដែរ សម្ងួននោះនិយាយថា

“ ទន្យាយអើយ ! ទន្យាយឯងមិនមែនជាអក្ខរដល់ទៅថ្នាក់ទទួលយកន្ទរពន្លឺព្រះចន្ទ មិនបាននោះទេ ព្រះចន្ទមិនមែនជាចិត្តអាក្រក់ដូចទន្យាយនោះទេ ” ហើយម្ចាស់សម្ងួនក៏សើចព្រមទាំងឈានដើរចេញមកពីទីឆ្ងាយតម្រង់មកកាន់ដើងម៉ាដែលឫណាមាណាពកំពុងអង្គុយ

ឫណាមាណាពប្រញាប់ប្រញាល់ក្រោកឈរឡើងដោយសេចក្ដីគោរពចំពោះភេទផ្ទុយគ្នានឹងជាធីតារបស់អ្នកមានគុណលើខ្លួន ។

“ បងឫណា: ! បងឫណា:ក្រោកធ្វើអី ! អង្គុយទៅវិញ ! ” នាងកុសលានិយាយថា “ តាំងពីពេលដែលបងត្រឡប់ពីក្រុងតក្កសិលាមកវិញ កំដូចជាមានឧស្ស័យផ្ទាស់ប្ដូរទៅច្រើនណាស់ ហើយមិនដែលបាននិយាយគ្នាទៅនឹងខ្ញុំសោះ ចេះតែគេចមុខពីខ្ញុំមិនដឹងជាព្រោះហេតុអីទេ តែខ្ញុំស្មានមើលទៅប្រហែលជាបងនឹកវេលឹកដល់នារីនៃក្រុងតក្កសិលាហើយមើលទៅបានជាបងចេះតែស្ងប់ស្ងុតមិនព្រមនិយាយលេងនឹងខ្ញុំ

នោះ ។

"ទេអូន!" ប៉ុណ្ណាមាណពឆ្លើយ "បងឥតនឹកដល់អ្នកណាទេ!"

"មិនមែនទេ" នាងកុសលានិយាយ "ខ្ញុំមិនដឿទេ! ព្រោះគេប្រើនតែនិយាយថា នារីនៅក្រុងតក្កសិលាស្អាត ។ ណាស់"

"អត់មានសោះហើយអូន" ប៉ុណ្ណាមាណពដោះស្រាយ "បងឥតមាននឹកនាដល់អ្នកណាក្រៅពី..." ដល់ត្រង់នេះដូចជាមានអ្វីមកទប់ហើយក៏បន្តទៀតថា "បើខុកជាបងទៀដល់ស្ថានសួគ៌ក៏ដោយ ក៏បងឥតនឹកនាអ្វីក្រៅពីមនុស្សដែលបងធ្លាប់បាននៅក្នុងផ្ទះជាមួយគ្នា ញ៉ាំបាយជាមួយគ្នា ដើរលេងជាមួយគ្នាដែរ តែដូចអូនឃើញស្រាប់ហើយ តាំងពីបងត្រឡប់ពីក្រុងតក្កសិលាមកវិញ បងមិនសូវមានពេលទំនេរសោះ បងត្រូវទៀហាត់គុំរោអាវុធជានិច្ច ព្រោះលោកឧត្តុកត្រូវការនឹងឲ្យបងចូលទៀប្រឡងថ្វៃដៃដណ្តើមយកតំណែងនៃមេញ្ញាការាហានក្នុងថ្ងៃបុណ្យចំរើនព្រះជន្មវស្សាស្អែកនេះឲ្យបាន តែណ្ហើយចុះភូសលា! កុំអូនមកវិលវល់នឹងបងធ្វើអីសូមអូនៈឡើងទៀផ្ទះវិញទៀ យប់ជ្រៅណាស់ហើយ"

"ទេ! ខ្ញុំមិនឡើងទៀទេ! បងប៉ុណ្ណៈនេះដូចជាវៃបូកណាស់ គេមកយកឈ្នះអាកាសនឹងមើលព្រះចន្ទលេងផងមិនបានឬ?" នាងកុសលានិយាយញញឹម "ឬក៏បងស្អប់ខ្ញុំណាស់មិនចង់ឲ្យខ្ញុំមកអង្គុយនិយាយលេងផង?"

"គ្មានស្អប់ខ្លឹមអីទេអូន" តែបើពួកបាវស្រីរាល់យើញ នាំឲ្យរាមាក់ងាយ"

"ស្រេចតែរាទៅ" តែនេះ ជារឿងមួយបែបទៀតទេដឹង ដែលបងប៉ុណ្ណោចង់គេចវេះកែខ្លួន មិនចង់និយាយលេងនឹងខ្ញុំដូចគ្រាមុនៗ ទេដឹង"

"ទេ! ទេអូន! អង្គុយមកអូន! មានរឿងអីដែលបងនិយាយលេងនឹងបងក៏និយាយមកចុះ"

នាងកុសលាអង្គុយចុះដិតបុរសកម្ងោះដែលខ្លួនហៅគេថា "បង។" ហើយសួរថា

"ព្រឹកស្អែកនេះបងមានសង្ឃឹមថានឹងដណ្តើមយកតំណែងជាមេបញ្ជាការាហានបានឬទេ?"

"បងគិតថា ត្រឹមតែតំណែងមេកងប៉ុណ្ណោះ តំលួមនឹងបងទៀហើយ បងមុខជានឹងស៊ូថ្វៃដៃវស្សភៈមិនបានទេ គេថ្វៃដៃពូកែជាងបងច្រើនណាស់ ហើយម្យ៉ាងទៀតគេក៏ជា..."

"ជាអី?"

"វស្សភៈជាគាហានមានថ្វៃដៃខ្លាំងពូកែនឹងមានសក្តិយសខ្ពស់ជាងបងឲ្យណាស់ហើយគេជាកូនអ្នកធំទៀត បងគិតថា មនុស្សដូចបងនេះមិនគួរនឹងលើកដំកើងខ្លួនឲ្យខ្ពស់ស្មើនឹងគេទេ បើខុកជាបងដណ្តើមយកតំណែងជា..."

"បងប៉ុណ្ណ!" នាងកុសលានិយាយកាត់ខ្លើងព្រមទាំងសម្លឹងមើលមុខប៉ុណ្ណមាណពដូចជាចង់ទឹង ។

ពន្ធ្រីព្រះចន្ទ ឮថាន សាចដះមកត្រូវឆ្អឹងដំមុខនាងដោយពាណិ
ទឹកច្រាក់ ហាក់ដូចជាជួយធ្វើឲ្យលំអនៃនាងលេច
ឡើងជាងមុនទៀត ។ ប៉ុណ្ណាមាណពដូចទ្រឹងទៅ
មួយស្របក់ទើបដកដង្ហើមវែង ។

" បងត្រូវយកឈ្នះសង្រ្គាមឲ្យបាន នេះជារឿង
នៃការប្រឡងថ្នូរដៃដោយឡែក មិនមែនជារឿងនៃការ
ប្រឡងយសសក្តិពូជពង្សត្រកូលទេបងត្រូវដណ្តើម
យកតំណែងជាមេបញ្ជាការមកហានឲ្យបាន ខ្ញុំនឹងទៅ
តាមសោកនុពុកទៅមើលក្នុងថ្ងៃស្អែកនេះ ហើយខ្ញុំចំ
បង់ស្រែនបួងសួងឲ្យបងដណ្តើមយកតំណែងនោះឲ្យ-
បានសម្រេច ឲ្យសមបំណងរបស់សោកនុពុក ,,

" បងអរគុណនឹងអូនឯងណាស់ហើយ បងនឹង
ខំប្រឹងប្រែងមើល ក្រែងសោបានសម្រេចតាម
បំណងនុពុក "

" ហើយជាបំណងរបស់ខ្ញុំផង ,, នាងកុសលា
ពោលជូនឡើងទៀត " សូមបងខំសាងកិត្តិយសនឹង
ជាន:របស់បងឲ្យមែនទែនឲ្យគាល់តែបានសម្រេចខ្ញុំនឹង
ជួយត្រេកអរផង . . . តែសូមបងចាំទុកចុះថា ទន្យាយ
ណា មិនមែនសុទ្ធតែអត្ថាទៅតាំងអស់នោះទេ គង់
មានទន្យាយខ្លះមិនអត្ថា ហើយព្រះចន្ទមុខជានឹង
អាណិតអាសូរក្នុងថ្ងៃណាមួយមិនខាន "

និយាយតែប៉ុណ្ណោះ នាងកុសលាក៏លាបុណ្ណ-
មាណពហើយឡើងទៅលើផ្ទះទៅ

(នៅមានត)

បញ្ញត្តន្ត្រៈ (ត)

២៩៦- អ្នកច្រាជ្រ បើមានច្រាណាគឺជីវិតបិតនៅ
ត្រឹមតែកងឹតប៉ុណ្ណោះទេ មិនសមបើបរិភោគរបស់ណា
វៀលមិនគួរបរិភោគទេ បើពោលដោយវិសេស របស់
នេះតិចណាស់ ហើយជាហេតុនាំឲ្យលោកទាំងពីរ
វិនាស ។

ប៉ុន្តែ អំពើដែលបងធ្វើនេះជាគ្រឿងនិទស្សន៍
ស្តែងឲ្យឃើញថាខ្លួនជាសត្វមានត្រកូលខ្ពស់, ព្រោះ
សប្បុរសលោកពោលថា ៖

២៩៧- ព្រោះតែអំពើប្រសើរនេះឯងបានជា
ព្រះរាជាទាំងឡាយតែងតែសង្គ្រោះពួកជនដែលមាន
ត្រកូល ព្រោះថាជនមានត្រកូលទាំងឡាយនេះតាំងពី
ខាងដើម កណ្តាល ដល់អវសាន មិនដែលធ្វើអ្វី
ឲ្យប្រែប្រួលឡើយ ។

បើដូច្នេះ បងចៀសចេញពីមុខខ្ញុំចេញ ខ្ញុំនឹង
ចូលទៅគោរពជំរាបលោកម្ចាស់ឲ្យបានជ្រាប ។ លុះ
ធ្វើយ៉ាងនេះហើយ ខ្លាក៏ចូលទៅក្រាបប្រណិប័តន៍
សីហៈដោយសេចក្តីគោរពដ៏ក្រៃលែង ទើបនិយាយ
នឹងសីហៈមហោត្តដៈថា: " លោកម្ចាស់! សូមលោក
ម្ចាស់ធ្វើច្រាណាយាត្រាដោយច្រាណគឺជីវិតខ្ញុំជាទេនេះ
ចុះ សូមលោកម្ចាស់ប្រទានទូរវាសជ្ញានដ៏ជានិច្ចកាល
ហាន សូត៌ឲ្យខាន សូមឲ្យខ្ញុំជាទមានកេរ្តិ៍ឈ្មោះល្បី
ល្បាញនៅលើផែនប្រថពីនេះ សូមលោកម្ចាស់កុំមាន

ត្តំគោតញ្ញញ្ញើតឡើយ, ព្រោះថា ៖

២៩៨- ខ្ញុំបំរើធ្វើការងារ ដែលធ្វើតាមបង្គាប់ម្ចាស់ ដែលហាមស្ងាប់ដើម្បីប្រយោជន៍ម្ចាស់ តែងបាននូវៃសង្ឃានដ៏ជានិច្ចនៅក្នុងឋានសួគ៌ផង នូវកុន្លឹះឈ្មោះទុតិយទុតមនៅនាដែនវរណីនេះផង ។

កាលនោះ ទុដ្ឋភថនក:បានស្តាប់ពាក្យសត្វតាំងឡាយនិយាយរួចហើយគិតថា: "សត្វតាំងអស់នេះ និយាយពាក្យពិតពិរោះណាស់ ឯលោកម្ចាស់ក៏មិនសម្លាប់សត្វណាមួយសោះ, បើដូច្នេះខ្ញុំនឹងអាត្មាអញក៏ត្រូវចូលទៅនិយាយសំដែងស្វាមីក៏ត្តិចំពោះលោកម្ចាស់ដូចគេដែរ ដើម្បីឲ្យសត្វតាំង ៣ នេះពេញចិត្តនឹងអាត្មាអញផង" ។ គិតដូច្នេះហើយទុដ្ឋនិយាយទៀងថា: "នែបងតាំងឡាយ! បងតាំងអស់គ្នានិយាយពាក្យសច្ចៈពិរោះណាស់ ប៉ុន្តែបងតាំងអស់គ្នាមានក្រញ៉ាំក្រចកដូចៗគ្នាធ្វើដូចម្តេចនឹងឲ្យលោកម្ចាស់ស៊ីបងតាំងអស់គ្នាកើត ព្រោះថា ៖

២៩៩- នរជនណាគិតធ្វើសេចក្តីអន្តរាយដល់ជាតិរបស់ខ្លួនសូម្បីតែដោយចិត្ត គំនិតអាក្រក់តាំងឡាយនោះតែងកើតមានដល់នរជននោះតាំងនៅនាលោកនេះនឹងបរលោក ។

បើដូច្នេះ ចូរបងតាំងឡាយចៀសចេញពីមុខខ្ញុំទុក ជារឿងខ្ញុំចូលទៅគោរពជំរាបលោកម្ចាស់ឲ្យបានជ្រាបពីគំនិតខ្ញុំ ។ លុះនិយាយរួចហើយទុដ្ឋភថនក:ចូលទៅបិតនៅចំពោះសីហៈ លើកទុសកប្រណម្យហើយពោលថា: "លោកម្ចាស់! សត្វតាំងឡាយនេះ លោកម្ចាស់មិនគួរបរិភោគទេ សូមលោកម្ចាស់ធ្វើប្រាណយាត្រាដោយប្រាណគឺជីវិតខ្ញុំបាទចុះ ដើម្បីឲ្យខ្ញុំបាទបានផលនៅក្នុងលោកនេះ នឹងបរលោកនាយ, ព្រោះថា ៖

៣០០- បុគ្គលជាអ្នកធ្វើវិធីយញ្ញៈក្តី យោគីក្តី មិនបានដល់គតិដ៏ប្រសើរទេ ឯបុគ្គលដែលលះបង់ប្រាណគឺជីវិតដើម្បីម្ចាស់ ទើបបានដល់គតិដ៏ប្រសើរ គឺសគាពជាសេរីគាមាត្យដ៏ឧត្តម ។

លុះទុដ្ឋភថនក:ពោលយ៉ាងនេះ ស្ទើរតែមិនទាន់ផុតពីមាត់ផង សត្វតាំងឡាយមានខ្លានឹងចចកជាដើមចូលទៅចាប់ដណ្តើងយកទុដ្ឋនោះដែលក្នុងព្រៃនោះឥតមានភ័តភ័យសោះក្តាម ហើយបំបាត់ជីវិតក្នុងមួយរំពេចនោះ ។ លំដាប់នោះទុដ្ឋភថនក:ត្រូវបណ្ឌិតទាំងពួងតាំង ៤ នាក់ស៊ីជាអាហារអស់ទៅ ហេតុនោះហើយបានជាខ្ញុំ (សញ្ជីវក:) ពោលថា: "បណ្ឌិតទាំងពួងច្រើននាក់ដូច្នេះជាដើម (លេខ ២៨៨) ។

★ (មានតទៅទៀតនឹងផ្សាយចេញជាសៀវភៅ) ★

Internationale
Academy of Indian Culture
Nàgpur
India

ថ្ងៃទី៣០ ខែស៊ីហា ព.ស.២៤៩៨

សូមចំរើនពរមកលោកអធិបតីសមាគមមិត្ត

សាលាចាលី

សូមជ្រាប ។

ទស្សនាវដ្តីមិត្តសាលាចាលីឯក្បាល, ៨លេខភប់
តំណលេខពីរសែសបានផង, នៃខ្ញុំនេះនឹងអតីតខ្ញុំ,
ផ្ញើមកប្រគេនអាត្មានៅក្រោមការចាត់ចែងរបស់សមា-
គម អាត្មាភាពបានទទួលហើយដោយសោមនស្ស,
ទស្សនាវដ្តីនៅមាន ការភ្ញាំងភ្ញាត់ប្រើនណាស់ អំពី
ការបោះពុម្ពនឹងការកែរិញ្ញាសានៃអត្ថបទម្ហូយៗ។

ក្នុងទស្សនាវដ្តីនេះ មានសេចក្តីកងអត្ថបទខ្លះ
ខ្លះ បើតាមទស្សនៈ អាត្មាភាពថាមិនគួរចុះផ្សាំងអស់ទេ
ព្រោះមិនមែនធម៌អាចិ ឬអក្សរសាស្ត្រ ។ ឯសេចក្តី
កងអត្ថបទខ្លះនោះ គឺពាក្យថា "ពតិមាឯគ្គរជឺងខ្លះ
គ្គរគិតខ្លះ" ។ កងសំដីនេះមានសេចក្តីខ្លះជាកិច្ចការ
នយោបាយរបស់ឯកចាលសុទ្ធ ។ មនគួរនឹងយកមក
យោសនាកងទស្សនាវដ្តីទេ ជាការណីយរបស់តាសែត
ទេតើ ។

ម្យ៉ាងទៀត បើអនុញ្ញាតផ្សាំងបៃបហ្នឹង ជាទំ-
នាស់ដល់ចំណងដើងទស្សនាវដ្តីផងថា: "ធ្បាយបេញ
សាសនា-អក្សរសាស្ត្រ នឹងប្រវត្តិសាស្ត្រ" ។



ដល់ទៅផ្សាយចេញនយោបាយផងឯចឹង ត្រែងលោ
មានគេរកវឿង, បើមានគេរកវឿងហើយ ត្រែង
សមាគមពាក់កន្ទុយដោះសារ? ។

អំពីអត្ថបទកាសាចាលី ដែលសមាគមសុំស្នើ
យោបល់នឹងអ្នកអាននោះ តាមមតិអាត្មាភាពថា "គួរ
តែកុំខានផ្សាំសោះ, ចុះនេះត្រូវហើយ" ។ ពោះ
បើមិនត្រូវនឹងចំណងដើងទស្សនាវដ្តីក៏ដោយ ក៏នៅតែ
ត្រូវនឹងឈ្មោះទស្សនាវដ្តីដែរ ។ បើមិនមានអ្នកយល់
ប្រឹនគ្នាទេ ក៏នៅតែមានប្រយោជន៍សំខាន់ខ្លួនៅដែរ។

ម្យ៉ាងទៀត ការចុះនេះផ្សាំស្របតាមឈ្មោះទស្សនា
វដ្តីថា: "មិត្តសាលាចាលី" ផង ព្រោះការងារ
នេះដែលអាចកើតឡើងបាន គឺនឹកឃើញដល់ឧបការ
គុណនៃកាសាចាលី ដែលជាអាយុសង្ខារព្រះពុទ្ធ-
សាសនានៅប្រទេសជាទីស្រឡាញ់របស់យើង។ ហេតុ
នេះតាមសេចក្តីយល់ឃើញរបស់អាត្មាភាពថា: "ក្នុង

ដល់ត្រឡប់មកប្រទេសខ្លួនវិញ ស្រាតចោលពាំងអស់ស្បែកសំពត់ចង្កត្រនៃវិញ ។ ឯសាសនាខ្មែតសោតគោះបីត្រូវប្តូរទុស ក៏ចេះតែគាន់ឲ្យគាល់តែឃើញស-ខ្មៅ ព្រោះគេថាធ្វើបែបនេះ ទើបអាចរកឥស្សរភាពរបស់ជាតិនិងសាសនាឃើញ ។

សង្ឃឹមថា លោកព្រមពាំងសមាជិកពាំងអស់សុខសប្បាយជាទេ ពាំងកិច្ចការងារគង់សមាគម ក៏បានចំរើនជាលំដាប់លំដោយ ។

ដោយមនោសញ្ចេតនាដ៏ខ្ពស់

ភិក្ខុ គួច-គីឡេង បឋមប្បញ្ញា

★

★ ★

ឯធានខ្ញុំ ។ (តបន់)

សត្វមៀមនោះមិនត្រាំសម្ងំនៅចាំដល់អស្តង្គតសិនទេ ស្រាប់តែហ៊ីរចេញទៅពាំងព្រឹកព្រហាម ។ គ្រានោះ វែកពាំងឡាយក៏ចោមរោម ហើយដេញចឹក-ខាំមៀមនោះដោយចំពុះ ពាល់តែសុះសាច់ ហើយធ្លាក់ចុះមកដល់ដីស្ទាប់ទៅ ។ ព្រះពាជាទ្រង់សាកសួរអាមាត្យម្នាក់ថា "ព្រោះហេតុអ្វី បានជាវែកពាំងឡាយដេញចោមរោមនូវសត្វមៀមនេះ?" អាមាត្យក្រាបទូលថា: "សូមទ្រង់ព្រះមេត្តាជ្រាស, ព្រោះសត្វមៀមនេះ បានចេញចាកទីលំនៅរបស់ខ្លួន មិនត្រូវកាល រមែងជួបប្រទះនឹងសេចក្តីទុក្ខបែបនេះឯង" ។

កតិដ្ឋកថា

អគាលេ ត្រាច់ចរ ទៅរុសកាល
តែងតែ បណ្តាល នូវក្តីទុក្ខ
ប្លុះបើ ចង់បាន នូវក្តីសុខ
ត្រូវលះ កាលល្មាក់ កុំប៉ស្តាយ ។

x x
x

៦) រឿងសត្វលាពាក់សែ្បកសីហៈ

កន្លងកាលកន្លះរំលងយូរណាស់ហើយ ពាណិជ
ម្នាក់បានយកលាឲ្យនាំអីវ៉ាន់ទៅលក់កន្លែងផ្សេង ។ ។
ពាណិជនោះបានទៅដល់ដំណាក់មួយ ។ គាត់ជាក់បង្ខិច
ទ្រព្យអំពីខ្នងលា ហើយបំពាក់សែ្បកសីហៈឲ្យលា
រួចលែងឲ្យដើរវាកស៊ីក្នុងស្រែស្រូវសាលី—ស្រូវទឹកយូរ
ទាំងថ្ងៃ ។ ថ្ងៃមួយក្រោយមក ពាណិជនោះឯង
បានចូលទៅសំណាក់ទៀបទ្វារនៃស្រុកមួយ ហើយឲ្យ
គេចំអិនអាហារព្រឹក (ជាតពាសៈ), ក៏បំពាក់សែ្បក
សីហៈនឹងសត្វលា រួចលែងឲ្យដើរវាកស៊ីក្នុងស្រែមួយ
ដូចមុនទៀត ។

អ្នកម្ចាស់ស្រែ ដោយសំគាល់ថាជាសត្វសីហៈ
ក៏ប៉ិនហិនចូលទៅជិតរួចរត់ទៅផ្ទះប្រាប់គ្នា ។ អ្នក
ស្រុកទាំងអស់បានកាន់យកអាវុធផ្សេងៗដែលសំលៀង
ហ៊ានមុត ហើយផ្គុំស្មេនវាយស្គរប្រកូកហៅគ្នាសំដៅ
ទៅកាន់ស្រែដែល (សីហៈបន្ទុំ)នៅកំពុងស៊ី ។ សត្វលា
ដោយខ្លាចស្ងាប់ក៏ស្រែកសម្រែកដូចជាសត្វលា ។ អ្នក
ស្រុកទាំងនោះដឹងច្បាស់ថា វាជាសត្វលាដូច្នោះ ក៏
វាយសត្វលាសំពងម្យាក់អស់ឆ្អឹងឆ្អែង ហើយក៏កាន់យក
សែ្បកសីហៈត្រឡប់ទៅវិញ ។

(ពាកសីហធម្មជាតក)

កតិដ្ឋកថា

ជាតិសត្វ ហៅកពាប, គាពហីនលក្ខណ៍
ពាក់សែ្បក សីហៈ យ៉ាងហ៊ុមហា
គង់តែ គេដឹង ដោយវាចា
តែងកាយ ត្រូវតែម្រាំ តាមមាឌអើយ ! ។

x x
x

៧. រឿងអធិករណ៍នៃក្អែកទាំងមៀម

ក្នុងកាលដែលកន្លងទៅហើយ ពួកមនុស្សក្នុង
បឋមកប្ប បានប្រជុំគ្នា ដើម្បីរើសយកបុរសម្នាក់
ដែលមានរូបស័ក្តិសមឲ្យធ្វើជាស្តេច ។ ឯពួកសត្វ
ចតុប្បាទ (សត្វដើរបួន) ក៏ប្រជុំគ្នារើសយកពពសីហ៍
ឲ្យធ្វើជាស្តេច ។ ពួកមច្ឆា (ត្រី) បានរើសត្រីឈ្មោះ
"អានន្ទៈ" ឲ្យធ្វើជាស្តេចពួកត្រី ។ លំដាប់នោះហ្វូង
សត្វបក្សី ក៏ជំនុំគ្នានៅឯហិមវន្តប្បទេសថា ឥឡូវនេះ
ពួកមនុស្សគេមានស្តេច ទាំងពួកសត្វចតុប្បាទ និងត្រី
ក៏គេមានស្តេចរបស់គេដែរ ។ ចំណែកយើងជាពួក
បក្សី គួរតែមានស្តេចដូចគេខើបសម, ដូច្នេះចូរអ្នក
ទាំងឡាយជ្រើសរើសរកបក្សីណាមួយ ក្នុងចំណោម
ពួកយើងដើម្បីតាំងឲ្យធ្វើជាស្តេចតទៅ ។

៨) កម្លាំងសាមគ្គី

ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ហៅព្រះញាតិទាំងឡាយមកហើយត្រាស់ថា "មហាវាជទាំងឡាយ, ទ្រង់ត្រូវជាព្រះញាតិរបស់តថាគត តបុរីជាអ្នកមានសាមគ្គីធម៌ស្មោះសរវាកគ្នាខើបប្រពៃ ព្រោះថាកាលបើព្រះញាតិទាំងឡាយ មានសេចក្តីព្រមព្រៀងស្មោះសរវាកគ្នា បច្ចាមិត្រទាំងឡាយ មិនអាចស្វែងរកនូវចន្ទោះគេសបានទេ, មិនបាច់និយាយទៅដល់ពួកមនុស្សផង សូម្បីតែរុក្ខាដែលឥតចេតនា ក៏ត្រូវមានសាមគ្គីនឹងគ្នាដែរ ។ ព្រោះថាក្នុងកាលកន្លងទៅហើយ ក្នុងហិមវន្តប្បទេស មានដើមសាលព្រឹក្សមួយដើម ត្រូវឲ្យលំយោនទាំងបត់បាក ។ ដោយការតូតផ្តុំចងចាប់គ្នា នៃព្រឹក្សាលតាវល្លិឯទៀតជារបើនដែលដុះនៅជិតដើមសាលព្រឹក្សនោះ ,មហាវាត (ខ្យល់ធំ) មិនអាចបក់បោកដើមឈើសូម្បីមួយដើមឲ្យរលំបានឡើយ គ្រាន់តែប៉ះបុងនឹងស្បែកបន្តិចបន្តួចប៉ុណ្ណោះ ។ នៅលើទីតូលមួយមានដើមឈើធំមួយដើម មានមែកនឹងបង្អៀបដាំ តែមិនចងកម្ចាំនឹងឈើទាំងឡាយដទៃ ត្រូវខ្យល់បោកបក់បោកមកលើរលើងទាំងឫស-តល់ រលំមកលើផែនដី ។ ព្រោះហេតុនេះ តថាគត សុំឲ្យទ្រង់ត្រាប់អង្គមានសេចក្តីព្រមព្រៀងស្មោះសរវាកគ្នាទៅវិញទៅមក កុំបីខាស់ខែងឬខ្វែងគំនិតគ្នាឡើយ ។

(ចាកក្កូធម្មជាតក)

ពួកបក្សីទាំងនោះ ក៏ជ្រើសរើសហើយបាន សម្រេចចិត្តយក "មៀម" ធ្វើជាស្តេច ។ ក្នុងបក្សីទាំងអស់នោះ មានបក្សីមួយបានសួរយោបល់របស់ពួកសត្វស្លាបទាំងអស់ គំរប់៣ដង ។ ក្នុងអនុស្សរនាជាគំរប់ ៣ ស្រាប់តែមានក្អែកមួយ ក្រោកឡើងនិយាយថា សូមអស់លោក-អ្នកបង្អង់សិន, ព្រោះក្នុងពេលអតិរេកមៀមនេះឡើងធ្វើជាស្តេច មើលៗទៅមុខរបស់គាត់នេះ ហាក់ដូចជាទឹង ដោយហេតុនេះ ពួកយើងដល់ក្រឡេកមើលទៅ ហាក់ដូចជាអំបិលដែលគេដាក់ចុះក្នុងអំបែងដ៏ក្តៅ ហើយយើងមុខជានឹងបែកបាក់គ្នាពុំខាន ។ ការដែលលើកមៀមនេះឡើងធ្វើជាស្តេច ខ្ញុំមិនពេញចិត្តទេ ។

(ចាកខ្លែកជាតក)

កតិឯពន្ធក៍

សត្វមៀម	អភ័ព្វ	ព្រោះបុណ្យតិច
ប្រទ័ងបាន	ធ្វើស្តេច	លើបក្សី
តែស៊ីយ	ដោយហេតុ	ក្អែកចង្រៃ
ដណ្តើម	ស៊ី	ឲ្យខកខាន ។
ហេតុនេះ	បានជា	មៀមនឹងក្អែក
កើតជា	ប្រកែក	គ្នាឥតស្រាន្ត
ខាស់ខែង	ខ្វែងចិត្ត	ឥតលស់ខាន
សន្តាន	បានដឹង	គ្រប់គ្នាហើយ ។

មហា-ហ៊ុយ-អ៊ួច

គតិធិពន្ធ៍

សេចក្តី	ព្រមព្រៀង	ជាកម្មាន
អាចបូល	តតាំង	បច្ចាមិត្រ
ឲ្យបាក់	ខូចខាត	រអាចិត្ត
លែងហ៊ាន	ប្រព្រឹត្ត	មើលងាយបាន ។
ដូច្នេះ	បងប្អូន	ជាតិខេមរៈ
ត្រូវមាន	សាម–	គ្គីគ្រប់ប្រាណ
ការពារ	សត្រូវ	ដែលរុកពន
ដល់រដ្ឋ	ភក្សាណ	របស់យើង ។

x

x x

៩) សប្បុរសដល់ផ្សេងសេចក្តីទុក្ខ

ព្រោះអសប្បុរស

នៅផ្លូវទៅភាន់នគរឈ្មោះខេដ្ឋនី, មានដើមត្រែក្រឹមមួយដើម ដុះនៅកងត្រៃព្រមួយ, មានសត្វបក្សីពីរគឺ ហង្ស១, កែក្អក១, នៅជាមួយគ្នា ។ ថ្ងៃមួយមានបុរសម្នាក់ធ្វើដំណើរតាមផ្លូវ ហត់អស់កំឡាំងដោយត្រូវកំដៅថ្ងៃ ក៏ចូលទៅជ្រកនៅក្រោមដើមឈើនោះ ហើយដាក់ឆ្នងរបស់គាត់នៅក្បែរខ្លួន រួចហើយក៏ប្រាសដេកនៅក្រោមម្លប់ឈើនោះឯង ។ មិនយូរប៉ុន្មាន ម្លប់ឈើក៏ហួតចេញពីមុខរបស់គាត់ ។ សត្វហង្សដែលទំនៅលើដើមឈើនោះ ហើយពន្លឺព្រះអាទិត្យចាំងចំមុខបុរសនោះដូច្នោះ ក៏ត្រជាងស្លាបរបស់ខ្លួន ដើម្បីការពារកំដៅថ្ងៃកុំឲ្យចាំងលើបុរសនោះ ដោយសេចក្តីអាណិតអាសូរចំពោះគាត់ ។

ដោយការលំបាកតាមផ្លូវ បុរសនោះដេកលក់យ៉ាងស៊ប់ហើយចំហមាត់ ។ សត្វកែក្អក ជាសត្វដែលតែងតែបំផ្លាញនូវសេចក្តីសុខរបស់សត្វដទៃ បានឃើញបុរសនោះ ដេកចំហមាត់ដូច្នោះ ក៏ជុះអាចម៍ជាក់ចំប្រហោងមាត់គាត់ រួចហើរបាត់ទៅ ។ បុរសនោះភ្ញាក់ឡើងក្រឡេកទៅឃើញហង្ស ក៏ដម្ងើងចិត្តរបស់ខ្លួនថ្នាក់ស្អាប់ទៅ ។

គតិធិពន្ធ៍

សត្វហង្ស	ខូចលែ	ក្តីអន្តរាយ
ព្រោះតែ	នយោបាយ	អសប្បុរស
ដែលតែង	បំផ្លាញ	សុខរបស់
ឥតស្គាយ	ស្រណោះ	ដល់តិចឡើយ ។
ប្រុស-ស្រី	ចានជ្រាប	ដំណើរនេះ
គប្បី	គេចវេះ	កុំភ្លៀតភ្លើយ
កុំស្ទ្រគ	ស្មាគម	ទំងាវឡើយ
ឯានេះ	ឯងហើយ	ផ្សុក្ខយើង ។

x

x x

១០) សត្វបបកទុប្បិត

ក្បែងកាលកន្លងទៅហើយ មានសត្វកេពីរជាសម្លាញ់ទឹងគ្នាយ៉ាងស្និទ្ធ ។ បណ្តាកេពីរនោះ កេមួយជាអ្នកដើរកេស៊ីតាមមាត់ប៉ឹង កេមួយទៀតជាអ្នកដើរកេស៊ីតាមដីកជ្រៅ ។ ក្នុងថ្ងៃមួយ សត្វពីរបានត្រីមួយ ។ កេមួយនិយាយថា ខ្ញុំចង់ស៊ី

ផ្នែកខាងលើ, គេមួយទៀតក៏ថា ខ្ញុំចង់ស៊ីជូរច្មាះដែរ, សត្វទាំងពីរពុំបានពិចារណាវាកការខុសត្រូវ ក៏ខាស់ខែងគ្នា ហើយនាំគ្នាទៅតាន់លំនៅសត្វចចកមួយ ។ ដល់ហើយក៏ប្រាប់តាមរឿងរ៉ាវ ហើយពោលថា សូមលោកមេត្តាជំនុំជំរះក្តីឲ្យយើងខ្ញុំផង ។

សត្វចចក កំនិយាយឲ្យគេទាំងពីរស្ងៀតនៅតង់ភ្នែ ពាក្យប្តេជ្ញារបស់ខ្លួន ហើយក៏កាត់ក្បាលត្រីមួយផ្នែកតន្ទុយមួយផ្នែក ជាក់ដោយឡែកពីគ្នា រួចនិយាយថា

អ្នកដើរតាមមាត់ប៊ឹង ត្រូវបានតន្ទុយ;

អ្នកមុជទឹកជ្រៅ ត្រូវបានក្បាល, ការឆ្ងាយ៉ាងនេះ ទើបយុត្តិធម៌ ។ រីឯខ្ញុំ ដែលជាអ្នកវិនិច្ឆ័យត្រូវបានសាច់តណ្ហាល ។ គេទាំងពីរ កំនឹកស្តាយក្រោយពន់ពេក ។ តាំងពីថ្ងៃនោះមក ក៏លែងជាស់ខែងគ្នា កាលណាបានត្រីមក យកមកបែងចែកស្មើភាគគ្នាស៊ីបញ្ចឹមជីវិតតទៅ ។

គតិពិពណ៌នា

ចចក	ជាសត្វ	ខ្លួរឆ្កែ
ពុំមាន	វិនិតិ	ឲ្យត្រឹមត្រូវ
តិតតែ	ចំណេញ	ជាក់ហោះច្បើ
គ្មានស្គាល់	ញាតិផៅ	សត្វជូចគ្នា ។
នេះសត្វ	ចចក	ជាតិតិរច្ឆាន
ព្រោះគ្នា	ពុំបាន	រៀនធម្មា
ទោះបើ	ខុសត្រូវ	បាកឃ្មាតឃ្មា
ពីព្រោះ	ធម្មា	មិនជាអ្វី ។
ចុះយើង	ជាមនុស្ស	យ៉ាងប្រណីត
ម្តេចក៏	ពេញចិត្ត	ខាងតែធំ
ស៊ីតូច	ស៊ីធំ	គ្មានប្រណី
នេះបើ	ស្រដី	អន់ជាងឆ្កែ ។

★

★ ★

រឿងពុទ្ធតាឆ្មៃពីទុធិជាតិ (គ)

ព្រះមហាក្សត្រនឹងព្រះអគ្គជាយាទ្រង់តែនហើយទ្រង់ស្រេបព្រះតំក្រៃនឹងគង្គាត្រជាក់ភ្លឺថ្លា ប្រាសដូចថ្មកែវនៅកង់ព្រះសុវណ្ណាភាជន៍ (bassine) ទ្រង់ព្រះពាស្តសម្រាប់រាជ្យហើយយាងចុះទៅគាន់ព្រះរាជរោងក្នុងព្រះបរមរាជវាំង តម្រង់ទៅតាមព្រះរាជមន្ទីរ ។ ព្រះរាជទេវីក្មេង, នៅលើព្រះទែនមាសត្រអូបឈ្ងុយឈ្ងប់ដោយបុប្ផាទ្រង់យកធូបដែលមានគំរប្បូរមកបក់, ហើយព្រះនាងទ្រង់ជាកចុះឡើងរួចផុតទៅទៀត ។

តើនៅរូមព្រះនាងទុក្ខពន់មានហេតុអ្វីខ្លះ? ពេលព្រះអរុណ.ចោលរស្មីក្រហមផ្លៅ ដូចផ្ទៃមាសនៅក្នុងរូមចាស់ទ្រុឌទ្រោម រះបំព្រះតំក្រៃព្រះនាងភ្ញីចែងចាំង, ព្រះនាងទុក្ខពន់ទ្រង់តែន មានបន្ទូលហៅស្វា, តែស្វានោះមិនឮឡើយ! ព្រះនាងទ្រង់រត់គ្រប់ប្រតល្អក ខាងនេះម្តងខាងនោះម្តង . . . តែស្វានោះមិននៅទេ! ព្រះនាងទ្រង់ព្រួយព្រះទ័យជាខ្លាំង, ទ្រង់សែ្វងរកពីបន្ទប់

ម្ដុយទៀបន្ទប់ម្ដុយ, ទ្រង់ឡើងទៀលើដំបូលរួមទ្រង់គាញមែកឈើ... ស្វានោះលែងរកឃើញ ឆ! គួរឲ្យអនិច្ច, ស្វារត់ចាត់ ។

ឆ! ស្វាល្ងង់លោមអើយ, ហេតុម្ដេចក៏នាងឯងចាកចេញពីរួម? តើនាងឯងទៀឯណា? ស្វានោះរត់ចេញពីយប់, ទុកឲ្យព្រះនាងទ្រង់ផ្ទំលក់តែម្ដុយព្រះអង្គឯងនៅក្នុងរួមចាស់ចាក់បែក... ។ បើកទ្វារតិចៗ ហើយបិទទៀវិញដោយថ្នមបន្ទើរៗហើយចាកចេញចាត់ទៀតាមផ្លូវដែលជម្រង់ទៀកាន់ព្រះបរមរាជវាំង ។

ទំនាយរបស់ស្វា

ព្រះមហាក្សត្រទ្រង់គង់នៅក្នុងព្រះរាជមន្ទីរសន្និចាត ។ រាជវង្សានុវង្សព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីអង្គុយគាល់ត្រៀបត្រានៅទីនោះ, អាមាត្យព្រមទាំងរដ្ឋមន្ត្រីស្ថិតនៅជុំវិញព្រះមហាក្សត្រ! នៅផ្លូវបូលមានពួកគាហាន ទឹងត្រមរក្សាព្រះអង្គ, ស្វានោះក៏រាតផ្លូវដើរវហួតទៀដល់ព្រះតំក្លែព្រះករុណា, ក្រាបក្រាយបង្គំដោយគោរព ហើយច្រៀងដោយចិត្តរីករាយថា:

មហារាជ ខ្ញុំបង្គំ សូមទូលទ្រង់
ដំណឹងពង្ស កបប្រពៃ ព្រះច័យស្រួល
ព្រះអង្គមាន រដ្ឋាយោធ ផ្សែងកំសួល
កបទំនូល ទុក្ខភនី មានរាជបុត្រ

ព្រះមហាក្សត្រទ្រង់មានបន្ទូលសួរស្វាថា: "នែស្វា, ស្វាឯង ច្រៀងអ្វី, មែនឬស្វា? ទុក្ខភនីជាព្រះអគ្គមហេសីឬង ទឹងប្រសូត្រព្រះរាជបុត្រ! បើមិនមែនយើងទឹងត្រាស់បង្គាប់ឲ្យពុះជាច្រើនកំណាត់, ឯងទឹងមាតាឯង, ទុក្ខភនី!

ស្វាឥតភ័យតក់ស្លុតច្រៀងតទៀត ។

មហារាជ ខ្ញុំបង្គំ ក្រាបទូលពិត
សូមជីវិត កបជោគជ័យ ដឿសសុទ្ធ
ទូលបង្គំ មហារាជ កបតាប់ទុត
ចាកជាបជុត សូមរាជទាន វត្ថុល្អ ។

ព្រះមហាក្សត្រទ្រង់ដកយកវឡែកធ្វើពីគយ: មុតិ (gaya-motis) ហើយទ្រង់ព្រះរាជទានទៀស្វា ទ្រង់មានព្រះបន្ទូលថា ឲ្យចេញពីទីនេះទៀចុះ ។

ស្វានោះលោតឡើងចុះហើយបង្ហិលខ្លួនបីដុំវិញ ស្វាក៏ចាកចេញចាត់ ។

(មានត)

★
★ ★

ម្ចាស់កែពិនិត

(ដោយ ពេញឯចិត្រ)

១ កំពស់របស់ដំរី ស៊ីធំជាង២ដងនៃរង្វង់ដើមអុំរបស់វា

ការវាស់កំពស់របស់ដំរីនោះ ដោយខ្លះទៀត្រូវវាស់ពីចុងដើមមុខដល់ស្មា ដូច្នោះការវាស់កំពស់ដំរី

(១) គយៈមុតិ (Gaya-motis) គយៈដំរី មុតិៈគជឬងតីឈ្មោកគជស្លឹងធំអស្ចារ្យ ។

បំបាក ដែលនឹងត្រូវកាត់ឫស្សីវែងៗ ហើយ
ទៅវាស់ដល់លើស្នាដីវ តែមានវិធីវាស់ផ្សេងកាត់
ទឹងវាស់កំពស់របស់ដីវបានដោយ ។ មួយបែប
គឺ ឲ្យវាស់រង្វង់ជុំវិញដើងដីវ ខាងណានិមួយក៏
កាលបើវាស់បានប៉ុន្មានហើយយកទៅគុណនឹង
លទ្ធផលក៏នឹងស្មើគានឹងកំពស់របស់ដីវនោះ ។ វិធី
បបនេះ ជាវិធីវាស់ដែលបានផលពិតប្រាកដ។
ថា បើយើងទៅប្រទះឃើញស្នាមដើងដីវ ឲ្យ
តមើលស្នាមដើងរបស់វាដែលជារង្វង់មូល ឯ
ដើងគ្រាយជារង់ព្រវែង កាលបើពិនិត្យដឹង
ថាជាស្នាមដើងមុខហើយ ឲ្យវាស់រង្វង់ជុំវិញនៃ
ដើងនោះ ឧបមាថា វាស់រង្វង់ជុំវិញដើងដីវ
ម ៥០ យកទៅគុណនឹងពីរ ក៏ដឹងថាដីវនោះ
ពស់ប្រាំម៉ែត្រ ។

២ កំពស់របស់មនុស្ស ស្មើនឹងប្រវែង ព្យាមរបស់អ្នកនោះ

បើយើងចង់ដឹងថា ខ្លួនយើងមានកំពស់ប៉ុន្មាន
ក៏អាចវាស់បានពីប្រវែង នៃព្យាមរបស់ខ្លួនយើង
ម៉ែត្រលាដែសន្ធឹងតាំងសងខាងឲ្យត្រង់ ហើយ
ប្រវែងនៃរយៈពីចុងម្រាមដៃកណ្តាលម្ខាងទៅចុង
ដៃកណ្តាលម្ខាងទៀត កាលបើវាសបានប្រវែង
ប្រវែងនេះក៏ស្មើនឹងកំពស់របស់ម៉ែត្រ ។ ឧបមា
ម៉ែត្រវាស់ប្រវែងនៃព្យាមរបស់ម៉ែត្របាន ១៦០
ខ្លួនម៉ែត្រក៏មានកំពស់ ១៦០ស.ម ដែរ ។

៣ រលំបណ្តាលពេជ្រ អាចប្រើជាថ្នាំលៃងអាភៀនបាន

គ្រឿងឧបករណ៍នៃការលៃងអាភៀននោះ គឺ
កម្លាំងចិត្តដ៏រឹងប៉ឹងរបស់អ្នកដែលដក់អាភៀន ។ បើអ្នក
ដែលញៀនអាភៀនគាំងចិត្តថា នឹងលៃងដោយពិត
ប្រាកដ ត្រូវជាមនុស្សដែលមានកម្លាំងចិត្តដ៏រឹងប៉ឹង
ពិតៗ ទើបនឹងយកជ័យជំនះអាភៀនបាន ហើយ
មិនត្រូវព្យាយាមទៅប៉ះពាល់វាទៀតទេ ។ ក្រៅពីនេះ
សូមឲ្យប្រើថ្នាំដែលនឹងពោលតទៅនេះ ជាជំនួយក្នុង
ការបំបាត់នូវសេចក្តីរសាប់រសល់នៃចិត្ត ថ្នាំនោះគឺ :

ឲ្យយករលំបណ្តាលពេជ្រប៉ុន្មានក្តួនដៃមក
រិសមួយជុំក្បាលអ្នក ដែលនឹងលៃងអាភៀន
ហើយឆ្ងាយដាក់ទៅក្នុងឆ្នាំង អត់ដង្ហើមប្បិប
យកអំបិលពគ្រាប់ធំៗ ដាក់ទៅជាមួយគ្នា
ហើយចាក់ទឹកដាំឲ្យពុះ ។ ឲ្យយកទឹកដែល
ដាំពុះនេះមកផឹកមួយប្លែពងង មុនពេល
អាហារ ផឹកម្តង ១ ពែងតែ ផឹកឲ្យគ្រប់ពីប្លែ ។
កុងរវាងដែលផឹកនេះ បើប្លែណាគ្រូនឲ្យលេប
គីនីន (QUININE) បាន ។

ថ្នាំនេះ មានគេពិសោធបានផលប្រៃនមកហើយ
ក្នុងប្រទេសថៃយ៍ ហើយប្រាកដថាបានផលល្អ ផ្ទៃ
ឲ្យអ្នកដែលញៀនអាភៀនលៃងអាភៀន បានដោយ

មិនវាសាប់សល់ចិត្តយ៉ាងណាឡើយ ។

៤ យន្តហោះទម្លាក់គ្រាប់បែកធ្លាយពីបំណុចបំណងប៉ុន្មាន

យន្តហោះទម្លាក់គ្រាប់បែក ដែលហោះខ្ពស់ដល់ទៅ១២.០០០ម៉ែត្រ កាលបើនឹងទម្លាក់គ្រាប់បែកតម្រង់ចំណុចណាមួយ ត្រូវផ្តើមពិនិត្យមើលចំណុចបំ ណាងធ្លាយពីចំណុច ដែលនឹងត្រូវការទម្លាក់គ្រាប់បែកតាំងពីរយៈចម្ងាយ៩០គ.ម ហើយកាលរបើហោះឆ្ងាយពីចំណុចបំណងជារយៈផ្លូវ៨គ.ម ទើបនឹងទម្លាក់គ្រាប់បែកនេះមក រយៈដូចពោលមកនេះ សំរេចដល់យន្តហោះដែលទម្លាក់គ្រាប់បែកក្នុងវិថី ដែលអាកាសស្រឡះល្អហើយមានខ្យល់ជាប្រក្រតី ។

★

★ ★

សូមថ្វាយបង្គំ – ជំរាបព្រះតេជគុណ លោក អ្នក នាងនឹងមិត្តជាទីគោរព ។

ដោយទស្សនាវដ្តីមិត្តសាលាចាស់មានកម្ពាំងទន់ខ្សោយខាងថវិកា មិនអាចទ្រាំទ្រដើរតែឯងរស់នៅបានយូរយារឡើយ ។

ចំពោះការរក្សាទុកដើរតែទន់ខ្សោយបែបនេះ សូមមិត្តមេត្តាសង្គ្រោះដល់ទស្សនាវដ្តី - មិត្តសាលាចាស់ផង ។

មានតែទស្សនាវដ្តីនេះមួយគេ ដែលកំពុងតែមានជីវិតស៊ូលុះសព្វថ្ងៃ តែត្រូវជាបត្រដួសយ៉ាងក្រៃលែង បើមិត្តបណ្តែតបណ្តោយមុខជារលត់ទន្ទេចាលមិត្តហើយ ។

សូមមិត្តតាំងចិត្តប្រកបដោយមេត្តាដល់សាសនារបស់យើង ហើយចាប់ផ្តើមជើងដៃម្ខាងវាដោយគតិចិត្តជាកុសល ។

បណ្ណាធិការ

ហួត-ហៀម

សមាគមមិត្តសាលាចាស់ ភូមិជវដ្ឋ

ទីសំណាក់ការនៅវត្តលង្កា សង្កាត់លេខ ១ ក្រុងភ្នំពេញ

លិខិតជូនដំណឹង

សូមនិមន្ត—អញ្ជើញព្រះតេជព្រះគុណអស់លោក—អ្នកនឹងមិត្តភ័ងឆ្ងាយ

ទៅកាន់មហាសន្និបាត នៅថ្ងៃអាទិត្យ ទី ៨ ខែមករា គ-ស-១៩៤៦ វេលាម៉ោង ១៥ (ម៉ោង ៣ រសៀល) នៅទីសាលាបាល័រងវត្តលង្កា សង្កាត់លេខ ១ ក្រុងភ្នំពេញ ដើម្បី:

១) ស្តាប់សេចក្តីថ្លែងរបស់អធិបតី អំពីព្រឹត្តិការណ៍នៃសមាគមពីកន្លងមក,

២) ស្តាប់សេចក្តីថ្លែងរបស់ហិរញ្ញិកអំពីស្ថានហិរញ្ញវត្ថុរបស់សមាគម,

៣) បោះឆ្នោតជ្រើសតាំងក្រុមអភិបាលថ្មី សម្រាប់ឆ្នាំ ១៩៤៦ ។

អធិបតី

ភ័យ-ប៊ុត

ជំនែឡជារៀ

ក្នុងប្រទេស			ក្រៅប្រទេស	
១ ឆ្នាំ	៦ ខែ	៣ ខែ	១ ឆ្នាំ	៦ ខែ
១៨០$00	១០០$00	៥០$00	៣៦០$00	២០$00

អ្នកទទួលផ្សារ

សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur **MAO-MEY** Ministère de L'Intérieur P.Penh





មហាកុដិសម្តេចព្រះធម្មលិខិតវត្តលង្កា

ព្រះវិហារវត្តបទុមវតី

រង់ចាំអានទឹងមើលរូបភាព

ប្រវត្តិសាស្ត្រនីមួយៗជាតិ ជាប្រវត្តិសាស្ត្រមួយក្បាល ដែលមានឈ្មោះថា "ង្កុំប្រុងខ្ញុំអើយ" ដំណួសពេលដែលអាត់ខាងនេះ ដោយមានការៈយើងខ្ញុំកំពុងរៀបរៀងលេខពិសេសទទួលពិពរណាអន្តរជាតិ ដែលមានរាល់សព្វគ្រប់ពីពិធីបុណ្យទឹងការប្រឡងប្រណែងរបស់នារី ហើយមានរូបភាពនៃការប្រឡងនារីគ្រប់បែបយ៉ាងផ្តិតជាប់នៅនោះផង ។

សូមមិត្តអត្ថយោសទឹងរង់ចាំអានលេខពិសេសនេះ មិត្តទឹងឃើញអនាគតនៃការជ្រើសរើសនារីឯកសម្រាប់ប្រទេសយើង ហើយទឹងកលល្បិចនៃចោរតន្ត្រីយ៍ខ្មៅ ព្រមទាំងការឈ្លាសវៃនៃលោកអធិការប៉ូលិសក្នុងវិស័យនៃប្រលោមលោកនោះ ។

សំខាន់មួយបែបទៀត

ទស្សនាវដ្តីមិត្តសាលាចាស់ ក៏ត្រូវចេញលេខពិសេសដែលមានពោលដោយម៉ាត់ចត់ ពីការប្រឡងប្រណែងនារីរៃវមួយអន្លើដោយរូបភាពគ្រប់គ្រាន់ ដែលមិត្តឃើញហើយត្រូវតែជារៀងមិនបាន ។

នារីឯកកម្ពុជាទឹងបង្ហាញសភាពឆើតឆាយលើវិស័យនៃទស្សនាវដ្តីមិត្តសាលាចាស់ ក្នុងពេលដ៏ខ្លីខាងមុខនេះ ។

សូមមិត្តកុំភ្លេចអានទស្សនាវដ្តីមិត្តសាលាចាស់, មិត្តជ្រាបបានទេ នៅសល់តែទស្សនាវដ្តីនេះមួយទេ ដែលអាចជាតន្ទីនៃជនរួមជាតិទឹងសាសនាតទៅអនាគតសម្រាប់ប្រទេសយើង ។

កុំភ្លេច ! ! . . . កុំភ្លេច ! . . . អានទស្សនាវដ្តីមិត្តសាលាចាស់ ! . . .

ពោធិពុទ្ធ អ៊ុក-ម៊ី-កុល